ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឧបករណ៍ដ៏ពិសិដ្ឋ

# តន្ត្រីខ្មែរ



រៀបរៀងដោយ

សាស្ត្រាចារ្យ ម៉ៅ ឡឿខ

CAMBODIA

LQ
781
MAO

www.elibraryofcambodia.org

# ស្វែងយល់ពីវិញ្ញាសិល្បៈតន្ត្រីខ្មែរ




**លោក ម៉ៅ គឿន**

សាស្ត្រាចារ្យតន្ត្រីបុរាណ

មហាវិទ្យាល័យតូរ្យតន្ត្រី

សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ


**សញ្ញាបំត្រកិត្តិយស វីរសិល្បករ ឆ្នាំ១៩៩៧**

ថ្ងៃ ខែ ឆ្នាំ កំណើត : ០១ មករា ១៩៣៧

កើតនៅភូមិសំរោង ឃុំសូភី ស្រុកបាទី ខេត្តតាកែវ


ឧបត្ថមថវិកាដោយអង្គការឃុណោស្តកម្ពុជា

បោះពុម្ពលើកទី២ ចំនួន ៣៣៥ ច្បាប់

ខែតុលា ឆ្នាំ២០០០

ព.ស ២៥៤៤



National Library of Cambodia

00023940

www.elibraryofcambodia.org

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតថ្លែងអំណរគុណ

សូមថ្លែងអំណរគុណចំពោះអង្គការយូណេស្កូកម្ពុជា ដែលបានជួយថវិកា ក្នុងការបោះពុម្ពលើកទី២ នេះ ចំនួន ៣០០ច្បាប់ ថែមទៀត ដើម្បីប្រយោជន៍ជាកេរ្តិ៍មរតក វប្បធម៌របស់ខេមរៈជាតិ ។ ហើយសូមថ្លែងអំណរគុណជាពិសេសលោក ហ្វេងហ្រេម ប៊ីហ្គ ដែលបានជួយខ្នះខ្នែងចាត់ចែងគ្រប់យ៉ាងក្នុងការបោះពុម្ពលើកទី២ នេះ ។

ទូលព្រះបង្គំសូមថ្លែងនូវព្រះមហាករុណាធិគុណ របស់ព្រះករុណា សម្តេចឪ និង សម្តេចម៉ែ ដែលយកព្រះទ័យទុកដាក់លើកទឹកចិត្ត សរសើរស្នាដៃនេះ ហើយថែមទាំងប្រោសព្រះរាជទានរង្វាន់ចំពោះទូលព្រះបង្គំ ចំនួន 500 $ ( ប្រាំរយដុល្លាអាមេរិក ) ។

សូមថ្វាយព្រះរាជកុសលដ៏ថ្លៃថ្លានេះ ចំពោះព្រះអង្គជាម្លប់ដ៏ត្រជាក់ដល់កូនចៅជ្រកកោនបានយឺនយូរតទៅអានាគត និង សូមថ្លែង អំណរគុណ ចំពោះសម្តេច **ហ៊ុន សែន** និង លោកជំទាវ ដែលបានជួយគាំទ្រ ហើយបានផ្តល់ ថវិកាបោះពុម្ពលើកទី ១ ។

សូមអោយសម្តេច និង លោកជំទាវព្រមទាំងក្រុមគ្រួសារទាំងអស់ បានប្រកបដោយសិរីសួស្តីវិបុលសុខគ្រប់ប្រការ ទូលព្រះបង្គំខ្ញុំបាទសូមឧទ្ទិសស្នាដៃនេះ ជូនលោកអ្នកមានគុណព្រមទាំងខេមរៈជនគ្រប់ ១ រូប ។

សូមអរគុណចំពោះកញ្ញា **ណា សុមិស្សរាត** សាស្ត្រាចារ្យតន្ត្រីសាកលនៅមហាវិទ្យាល័យតូរ្យតន្ត្រី ជនជាតិអង់គ្លេស ដែលបានជួយបកប្រែសំរួលពីភាសាខ្មែរទៅជាអង់គ្លេស ។

សូមអោយស្នាដៃនេះ ក្លាយជាប្រយោជន៍រួមរបស់កុលបុត្រខ្មែរ គ្រប់រូប សូមអោយស្រឡាញ់ និង ទ្រទ្រង់សិល្បៈវប្បធម៌ ដែលជាកេរ្តិ៍មរតកជាព្រលឹងជាតិយើង ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០០

ហត្ថលេខា

ម៉ៅ គឿង សាស្ត្រាចារ្យ តន្ត្រីបុរាណ

www.elibraryofcambodia.org

ព្រះករុណាព្រះបាទសម្ដេច

ព្រះនរោត្តម សីហនុ

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ជូន លោក ម៉ៅ កឿង

តំណាងសាស្ត្រាចារ្យគ្រូពេទ្យបុរាណ

វិទ្យាល័យគ្រូពេទ្យខ្មែរនៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

លោកសាស្ត្រាចារ្យជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ

ខ្ញុំបានទទួលរួចហើយលិខិតរបស់លោកសាស្ត្រាចារ្យ ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០០ ព្រមទាំងសៀវភៅគ្រូពេទ្យខ្មែរមួយច្បាប់ផង ។

ខ្ញុំសូមសំដែងនូវអំណរគុណដ៏ជ្រាលជ្រៅ និងសូមសរសើរដ៏កក់ក្ដៅលោកសាស្ត្រាចារ្យដែលបានខិតខំធ្វើការស្រាវជ្រាវ រៀបចំ ចងក្រងឯកសារទាំងនោះជាសៀវភៅ ដើម្បីផ្សព្វផ្សាយក្នុងមជ្ឈដ្ឋានជាតិ ក្នុងគោលបំណងថែរក្សាវប្បធម៌ជាតិយើងឱ្យបានគង់វង្សតរៀងទៅ ។

ខ្ញុំសូមជួយឧបត្ថម្ភជាថវិកានូវទឹកប្រាក់ចំនួន៥០០ដុល្លារអាមេរិក (ប្រាំរយដុល្លារអាមេរិក) ហើយសូមលោកសាស្ត្រាចារ្យអញ្ជើញទៅយកទឹកប្រាក់ចំនួន៥០០ដុល្លារអាមេរិកនេះពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី គង់ សំអុល ។

សូមលោកសាស្ត្រាចារ្យ ទទួលនូវសេចក្ដីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ អំពីខ្ញុំ និងសម្ដេចព្រះរាជអគ្គមហេសី ។

ន សីហនុ

**នរោត្តម សីហនុ**

ភ្នំពេញ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០០

www.elibraryofcambodia.org

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ម៉ៅ ឡឿង** ជាសាស្ត្រាចារ្យតន្ត្រីបុរាណ នៅមហាវិទ្យាល័យតន្ត្រីនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។

សូមគោរពជូន

សម្ដេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីទី២ និងជាអនុប្រធានគណបក្សប្រជាជនកម្ពុជា ព្រមទាំងលោកជំទាវ ។

ក្រោយពីខ្ញុំបាទ **ម៉ៅ ឡឿង** បានទទួលលិខិតថ្លែងអំណរគុណនិងកោតសរសើរពីស្នាដៃខ្ញុំដែលបានសរសេរចងក្រងឯកសារតន្ត្រីបុរាណខ្មែរទុកឱ្យកុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយសិក្សាស្រាវជ្រាវខ្ញុំមានសេចក្ដីរីករាយសប្បាយរីករាយណាស់ ទន្ទឹមនេះទៀត សម្ដេច និងលោកជំទាវបានជួយជំរុញលើកទឹកចិត្តដល់ខ្ញុំ ឱ្យកាន់តែមានកម្លាំងចិត្តខ្លាំងក្លាថែមទៀតដោយសម្ដេចនិងលោកជំទាវបានផ្ដល់ថវិកាដ៏ថ្លៃថ្លាផ្ទាល់ ជួយបោះពុម្ពសៀវភៅនេះចំនួន ១០០ក្បាល ដើម្បីផ្សព្វផ្សាយនិងថវិកាចំនួន ៥០០ដុល្លារអាមេរិក ទៀតផង ។

ចំពោះកុសលផលបុណ្យ ដែលកើតចេញពីទឹកចិត្តសប្បុរសធម៌ មនុស្សធម៌របស់សម្ដេចមកលើសៀវភៅនេះ ខ្ញុំបាទសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធក្នុងលោកទាំងអស់ សូមជួយថែរក្សាសម្ដេចនិងលោកជំទាវ ក្នុងនាមជានាយករដ្ឋមន្ត្រីផង និងក្នុងនាមជាប្រមុខបក្សផង ឱ្យមានសុខភាពល្អ ដើម្បីបន្តដឹកនាំនាវាកម្ពុជាឆ្ពោះទៅកាន់ត្រើយសុភមង្គល ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិនា ឆ្នាំ១៩៩៨*

ម៉ៅ ឡឿង

www.elibraryofcambodia.org

សម្តេច ហ៊ុន សែន

នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

**សូមផ្ញើជូន**

**លោក ម៉ៅ តឿង សាស្ត្រាចារ្យតន្ត្រីបុរាណ**

**មហាវិទ្យាល័យតន្ត្រី**

លោកសាស្ត្រាចារ្យជាទីគោរពរាប់អាន !

ខ្ញុំបានទទួលសៀវភៅមួយក្បាលរបស់លោករួចហើយ ដែលលោកបានផ្ញើរមកឱ្យខ្ញុំ ខ្ញុំសូមកោតសរសើរចំពោះស្មារតីយកចិត្តទុកដាក់ស្រឡាញ់ប្រពៃណី វប្បធម៌ជាតិ ខិតខំសរសេរ បង្រួមបោះពុម្ពជាសៀវភៅ ស្តីពីតន្ត្រីប្រពៃណីជាតិ សម្រាប់ជាជំនួយបណ្តុះបណ្តាលដល់ស្មារតីកុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយឱ្យយល់ពីតម្លៃវប្បធម៌ជាតិ ។

ខ្ញុំសូមអបអរសាទរ និងសូមរួមចំណែកជួយឧបត្ថម្ភបោះពុម្ពសៀវភៅនេះចំនួន ១០០ក្បាល ដើម្បីឆ្លើយតបនឹងការខិតខំប្រឹងប្រែងយកចិត្តទុកដាក់របស់លោកចំពោះជាតិមាតុភូមិ នៃយើងរាល់គ្នា ។

សូមលោកសាស្ត្រាចារ្យបានប្រកបដោយពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ និងពរជ័យពីរប្រការទៀតគឺអភិវឌ្ឍន៍និងសុភមង្គលកុំបីឃ្លៀងឃ្លាតឡើយ ។

សូមលោកសាស្ត្រាចារ្យ ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៨

- [illegible]
[illegible] USD.
([illegible])

ហ៊ុន សែន

www.elibraryofcambodia.org

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទូលព្រះបង្គំខ្ញុំព្រះករុណា ឈ្មោះ ម៉ៅ កឿង សាស្ត្រាចារ្យ តន្ត្រីបុរាណនៅវិទ្យាល័យតូរ្យតន្ត្រី នៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។

សូមក្រាបថ្វាយបង្គំក្រោមល្អងធូលីព្រះបាទនៃ
សម្ដេចឪ និង សម្ដេចម៉ែ ជាព្រះបិតាឯករាជ្យជាតិ និង បិតាឧបត្ថម្ភជាតិ
ដោយកតញ្ញូកតវេទិតា

<u>កម្មវត្ថុ</u> : សូមថ្វាយសៀវភៅតន្ត្រីបុរាណមួយច្បាប់ចំពោះសម្ដេចឪ និង សម្ដេចម៉ែ

ដោយយោគទៅតាមការខ្វះខាតក្បួនខ្នាតជាច្រើនស្ទើរតែគ្មានសល់ ដោយសារប្រទេសយើងមានការទទួលទារុណកម្ម អកុសល ផ្នែកសង្គមកិច្ច ការរស់នៅរបស់ប្រជារាស្ត្រដោយវេទនាហួសនិស័យ ដូច្នេះបានជាទូលព្រះបង្គំជាខ្ញុំខំប្រឹងប្រែង ព្យាយាមធ្វើការស្រាវជ្រាវរកក្បួនខ្នាត ដើម្បីធ្វើឯកសារភ្លេងសំរាប់បណ្តុះបណ្តាលសិស្ស និស្សិត ទៅអនាគត ទិសដៅពង្រឹង និង ពង្រីកព្រលឹងជាតិ ចងក្រងក្បួនខ្នាត និង បទភ្លេងបុរាណរបស់យើងអោយបានត្រឹមត្រូវពិតប្រាកដកុំអោយប្រែក្លាយខុសពីមុន សៀវភៅដ៏ដូចជាតន្ត្រីផ្នែកបុរាណ ទូលព្រះបង្គំបានស្រាវជ្រាវថតបញ្ចូលក្នុងខ្សែអាត់ចំនួន ៣០០បទ ហើយ ក្នុងបទភ្លេងនេះមាន : បទភ្លេងអារក្ស បទភ្លេងអាពាហ៍ពិពាហ៍ បទមហោរី បទភ្លេងពិណពាទ្យ បទភ្លេងបាសាក់ ទុកជាឯកសារ ប៉ុន្តែបច្ចុប្បន្ននេះនៅខ្វះថវិកាជាច្រើន ដើម្បីធ្វើការស្រាវជ្រាវបន្តទៅទៀត ទូលព្រះបង្គំជាសាស្ត្រាចារ្យតន្ត្រីបុរាណទាំងអស់គ្នាមានសង្ឃឹមតែលើសម្ដេចឪ និង សម្ដេចម៉ែតែប៉ុណ្ណោះ ដែលអាចជួយឧបត្ថម្ភជាថវិកាបន្តិចបន្តួចក្តី ដើម្បីធ្វើការស្រាវជ្រាវបទភ្លេងបុរាណនេះតទៅទៀត ដើម្បីផ្សព្វផ្សាយទូទាំងប្រទេសអោយកុលបុត្រកុលធីតាបានយល់ដឹងពីវិស័យវប្បធម៌ ប្រពៃណីជាតិផ្នែកបុរាណនេះផង ដែលជាកេរ្តិ៍មរតក ឬ ក៏ជាអច្ឆរិយវត្ថុដ៏មានតម្លៃរបស់ដូនតារបស់យើង ។

ជាទីបញ្ចប់ទូលព្រះបង្គំជាសាស្ត្រាចារ្យតន្ត្រីបុរាណទាំងអស់គ្នា សូមបួងសួងគុណព្រះរតនត្រ័យ គឺ ពុទ្ធរតនៈ ធម្មរតនៈ សង្ឃរតនៈ និង បារមីព្រះមហាស្វេតឆ័ត្រ និង វត្ថុស័ក្តិសិទ្ធក្នុងលោក សូមលោកមេត្តាអភិបាលថែរក្សា អង្គសម្ដេចឪ និង សម្ដេចម៉ែខ្ញុំ សូមព្រះអង្គស្ថិតនៅក្រោមម្លប់បារមីដ៏ត្រជាក់ប្រកបដោយពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណ កុំបីឃ្លៀងឃ្លាតឡើយ តួមិនគួរសូមព្រះមេត្តាប្រោសក្រោមល្អងធូលីព្រះបាទ ។

ភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០០
តំណាងសាស្ត្រាចារ្យតន្ត្រីបុរាណ

ម៉ៅ កឿង

www.elibraryofcambodia.org

# មាតិការឿង


| | ទំព័រ |
|---|---|
| ⊕ មតិអ្នកនិពន្ធ | i |
| ១ - បុរេប្រវត្តិសង្ខេបនៃវប្បធម៌ផ្នែកតន្ត្រីបុរាណខ្មែរ | ១ |
| ២ - ចរិតខ្មែរ | ៥ |
| ៣ - អំពីតន្ត្រីបុរាណខ្មែរ | ៦ |
| ក. អំពីនិយមន័យតន្ត្រី | ៦ |
| ខ. តន្ត្រីនិងដំណើរជីវិតនៃប្រជាជនខ្មែរ | ៧ |
| គ. ជំពូកឧបករណ៍តន្ត្រីបុរាណខ្មែរ | ១១ |
| ឃ- អំពីវង់តន្ត្រីបុរាណខ្មែរ | ១២ |
| ៤- ភារកិច្ចវង់តន្ត្រីផ្សារភ្ជាប់ជាមួយនឹងពិធី | ២៧ |
| ក. វង់តន្ត្រីអារក្ស | ២៧ |
| ខ. វង់តន្ត្រីរៀបអាពាហ៍ពិពាហ៍មង្គលការ | ៣៦ |
| គ. វង់តន្ត្រីគងស្គរ ឬ ទាំមូង | ៤៧ |
| ឃ. វង់តន្ត្រីខ្លងធ្លាក់ ( ស្គរយោល ឬ ស្គរឈ្នះ ) | ៤៨ |
| ង. វង់តន្ត្រីវាទ្យភណ្ឌ ឬ ពាទ្យភណ្ឌតន្ត្រី ឬ ពិណពាទ្យ | ៤៩ |
| ច. វង់តន្ត្រីមហោរី | ៥២ |
| ឆ. វង់តន្ត្រីមហោរីថ្ងៃ | ៥៥ |
| ជ. វង់តន្ត្រីភ្លេងយីកេ | ៥៦ |
| ឈ. វង់តន្ត្រីភ្លេងអាប៉េ | ៥៧ |
| ញ. វង់តន្ត្រីអាយ៉ៃ | ៥៨ |
| ដ. វង់តន្ត្រីភ្លេងមហោរី | ៦០ |
| ឋ. វង់តន្ត្រីភ្លេងប្រាមោជ្ជទ័យ ( ប្រាមោទ្យម័យ ) | ៦១ |
| ឌ. វង់តន្ត្រីភ្លេងខែន | ៦២ |
| ឍ. វង់តន្ត្រីបាសាក់ | ៦៣ |
| ៥ - ពិធីសំពះគ្រូ ផ្នែកតន្ត្រីបុរាណខ្មែរ | ៦៧ |
| ក. ពិធីសំពះគ្រូធំ ក្នុងវង់ពិណពាទ្យ | ៦៨ |
| ខ. ពិធីសំពះគ្រូតូច ក្នុងវង់ពិណពាទ្យ | ៧៧ |
| គ. ពិធីសំពះគ្រូ ក្នុងវង់មហោរី | ៨១ |
| ៦ - សំយោគ | ៨៧ |


www.elibraryofcambodia.org

## មតិអ្នកនិពន្ធ

ជាបឋមទូលព្រះបង្គំខ្ញុំបាទឈ្មោះម៉ៅភឿង ជាសាស្ត្រាចារ្យផ្នែកតន្ត្រីប្រពៃណីបូរាណ ធ្វើការនៅមហាវិទ្យាល័យតូរ្យតន្ត្រីនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈសូមខមាលទោសពីសំណាក់ព្រះអង្គម្ចាស់សម្តេច ឯកឧត្តមលោកជំទាវ អស់លោកលោកស្រីអ្នកនាងកញ្ញាព្រមទាំងបងប្អូនរួមជាតិទាំងអស់ជាទីគោរព ដោយសូមបញ្ចេញមតិដូចខាងក្រោមនេះ :

មុននឹងឧប្បត្តិឡើងជាអត្ថបទស្រាវជ្រាវដែលមានចំណងជើងថា : «ការស្វែងយល់ជុំវិញសិល្បៈតន្ត្រីខ្មែរ »នេះ ទូលព្រះបង្គំខ្ញុំបាទបានកំណត់ទុកក្នុងចិត្តដោយប្តូរផ្តាច់ថាវិស័យតូរ្យតន្ត្រីបូរាណដែលយើងអាចចាត់ទុកថាជាព្រលឹងឬអត្តសញ្ញាណជាតិបានជ្រួតជ្រាបផ្តិតជាប់ក្នុងបេះដូងរបស់ខ្មែរគ្រប់រូប តាំងពីអតីតកាលមកទល់នឹងបច្ចុប្បន្នកាលនេះ ដោយហេតុថាសំនៀងសញ្ចេតនាជាកេរ្តិ៍មរតកដ៏មានតម្លៃបំផុតនៃដូនតារបស់ខ្មែរយើងដែលបានផ្ទេរឱ្យកុលបុត្រកុលធិតាខ្មែរគ្រប់រូប ។

ក្រោយពីថ្ងៃ៧មករា ឆ្នាំ១៩៧៩មក ស្ថានភាពវិស័យសិល្បៈវប្បធម៌ផ្នែកតន្ត្រីបូរាណរបស់ខ្មែរមានការបាត់បង់នូវឯកសារទ្រឹស្តីប្រវត្តិតន្ត្រីនិងក្បួនខ្នាតផ្សេងៗជាច្រើនស្ទើរតែគ្មានសល់ឡើយ ជាហេតុដែលនាំឱ្យមានផលវិបាកក្នុងការបណ្តុះបណ្តាលសិស្សជំនាន់ក្រោយៗគួរអោយព្រួយបារម្ភយ៉ាងខ្លាំង។ ដើម្បីរួមចំណែកប្រមូលផ្តុំនិងថែរក្សាឱ្យបានគង់វង់ឡើងវិញសមតាមគោលបំណងរបស់ទូលព្រះបង្គំខ្ញុំបាទ ធ្លាប់បានសិក្សាស្រាវជ្រាវផ្នែកជាតិពន្ធុតន្ត្រីវិទ្យានេះខ្លះៗ និងជាវិជ្ជាជីវៈផ្ទាល់ ចូលរួមបំពេញការរាល់



www.elibraryofcambodia.org

សកម្មភាពសំដែងក្នុងពិធីបុណ្យប្រពៃណីជាតិ ក្នុងវង់របាំបុរាណនិងល្ខោនដីទៃទៀត ផងធ្វើឱ្យមនោសញ្ចេតនាឆន្ទៈមោះមុតផុសឡើងយ៉ាងសកម្មដើម្បីបំរើតាមសំណូមពរនូវវិស័យនេះឱ្យបានទាន់ពេលវេលា ។ ឆ្លងតាមបទពិសោធន៍ទាំងនេះទូលព្រះបង្គំខ្ញុំបានព្យាយាមគ្រប់មធ្យោបាយធ្វើការស្រាវជ្រាវរាវរកឯកសារ និងដកស្រង់ពីសៀវភៅរបស់អស់លោកអ្នកចេះដឹងច្រើនពីជំនាន់មុនៗមួយចំនួន ក្រុមជំនុំទំនៀមទំលាប់ខ្មែរមួយចំនួន ពីឯកសារស្រាវជ្រាវបូរាណវិទ្យារបស់លោក ហ្សឺគ សេដែស អ្នកប្រាជ្ញជនជាតិបារាំងមួយចំនួន បូកផ្សំនិងការសិក្សាស្វែងយល់ដឹងពីជំនាញឯកទេសរបស់ខ្លួនមួយចំនួនផង ។

ក-មួយចំណែកបានការជួយគាំទ្រពីលោកឯកឧត្តម ឆេង ផុន អតីតរដ្ឋមន្ត្រីក្រសួងឃោសនាការនិងវប្បធម៌ បានផ្តល់នូវមតិដ៏ល្អៗមួយចំនួន ។

ខ-បានលោក ពេជ្រទុំ ក្រវិលប្រធាននាយកដ្ឋានសិល្បៈទស្សនីយភាព ជួយណែនាំពិភាក្សាអំពីប្រវត្តិទំនាក់ទំនងនឹងអត្ថន័យតាមវង់មួយចំនួន និងជួយពិនិត្យការស្រាវជ្រាវនេះឱ្យបានឆាប់រហ័ស ។

គ-បានការជួយជ្រោមជ្រែងពីឯកឧត្តម មីសែលត្រាណេ អនុរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈបច្ចុប្បន្ន ជួយបំភ្លឺបន្ថែម កែសំរួលនូវអត្ថន័យខ្លឹមសារក្នុងអត្ថបទចៃបទភ្លេងមួយចំនួន និតខំខ្វល់ខ្វាយរកមធ្យោបាយដើម្បីបោះពុម្ពឱ្យបានចេញជាសៀវភៅនេះឡើង ។

ឃ-បានលោកបណ្ឌិត អ៊ុំ មង្គល់ ទីប្រឹក្សារដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ



www.elibraryofcambodia.org

ជួយផ្ដល់ថវិកាវាយកុំព្យូទ័រ ។

ង-បានលោកបណ្ឌិតសំ សំអាង សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ជួយបកប្រែ និងប្រែសម្រួលជាភាសាអង់គ្លេស ។

ច-បាននាងកញ្ញា កាតឺរីន ជួយបកប្រែជាភាសាអង់គ្លេស មួយចំនួន ។

ឆ-បាននាងកញ្ញាម៉ៅ ឡេណា ជួយរៀបចំកែសម្រួលអត្ថបទខ្មែរ និងវាយកុំព្យូទ័រ ។

ជ-បានលោក ណុប សំបូរណា ជួយថតរូប ។

ពេលវេលាមិនអាចរង់ចាំឬអូសបន្លាយវែងឆ្ងាយទៅមុខបានឡើយ អត់ទ្រាំពុំបានត្រូវបង្ខំចិត្តធ្វើការស្រាវជ្រាវ ប្រមូលផ្ដុំចងក្រងក្រងនូវ : អត្ថសារណាសម្បទានបទការស្វែងយល់ជុំវិញសិល្បៈតន្ត្រីខ្មែរនេះជាបន្ទាន់ អាចសន្មត់បានថាជាពន្លឺផ្នែកតូចមួយរួមជាមួយនិងពន្លឺនៃផ្នែកដ៏ទៃទៀតដើម្បីទ្រទ្រង់នូវព្រលឹងអត្តសញ្ញាណជាតិ កុំឱ្យមានការបាត់បង់សាបសូន្យបានឡើយពិសេសទុកជាសន្និធានកម្មនៃតន្ត្រីខ្មែរសំរាប់កុលបុត្រកុលធិតាជំនាន់ក្រោយៗបានយល់ដឹងនិងឃើញច្បាស់អំពីបុរេប្រវត្តិខ្លះៗពីរបៀបរបបអត្ថន័យខ្លឹមសារនិងលក្ខណៈពិសេសរបស់ជាតិខ្លួនផង ។

សូមអភ័យទោសជាមុននូវកំហុសខុសឆ្គងទាំងឡាយដែលមិនអាចជៀសផុត ពេលខ្លី និងជាបន្ទាន់ផងការរៀបរាប់នូវចំណុចនិមួយៗនិងការវែកញែកមិនបានល្អិតល្អន់ពិស្ដារ គ្រាន់តែបង្ហាញនូវគោលៗខ្លីប៉ុណ្ណោះ ដើម្បីឱ្យប្អូនៗជំនាន់ក្រោយបានទុកជាទុនខ្លះៗ



www.elibraryofcambodia.org

សំរាប់ធ្វើការត្រិះរិះពិចារណានិងស្រាវជ្រាវទៅពេលអនាគតទៀត។ រាល់ជំពូកពាក្យ ពេជន៍ឃ្លោងឃ្លាអក្ខរាវិរុទ្ធពិតជាមានការខ្វះខាតពុំសមរម្យខ្លះមិនខានប៉ុន្តែបើសុខចិត្តនៅស្ងៀមមិនព្រមធ្វើនោះ កម្មវត្ថុនេះមិនអាចកើតឡើងដោយឯកឯងបានឡើយ ។ ដូចនេះទូលព្រះបង្គំខ្ញុំបាទសូមសំណូមពរ ព្រះអង្គម្ចាស់ សម្ដេចលោកឯកឧត្តម លោកជំទាវ អស់លោកលោកស្រី អ្នកនាងកញ្ញាសូមទឹកព្រះទ័យនិងទឹកចិត្ត មេត្តាសន្ដោសប្រោសប្រណីជួយបំភ្លឺបន្ថែមកែលំអរដើម្បីឱ្យការស្វែងយល់ជុំវិញសិល្បៈផ្នែកតន្ត្រីខ្មែរនេះមានពន្លឺភ្លឺថែងចាំងចំពោះចក្ខុនិងវិចារណញាណនៃកុលបុត្រកុលធិតាខ្មែរប្រកបដោយអត្ថន័យខ្ពង់ខ្ពស់ទូវវិស័យនេះទៅអនាគត ។

សូមអរព្រះគុណ និង អរគុណ

-មួយអន្លើ :

ក្នុងនាមសិស្សានុសិស្សជាអ្នកបន្តវេនសូមឧិនកាយវាចាចិត្ត ធ្វើការកិច្ចសំដែងក្ដីកតញ្ញូតាធមិ៍ដ៏ស្មោះបំផុតចំពោះវិញ្ញាណខន្ធ័លោកគ្រូអ្នកគ្រូភ្លេង លោកគ្រូអ្នកគ្រូល្ខោនទាំងអស់ ដែលបានដឹកដៃបំភ្លឺផ្លូវបង្ហាត់បង្ហាញឱ្យចំណេះដឹងដល់សិស្សគណទាំងប៉ុន្មានសូមលោកទទួលអបអរសាទរនូវអត្ថសារណាសម្បទានបទ ជាតំណាងស្នាដៃរបស់អស់ លោកបុព្វការីជនទាំងអស់រួមជាមួយសិស្សានុសិស្ស ទុកជាកម្មវត្ថុមួយរួមចំណែកលើកស្ទួយនូវវប្បធម៌សិល្បៈដ៏ប្រណិតឬជាអច្ឆរិយវត្ថុរបស់ដូនតាយើងជាអមតៈរឿង ។

⁂



www.elibraryofcambodia.org

## ១-ប្រវត្តិសង្ខេបនៃចម្រៀងមីរ៉ែកតន្ត្រីខ្មែរ

ដើមឡើយព្រះរាជាណាចក្រកម្ពុជាមានឈ្មោះថាចក្រភពភ្នំ ដែលចិនហៅថាហ្វូណន ។ ប្រទេសនេះមានប្រជាជនស្លូតត្រង់សុភាពរាបសារស្រឡាញ់យុត្តិធម៌និងសច្ចធម៌ មាន ប្រពៃណី ទំនៀមទំលាប់ដ៏ល្អប្រពៃ តស៊ូឧស្សាហ៍ព្យាយាមធ្វើការងារ ជាអ្នកស្រឡាញ់សិល្បៈវប្បធម៌របស់ខ្លួនយ៉ាងប្តូរផ្តាច់ មានជំនឿជឿជាក់ទៅលើលទ្ធិព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនាមានសុធន្ទះ ចង់រួមរស់នៅដោយសុខសន្តិភាពជាមួយនឹងប្រជាជនជឿនលឿនលើសាកលលោកផង ។

ក្រៅពីជំនឿសាសនាដែលមានប្រភពមកពីក្លឹង្គ ខ្មែរមានជំនឿទៅលើបុព្វបុរសមេបាគ្រូបាធ្យាយ អារក្សអារ៉ក្សអ្នកតា វត្ថុស័ក្តិសិទ្ធិលាយឡំទៅដោយព្រលឹងនិយម ដែលមានកំណើតតាំងពីយូរលង់មកហើយនិងមានទាក់ទងនឹងអភូតិហេតុពីប្រភពហេតុនិងផល ជាហេតុនាំឱ្យខ្មែរជឿចំពោះបុណ្យនិងបាប ពោលគឺមានសីលធម៌ខ្ពង់ខ្ពស់ឧត្តុងឧត្តម ។ ទន្ទឹមនឹងជំនឿលើអភូតិហេតុនេះ បុព្វបុរសខ្មែរក៏បានបង្កើតភាសារបស់ខ្លួនមួយផ្ទាល់ ដែលស្ថិតក្នុងអំបូរភាសាមន-ខ្មែរ សំរាប់ប្រាស្រ័យទាក់ទងគ្នាក្នុងសង្គមជាតិ ។

ពីបុរមបុរាណមកគេឃើញមានតាមរយៈជំនឿទៅលើអភូតិហេតុជាក់ស្តែងខ្លះ ជាហេតុនាំឱ្យកើតជាភាសាមួយហៅថាសំនៀងភាសា។ ភាសានេះ មានតួនាទីជាវិធីសាស្ត្រសំរាប់ដាស់ស្មារតីសទ្ធារម្មណ៍ហទ័យៈបេះដូងមួយស្ថិតក្នុងលក្ខណៈបំពីរលួងលោម បរពោធ អង្វែលនូវមនោសញ្ចេតនារម្មណ៍របស់មនុស្សខ្លះៗ. នៅពេលប៉ះទង្គិចនឹងសុភាវៈបរិយាកាសតប់ប្រមល់ហឹង្សា កាចឬស្លូត ក្តៅឬត្រជាក់ ខ្លាំងឬខ្សោយ តឹងឬធូរ ។ ភាសានេះមានលក្ខណៈបង្ហាញពន្យល់និងអង្វរករបញ្ចុះលបិត្តធ្វើឱ្យស្ងប់មួយរយៈនិងទាញនូវអារម្មណ៍ទាំងនោះឱ្យទោរទន់ចូលចិត្ត យល់ព្រមអនុលោមក្នុងលក្ខណៈសុភវិធិជ្ជ័យ



www.elibraryofcambodia.org

ទៅតាមសំនៀងភាសានោះផង។ ឯភាសានេះ មិនមែនមានឥទ្ធិពលសំរាប់លួងលោមតែមនុស្សលោកប៉ុណ្ណោះទេ គឺមានសិលវិធីដ៏សំខាន់សំរាប់បំពីរលួងលោមអង្វរករនូវព្រលឹងវិញ្ញាណខ័ន្ធរបស់បុព្វបុរសដូនតា ទេវតា ខ្មោចអារក្ខអ្នកតា ទៀតផង ។

ដូចនេះហើយបានជាដូនតាខ្មែរយើងជំនាន់នោះមានទេពកោសល្យខ្ពស់ បានរៀបចំរចនាកែច្នៃបង្កើតនូវទម្រង់ភ្លេងខ្មែរនេះឡើងដើម្បីសំរាប់បំពីនូវបុណ្យហេតុដែលមានការចាំបាច់ពាក់ពន្ធ័ខ្សាវរ៉ាងពិធីនានានិងវត្ថុបំណងជាសារវន្ត័ ។ ដោយផ្នែកប្រទេសកម្ពុជាយើងបានទទួលឥទ្ធិពលវប្បធម៌មួយចំនួនពីក្ញដ្ឋ ។

ប្រជាជនឥណ្ឌាមានជំនឿទៅលើទេវតា ព្រះវិស្ណុ ព្រះឥសូរ ព្រះនារាយណ៍ ព្រះអាទិត្យព្រះចន្ទ័នាងគង្គឹងព្រះធរណីនិងទៅលើធម្មជាតិផង ដែលជាការស្វែងយល់នៃផ្លូវមនោរម្មណ៍ មនោគតិ ភាពជឿជាក់ដើម្បីសុភមង្គលក្នុងមាគ៌ាជីវិតរបស់គេ ។ ហើយដើម្បីសំរេចនូវគោលដៅដ៏ថ្លៃថ្លានេះ គេត្រូវតែថ្វាយតូរ្យតន្ត្រីទៅចំពោះអច្ឆរិយបុគ្គលទាំងអស់នោះ ដែលជាម្ចាស់នៃវាសនារបស់មនុស្សលោក ។ ទង្វើនេះ ក៏មានលក្ខណៈប្រហាក់ប្រហែលនឹងការបួជាភ្លេងភ្ជាត់ចំពោះអារក្សអ្នកតាចាស់ស្រុករបស់ជនជាតិខ្មែរយើងដែរ។-តាមពិតប្រជាពលរដ្ឋខ្មែរយើងរមែងតែនិយមភ្លេងជាផង្វាយ ដើម្បីថ្វាយមិនចំពោះតែទេវតានៃព្រហ្មញ្ញសាសនាតែប៉ុណ្ណោះទេក៏ប៉ុន្តែចំពោះគ្រប់វត្ថុស័ក្តសិទ្ធនៃលោកយើងនេះដើម្បីសេចក្តីសុខសេចក្តីចំរើនរបស់ខ្លួន ។

គប្បីរំលឹកនៅត្រង់នេះ អ្នកប្រាជ្ញខាងសង្គមវិទ្យាអាចចាត់ទុកថាសំនៀងភាសាជាផ្នែកមួយនៃតូរ្យតន្ត្រីដែរ ពីព្រោះវាមិនគ្រាន់តែជាមធ្យោបាយសំរាប់ទាក់ទងគ្នាតែប៉ុណ្ណោះទេក៏ប៉ុន្តែវាជាវេទមន្តសំរាប់បំពេរអារម្មណ៍ធ្វើឱ្យស្រទន់ចិត្តបង្កើតនូវមនោសញ្ចេតនាសេចក្តីរំភើបញាប់ញ័រយ៉ាងក្រៃលែងថែមទៀតផង ។ បើនិយាយសរុបទៅតូរ្យតន្ត្រីជាភាសាដ៏



www.elibraryofcambodia.org

ពិសិទ្ធមួយនៃអារ្យធម៌វប្បធម៌ ដែលមានលក្ខណៈសកល ។ ទស្សនៈខាងលើនេះសឱ្យឃើញថាគ្រប់សញ្ជាតិគ្រប់ប្រទេស គ្រប់សង្គមមនុស្សទាំងអស់ទោះធំក្តីតូចក្តី សុទ្ធសឹងតែមានតូរ្យតន្ត្រីប្រចាំជាតិរបស់ខ្លួន ហើយម្យ៉ាងទៀតរីឯព្រះរាជាណាចក្រកម្ពុជាក៏ដូច្នេះដែរ ។

លក្ខណៈមួយទៀតនៃតូរ្យតន្ត្រីខ្មែរដែលយើងត្រូវផ្តោតអារម្មណ៍ទៅលើ គឺភាពចំណាស់របស់សិល្បៈនេះដែលដូចយើងបានពោលខាងលើជាមរតកវប្បធម៌ជាតិ ។ នៅត្រង់នេះយើង ចង់រំលឹកឡើងវិញថាកិត្តនាមឬកេរ្តិ៍ឈ្មោះដ៏ល្បីល្បាញរបស់តូរ្យតន្ត្រីខ្មែរមិនមែនកើតមានឡើង ឬមានឈ្មោះពីរោះសម្លេងគ្រាន់តែនៅសម័យអង្គរ និងសម័យអង្គរតែប៉ុណ្ណោះទេ ដូចជាខ្លឹមសារនៃសិលាចារឹកនិងចម្លាក់នៅតាមប្រាសាទបុរាណជាភស្តុតាងស្រាប់ ក៏ប៉ុន្តែវិស័យសិល្បៈនេះ ដែលបានប្រសូតតាំងតែសម័យបុរេប្រវត្តិសាស្ត្រម្ល៉េះ ហើយបានបំពេញនាទីយ៉ាងសំខាន់បំផុតក្នុងសង្គមខ្មែរ ។ សូមជម្រាបថា តាំងពីកើតរហូតដល់ស្លាប់ វត្តមានរបស់តូរ្យតន្ត្រីត្រូវគេជួបប្រទះនៅគ្រប់ពិធីការទាំងអស់ ។

មួយវិញទៀតកំណាយតាមស្ថានីយបុរេប្រវត្តិសាស្ត្រជាច្រើនក៏បានបញ្ជាក់ឱ្យយើងឃើញនូវភាពចំណាស់នៃឧបករណ៍មួយចំនួនដែរដូចជាស្គរមហោធឹកធ្វើអំពីសំរឹទ្ធ ដែលគេប្រើសំរាប់សូមទឹកភ្លៀង, ផ្លែនាគចូនិងរូបចំលាក់តំណាងមនុស្សផ្លុំកែននិងលេងគង ។ និរន្តភាពរបស់ប្រពៃណីខាងលើនេះ បានត្រូវគេកត់សំគាល់តាមរយៈឧបករណ៍ភ្លេងមួយចំនួនដែលខ្មែរយើងនិងកុលសម្ព័ន្ធខ្មែរលើនៅប្រើប្រាស់រហូតដល់សព្វថ្ងៃនេះ។ គប្បីខ្មែរយើងគ្រប់មជ្ឈដ្ឋានឱ្យបានគង់វង្សនូវមរតកវប្បធម៌ខាងលើនេះ នេះជាសំណូមពរដ៏ស្មោះស្ម័គ្ររបស់ទូលបង្គំខ្ញុំ បាទដែលជាសិល្បករមួយរូបដែលបានបូជាជីវិតសម្រាប់បុព្វហេតុខាងលើនេះ ។

តាមរយៈវប្បធម៌របស់ឥណ្ឌាទាំងប៉ុន្មានដែលបានជះឥទ្ធិពលនៅក្នុងសង្គមខ្មែរ តាំងពីមុនមកបានជិតដាមចូលក្នុងមនោសញ្ចេតនារម្មណ៍របស់ខ្មែរផងដែរ ។ មិនតែប៉ុណ្ណោះឥទ្ធិ



www.elibraryofcambodia.org

ពលនេះបានសម្របសម្រួលជាមួយលក្ខណៈខ្មែរ ហើយបានប្រតិស្ឋានយ៉ាងប្រត្យក្សនិងប្រកបដោយភាពជាអាជ្ញាក្នុងស្រទាប់មនុស្សខ្មែរ។ អ្នកប្រាជ្ញខ្មែរបានសន្និដ្ឋានយ៉ាងត្រឹមត្រូវថាវប្បធម៌ខ្មែរជាវប្បធម៌សំយោគរវាងវប្បធម៌មន-ខ្មែរ ដែលមានកំណើតមករាប់ពាន់ម៉ឺនឆ្នាំនៅលើឧបទ្វីបឥណ្ឌូចិននេះ និងរួមជាមួយវប្បធម៌ក្លឹង្គដែលខ្មែរបានទទួលតាំងពីសតវត្សទី១នៃគ្រិស្តសករាជផងនោះ។ វប្បធម៌ទាំងពីរនេះបានស្ថិតនៅក្នុងរូបមេត្តនៃមនោសញ្ចេតនាតែមួយធ្វើឱ្យខ្មែរមានវឌ្ឍនៈធម៌ និងអរិយធម៌រុងរឿងល្អប្រពៃតាំងពីបរម្បុរាណកាលមកទល់បច្ចុប្បន្នកាលនេះដូចជាវប្បធម៌នគរភ្នំនិងចេនឡាជាសក្ខីភាពស្រាប់ ។



www.elibraryofcambodia.org

## ២-ចរិកខ្មែរ

ជនជាតិខ្មែរជាជនជាតិចាស់មួយដែលបានកើតនៅភូមិភាគឥណ្ឌូចិននេះ ហើយជនជាតិនេះបានបន្សល់ទុកនូវកេរ្តិ៍វប្បធម៌គ្រប់វិស័យ។ ម្យ៉ាងទៀតខ្មែរមុននឹងប្រារព្ធធ្វើពិធីឬការបង្កើតស្នាដៃអ្វីមួយ ខ្មែរយើងតែងតែគិតគូរឲ្យពិចារណាវិភាគនឹកឃើញទៅផលវិភាពរបស់បុព្វការីជននិងពីទំនៀមទំលាប់ប្រពៃណីរបស់ជាតិជាមុន។ រាល់វិស័យកសាងជាតិក៏ដូចជាវិស័យវប្បធម៌ជំនាញឯកទេសនិមួយៗអ្នកកវីនិពន្ធបញ្ញវន្តខ្មែរពីជំនាន់ដើមបានពិនិត្យពិចារណាវិភាគនូវចរិកពិតនៃលក្ខណៈពិសេសនិងជម្រៅចិត្តរបស់ខ្មែរ ។ គេបានធ្វើការប្រៀបធៀបពីមនុស្សទៅនឹងពពួកសត្វ ពីមនុស្សទៅនឹងសង្គម ពីមនុស្សទៅនឹងធម្មជាតិ ពីទស្សនៈទៅនឹងវិទ្យាសាស្ត្រសង្គម ។ល។ ខ្មែរមានឧត្តមគតិខ្ពស់ និងសិលវិធីក្នុងការស្រាវជ្រាវចងក្រងរៀបរយនូវមុខជំនាញនិមួយៗដូចជា : ជំនាញសិល្បៈតន្ត្រី បំរៀងល្ខោននាដ្ឋសាស្ត្រគំនូរចំលាក់ជាដើម ដែលមានការទាក់ទងគ្នាពីសភាវៈមួយទៅសភាវៈមួយនិងបានផ្សារភ្ជាប់នូវមនោសញ្ចេតនារម្មណ៍ជាព្រលឹងរស់ឱ្យស្ថិតនៅក្នុងមនោគតិនៃមនុស្សទូទៅ អាស្រ័យតាមហេតុការណ៍ ឬទៅតាមកាលសម័យផង ។ ជាមួយគ្នានេះ ថែមទាំងបានចារឹកទុកជាក្បួនខ្នាតជាគ្រឹះនិងជាគោល សំរាប់ជាមូលដ្ឋាននៃវប្បធម៌យូរអង្វែងទៅអនាគតផង។ ឧទាហរណ៍ជាក់ស្តែងដូចជាមានរូបចំលាក់ចារឹកនៅតាមផែនទានានៃប្រាសាទបូរាណ ជាសក្ខីភាពសំរាប់កូនចៅជំនាន់ក្រោយៗរៀនសូត្រតាម ។



www.elibraryofcambodia.org

## ៣. អំពីតន្ត្រីបុរាណខ្មែរ

ប្រទេសកម្ពុជាជាប្រទេសមួយដែលមានលក្ខណៈភូមិសាស្ត្រធនធានធម្មជាតិ អំណោយផលគ្រប់បែបយ៉ាង។ ផ្នែកសង្គមកិច្ចនិងវប្បធម៌ អាចផ្តល់នូវសុភមង្គលដល់ប្រជាពលរដ្ឋគ្រប់យ៉ាងសុខសាន្ត ដោយផ្នែកសិល្បៈនាដ្យសាស្ត្រ ចំរៀងតន្ត្រីក៏ជានិស្សន្ទ័ពិសិដ្ឋ អាចផ្តល់នូវថាមពលដល់អត្តសញ្ញាណជាតិ ដែលមានលក្ខណៈទាក់ទិនផ្សារភ្ជាប់ជាមួយនឹងដំណើរជីវិតរបស់ប្រជាជនខ្មែរជានិច្ចនិរន្តរ៍ ។

ជាបឋមនេះសូមលើកយកវិស័យសិល្បៈផ្នែកតន្ត្រីបូរាណខ្មែរមកជូនពិចារណានូវចំណុចខ្លះៗដូចតទៅ :

<u>ចំណុច</u> : ក- អំពី និយមន័យនៃតន្ត្រី

- ខ- តន្ត្រីនិងដំណើរជីវិតនៃប្រជាជនខ្មែរ
- គ- ជំពូកឧបករណ៍តន្ត្រីបូរាណខ្មែរ
- ឃ- អំពីវង់តន្ត្រីបូរាណខ្មែរ

**<u>ចំណុច</u> ក. អំពីនិយមន័យនៃតន្ត្រី**

*<u>និយមន័យនៃតន្ត្រី :</u>* ពាក្យដែលហៅថាតន្ត្រី ឬ ភ្លេង

តន្ត្រីគឺជាស្នូរសំនៀងនៃមនោសញ្ចេតនារម្មណ៍ ជានិមិត្តរូបនៃព្រលឹងរស់មានភាពអាថ៌កំបាំងទីតាំងរបស់វាស្ថិតនៅក្នុងភពជាអរូបិយ៍ឬជាអរូបធម៌ធម្មជាតិឮសំឡេង ប៉ុន្តែគ្មានឃើញរូបនិងធ្វើឱ្យទាក់ទាញអារម្មណ៍របស់មនុស្សទៅលើមនោសញ្ចេតនាដ៏ត្រកាលនោះ។ លក្ខណៈកំណត់សំគាល់របស់បទភ្លេងនិមួយៗ ទឹកដមនៃបទអាចកំណត់បាននូវសច្ចៈភាពសោភ័ណភាព ចរិយាធម៌និងគុណធម៌តាមរយៈល្បះឃ្លានិមួយៗ ។ យើងអាចដឹងបានថា បទភ្លេងនេះមានភាពតស៊ូឬភាពអស់សង្ឃឹម ភាពស្លូតបូតឬកាច ភាពកើតទុក្ខ



www.elibraryofcambodia.org

ឬភាពសប្បាយរីករាយសរុបមកគឺជាមនោសញ្ចេតនារម្មណ៍ទាំងអស់ ។មនោសញ្ចេតនារម្មណ៍នេះធ្វើឱ្យមនុស្សទទួលបានឆ្លងតាមសោតិន្ទ្រីយារម្មណ៍ ជាបន្តនាំមកប៉ះនឹងអាយតនៈទាំង៦ ទើបបាតុភូតិធ្វើឱ្យមនោគតិកំណត់បានទូវសំនៀងនិងនាំឱ្យកើប សប្បាយ ឬព្រួយទៅតាមភាពសច្ចៈនោះ។ មិនតែប៉ុណ្ណោះតន្ត្រីមានការទាក់ទិន ផ្សារភ្ជាប់ទៅនឹងដំណើរជីវិតរបស់ប្រជាជនកម្ពុជា ចាប់តាំងពីថ្ងៃកើតរហូតដល់ថ្ងៃស្លាប់ទៅវិញផង ។

**<u>ចំណុច</u> ៩. តន្ត្រីនិងដំណើរជីវិតនៃប្រជាជនខ្មែរ**

នៅក្នុងដំណើរជីវិតនៃប្រជាជនកម្ពុជា គឺចាប់ពីថ្ងៃកើតរហូតដល់ថ្ងៃស្លាប់តន្ត្រីខ្មែរបានផ្សារភ្ជាប់យ៉ាងស្អិតរមួតនិងដំណើរជីវិតខ្មែរគ្រប់រូប។លក្ខណៈផ្សារភ្ជាប់ទាំងនោះមានដូចតទៅ :

លក្ខណៈផ្សារភ្ជាប់ទី១ គឺ :

*<u>ពិធីបង្កក់កូន</u>* :

នៅពេលប្រសូត្រចេញពីឧទរម្តាយបានបីថ្ងៃ ឪពុកម្តាយត្រូវធ្វើពិធីបង្កក់កូន ។ តាំងពីបូរាណកាល ពិធីបង្កក់កូននេះ គេត្រូវរៀបចំសែនព្រេននៅចំពោះគ្រូបាធ្យាយ ជីដូនជីតានិងមានធ្វើកិច្ចសូមខមាលទោសចំពោះយាយម៉បសូមឱ្យបានប្រកបដោយសុភមង្គលវិបុលសុខគ្រប់ប្រការផង ។ ឯពិធីត្រូវធ្វើមានដូចតទៅ :

ក- ត្រូវរៀបព្រះពិស្ណុការ មានបេកទុំមួយស្អិត នំចំណី បង្អែមចង្ហាប មានស្រាមួយកំប៉ុកសំរាប់សែនព្រេនថ្វាយគ្រូបាធ្យាយជីដូនជីតានិងប្រដាប់ប្រដារស្រូវពន្លៃមួយកន្លាំងផង ។

ខ-ក្នុងពេលសែនព្រេន ត្រូវមានភ្លេងប្រគុំកំដរជូនដូនតា គ្រូបាធ្យាយ សេពសោយ។ លុះពេលសេពសោយរួចហើយទើបលើកប្រដាប់ប្រដារទាំងនោះ ជូនទៅយាយម៉បតែម្តង ។



www.elibraryofcambodia.org

លក្ខណៈផ្សារភ្ជាប់ទី ២ គឺ :

*ពិធីកោរជុក*

ចំណែកកូនប្រុស នៅពេលដែលបានចំរើនវ័យវឡូទាការ អាយុជាងដប់ឆ្នាំឡើងទៅ ឪពុកម្ដាយត្រូវរៀបចំពិធីកោរជុក។ ពិធីកោរជុកនេះមានរៀបចំជាពលិការស្លាធម៌ធម្មតាមួយគូ ស្លាធម៌ជួងមួយគូ បាយសីចាំឆាមមួយគូ ទៀនប្រាំធូបប្រាំ ទំចំណី បង្អែមចង្ហាបអំបោះថ្នក កាំបិតកោរមួយនិងទឹកមួយផ្តិល ។ នៅពេលឪពុកម្ដាយបងប្អូនញាតិមិត្តមកជួបជុំគ្នាអស់ហើយពេលនោះ លោកអាចារ្យធ្វើការប្រកាសឧទ្ទិសបួងសួងចំពោះគ្រូបាធ្យាយ ទេវតាបារមី ព្រះរតនត្រ័សូមជួយកំចាត់គ្រោះចង្រៃផ្សេងៗនិងសូមបារមីប្រសិទ្ធីតេជះប្រស់ព្រំឱ្យកូនចៅបានសុខសប្បាយតរៀងទៅ ។

លក្ខណៈផ្សារភ្ជាប់ទី ៣ គឺ :

*ពិធីចូលម្លប់*

ឯកូនស្រីវិញនៅពេលអាយុគ្រប់ការ ឪពុកម្ដាយត្រូវរៀបចំពិធីចូលម្លប់ ។ ពិធីនេះមានកំណត់រយៈពេលបីខែទើបចេញពីម្លប់បាន ។ ពិធីចូលនិងចេញពីម្លប់នេះក៏ត្រូវមានភ្លេងប្រពៃណីប្រគុំកំដរដើម្បីបំពេញនូវសិរីសួស្ដីជ័យលាភិនារីមានលក្ខណ៍ព្រហ្មចារីយ៍នៃស្រីក្រមុំ ព្រោះនាងបានបំពេញនូវតួនាទីរបស់ខ្លួនតាមជំនួទាងប្រពៃណីជាតិនិងជាអនាគតនៃមេផ្ទះដ៏ប្រពៃផង ។

លក្ខណៈផ្សារភ្ជាប់ទី ៤ គឺ :

*ពិធីបំបួសនាគ*

លក្ខណៈទី៤នេះ មានសារៈសំខាន់បំផុតសំរាប់កុលបុត្រជាយុវជនក្នុងការស្វែងរកនូវវិជ្ជាសម្បត្តិឧត្តមគតិជាប្រភពនៃការអប់រំផ្លូវកាយវាចាចិត្ត ឱ្យដើរផ្លូវល្អឆ្ពោះទៅរកពន្លឺនិងភាពរីកចំរើនសំរាប់ប្រវត្តិជីវិតនៃមនុស្សម្នាក់ៗនៅពេលបំពេញបព្វជ្ជាជាភិក្ខុឬសាមណេរ



www.elibraryofcambodia.org

តាមប្រពៃណីព្រះពុទ្ធសាសនា។ ជាដំបូងត្រូវកោរសក់ស្លៀកពាក់ស ពានាសផ្លាស់នាមកំណើតចេញ យកនាមថ្មីវិញសន្មត់ហៅថានាគគឺបុគ្គលដ៏ប្រសើរ។ នៅពេលដង្ហែនាគទៅកាន់ទីវត្តអារាមគឺត្រូវមានភ្លេងដង្ហែរអបអរសាទរជូនដំណើរនាគ ជាពិធីមួយយ៉ាងអឹកធឹករុងរឿង ។

លក្ខណៈផ្សារភ្ជាប់ទី ៥ គឺ :

*ពិធីរៀបអាពាហ៍ពិពាហ៍ ឬ រៀបមង្គលការ*

នៅពេលរៀបចំគូស្រករឬស្វាមីភរិយាគឺពិធីរៀបអាពាហ៍ពិពាហ៍ឬរៀបមង្គលការ ពេលនោះហើយជាពិធីធំជាមង្គលដ៏ឧត្តមសំរាប់ប្រវត្តិសាស្រ្តជីវិតនៃយុវជនយុវតីគ្រប់រូបដែលត្រូវបំពេញកាតព្វកិច្ចឬកតញ្ញូធម៌ចំពោះមាតាបិតានិងគោរពទៅតាមប្រពៃណីជាតិ ។ ដូច្នេះក្នុងពិធីមង្គលការនេះ គឺត្រូវមានភ្លេងមួយវង់សំរាប់ប្រគុំកំដរក្នុងពិធីជាចាំបាច់ ។

លក្ខណៈផ្សារភ្ជាប់ទី ៦ គឺ :

*ពិធីជុំញាតិ*

នៅពេលមានមនុស្សក្នុងគ្រួសារណាមួយមានជម្ងឺឈឺធ្ងន់ឈឺរាប់ខែឆ្នាំឈឺរ៉ាំរ៉ៃ ដាក់ថ្នាំមិនត្រូវអស់សង្ឃឹម តាមជំនឿមនុស្សដើម្ ខ្មែរដើមគេតែងតែធ្វើពិធីជុំញាតិសំបូងសង្រ្គងលាមាត់លាពាក្យ ។ ពិធីនេះ គេត្រូវអញ្ជើញចាស់ទុំបងប្អូនបង្កើតបងប្អូនជីដូនមួយមកជួបជុំគ្នានៅផ្ទះអ្នកជំងឺ ។
ជាតំបូងចាស់ទុំផ្តើមធ្វើពិធីប្រកាសចំពោះគ្រូបាធ្យាយ ជីដូនជីតាជួរខាងឪពុកនិងម្តាយព្រមទាំងខ្មោចអារក្សអ្នកតាចាស់ស្រុក ទេព្តារក្សាព្រៃព្រឹក្សាភូមិករទាំងប៉ុន្មានមកស្ថិតក្នុងទីនេះធ្វើជាសាក្សីបើកូនចៅណាបានធ្វើខុសឆ្គងប្រពៃណីឬមានឈ្លោះប្រកែក ទាស់ទែងតមមាត់តម-កនឹងគ្នាសូមអ្នកទាំងពីរនោះរាប់អាននិយាយស្តីរកគ្នាវិញឈប់ប្រកែប្រកាន់គ្នាចាប់ពីពេលនេះតទៅ គ្រូបាធ្យាយនិងជីដូនជីតាទាំងអស់លែងខឹងសំបានឹងកូនចៅ



www.elibraryofcambodia.org

ទៀតហើយព្រោះកូនចៅ បានរៀបចំគ្រឿងសក្ការៈបូជាជូនថ្វាយសព្វគ្រប់នៅចំពោះមុខនេះស្រាប់ ។ នៅពេលនោះអ្នកដែលមានអាយុតិចជាងចាប់យកផ្កាមួយទងជូនទៅអ្នកដែលមានអាយុច្រើនជាង ។ អ្នកទាំងពីរជូនផ្កាគ្នាទៅវិញទៅមក យកផ្កាដោយទឹកមុខញញឹមញញែមរកគ្នានៅចំពោះមុខអ្នកជំងឺ ពេលនោះអ្នកកាន់ផ្កា និងភ្ញៀវទាំងអស់បានទះដៃព្រមគ្នាជានិមិត្តរូបអបអរសាទរស្រុះស្រួលគ្នាក្នុងបរិយាកាសសប្បាយរីករាយ ។ ពេលនោះក្រុមភ្លេងប្រពៃណីក៏បានប្រគំឡើងភ្លាមមាន ៤បទ :

ទី១- បទហោមរោង : ថ្វាយគ្រូបាធ្យាយ ព្រះពិស្ណុការ

ទី២- បទអង្គរាជបែកចាន : ក្នុងន័យរក្សាសាមគ្គីគ្រួសារឡើងវិញ

ទី៣- បទកងសោយ : កំដរគ្រូបាធ្យាយ ពីជូនពីកាសោពសោយ

ទី៤- បទអុំទូក : ជាកិច្ចជូនដំណើរជូនតា គ្រូបាធ្យាយត្រឡប់ទៅវិញ

ចំពោះអ្នកជំងឺកាលបើបានឃើញទិដ្ឋភាពនឹងបរិយាកាសនៃគ្រួសារមានការរីករាយដូច្នេះព្រមទាំងស្តាប់ភ្លេងដ៏ពិរោះគួរឱ្យជាប់ចិត្តផងនោះ ក៏រំភើបក្នុងខ្លួនយ៉ាងខ្លាំងហាក់ដូចជាបានទទួលទឹកមន្ត ធ្វើឱ្យជំងឺក្នុងខ្លួនបានធូរសះស្បើយមួយចំនួនធំ ។

<u>តាមការសង្កេត</u> :តន្ត្រីគឺជាចិត្តសាស្ត្រឬជាឱសថម៉្យាង ដែលមានប្រសិទ្ធិភាពធ្វើឱ្យមនោសញ្ចេតនារម្មណ៍នៃអ្នកជម្ងឺបានសប្បាយរីករាយជម្ងឺក្នុងខ្លួន និងបានស្រាកស្រាន្តមួយចំណែកធំដែរ ។

លក្ខណៈផ្សារភ្ជាប់ទី៧ គឺ :

*<u>ពិធីកំដរសព</u>*

នៅពេលមនុស្សទទួលមរណភាពជាទូទៅគឺជាការបញ្ចប់ពីដំណើរអវសាន្តនៃជីវិត និងជាកិច្ចលើកតំកើងនៃវិញ្ញាណខន្ធរបស់បុគ្គលម្នាក់ៗក្នុងគ្រាចុងបញ្ចប់ ត្រូវមានពិធីកំដរសព ។ ក្នុងពិធីនេះត្រូវមានព្រះសង្ឃឬលោកអាចារ្យសូត្រធម៌ព្រះអភិធម្មព្រះត្រៃយលក្ខ័ ដោយឡែកត្រូវមានវង់ភ្លេងគងស្គរទាំម្ងួងឬវង់ភ្លេងពិណពាទ្យ សំរាប់ប្រគុំកំដរជាប្រចាំ



www.elibraryofcambodia.org

រហូតដល់ពេលដង្ហែរសពទៅបញ្ចុះឬបូជាទើបឈប់គំនរ ។
សូមបញ្ជាក់ថាតន្ត្រីនិងដំណើរជីវិតនៃប្រជាជនកម្ពុជា មានលក្ខណៈទាក់ទិនផ្សារភ្ជាប់គ្នារៀងរាប់ចាប់តាំងពីថ្ងៃកើតរហូតដល់ថ្ងៃស្លាប់ទៅវិញប្រាកដមែន មិនអាចជៀសវាងឬផ្តាច់ពីគ្នាបានឡើយ ។ ក្រៅពីនេះ តន្ត្រីមាននាទីចូលរួមរាល់សកម្មភាពនៃពិធីដ៏ច្រើនទៀតផងដូចជា : ពិធីបុណ្យប្រពៃណីជាតិមានពិធីបុណ្យទ្វាទសមាសជាដើម ។

<u>ចំណុច</u> គ_ជំពូកឧបករណ៍តន្ត្រីបុរាណខ្មែរ
សូមបង្ហាញជូននូវរូបភាពឧបករណ៍តន្ត្រីខ្មែរដូចតទៅនេះ ៖ ឧបករណ៍តន្ត្រីខ្មែរមានច្រើនប្រភេទ ហើយចែកចេញជា៤ជំពូកដូចតន្ត្រីប្រទេសដទៃដែរ ។

<u>រូបភាពឧបករណ៍ក្តួតឬកេះ</u>



តះខេ

<u>*ជំពូក ១*</u> : ឧបករណ៍ក្តួតឬកេះ អន្តរជាតិហៅថា Cordophone : គឺឧបករណ៍ខ្សែដូចជា : ទ្រខ្មែរ ទ្រសោ ទ្រអ៊ូ ទ្រឆេ ខ្សែដៀវ ចាប៉ីវែងនិងតះខេ ។ល។ ឧបករណ៍ទាំងនេះនៅពេលប្រគំគឺក្តួតឬកេះនឹងដៃ ហើយមានសំនៀងស្រាលមធ្យម ឧបករណ៍ខ្លះសំនៀងវែងស្រទន់ សុភាព ស្តួតបួតផង ។



www.elibraryofcambodia.org



ទ្រឈេ



ចាប៉ីដងវែង



ខ្សែដៀវ



www.elibraryofcambodia.org






www.elibraryofcambodia.org

*ជំពូកទី ២* : ឧបករណ៍វាយប្ដូរ អន្តរជាតិហៅថា Membranophone : គឺជាឧបករណ៍ស្គរ ។ ស្គរនេះមានច្រើនយ៉ាងណាស់ដែរ ដូចជាស្គរពិណពាទ្យ ស្គរដៃយាំ ស្គរឆៃយ៉ាំ ស្គរយីកេ ស្គរយោល សំភោរ ស្គរធនរមនា និងស្គរដៃប្អូការ ។ល ។

ស្គរពិណពាទ្យគេពាសអំពីស្បែកក្របី ។ ចំណែកស្គរដៃយាំ ស្គរយីកេ ស្គរយោល

<u>រូបភាពឧបករណ៍វាយប្ដូរ</u>



ស្គរឆៃយ៉ាំ

និងសំភោរពាសអំពីស្បែកគោ។ ឯស្គរដៃ និងស្គររធនរមនា គេពាស អំពីស្បែកពស់ប្រមោយឬពស់ថ្លាន់។ ឧបករណ៍ទាំងនេះ គេវាយនិងអន្ទង់ប្ដូរនឹងដៃ ហើយសំនៀងពូស្គរខ្លាំងឬមធ្យមខុសគ្នាដោយឡែក ។ រីឯស្គរពិណពាទ្យពូស្គរខ្លាំងជាងគេ ។



www.elibraryofcambodia.org



ស្គរធំ



ស្គររមនា



ស្គរយោល



www.elibraryofcambodia.org



ស្គរដៃ ឬ ស្គរការ



ស្គរយីកេ



www.elibraryofcambodia.org



សំភោរ



ស្គរធំ



www.elibraryofcambodia.org

*ជំពូក៣* : ឧបករណ៍ភ្លេងផ្លុំដោយខ្យល់ អន្តរជាតិហៅថា Aerophone : ដូចជាឧបករណ៍ : ប៉ីបបុស ប៉ីអ ប៉ីពក ស្រឡៃ ខ្លុយ ស្នែង តែន និងភ្លយ ។ល។ ឯឧបករណ៍ប៉ីបបុស ប៉ីអ និង ប៉ីពក តួវា ធ្វើអំពីឈើខ្លឹម ស្នូលធ្វើអំពីឈើ ។

<u>រូបភាពឧបករណ៍ផ្លុំ</u>



ប៉ីធាក



ស្នែង

ឯឧបករណ៍ស្នែងតួវាធ្វើអំពីស្នែងក្របី អណ្តាតធ្វើអំពីដើមបបុសឬសទ្ធីកស្អាន់ស្អិត ។ ឯតែនតួវាធ្វើអំពីដើមបបុស អណ្តាតធ្វើអំពីស្អាន់ស្អិត។ ឧបករណ៍ទាំងអស់នេះ ពេលប្រគំគេផ្លុំផ្ទាល់នឹងមាត់ឮសំនៀងខ្លាំងគ្រលួច ។



www.elibraryofcambodia.org



ខ្លុយ



ភ្លយ



ប៉ិបបុស



www.elibraryofcambodia.org



ស្រខៀ



គែន



www.elibraryofcambodia.org

*ជំពូកទី ៤* : ឧបករណ៍គោះដៃ-ដំ អន្តរជាតិហៅថា Idiophone : គឺឧបករណ៍ជំពូកនេះមានរូបភាពជាឧបករណ៍ផ្លែ ខ្លះទៀតដូចជាបន្ទះរនាបផង។ ដូចជា រនាតឯក រនាតធុង រនាតដែក រនាតថោងធុង គងវង់ធំ គងវង់តូច គងដោះធំ ឆ្លុង ឈឹង និងឃ្មោះ ។ល។ ផ្លែរនាតឯកធ្វើអំពីដើមឫស្សី ឫដើមគ្រញូង មានផ្លែ ២១ ។ រនាតដែកមានផ្លែធ្វើអំពីដែកឬលង្ហិន ផ្លែមាន២១។ រនាតធុង ផ្លែធ្វើអំពីឫស្សីឬដើមគ្រញូង មានចំនួន១៦ផ្លែ ។ ឯរនាតថោងធុង មានផ្លែធ្វើអំពីដែកឬលង្ហិន ផ្លែមានចំនួន១៦ផ្លែ ដូចរនាតធុងដែរ ។ ឯគងវង់ធំ និងគងវង់តូច មានផ្លែធ្វើអំពីលង្ហិន ។ ក្នុងគងវង់និមួយៗផ្លែមានចំនួន១៦ ។

ឧបករណ៍ទាំងអស់នេះ មានសំឡេងធម្មជាតិខ្លួនឯងស្រាប់មកហើយ ប៉ុន្តែមិនទាន់គ្រប់គ្រាន់ត្រឹមត្រូវនៅឡើយទាល់តែយើងយកមកកែច្នៃរៀបសំឡេងជុំគ្នា ពីខ្ពស់មកទាប ពីលើមកក្រោមឱ្យបានត្រឹមត្រូវតាមក្បួនជាកម្រងសំនៀងរៀបរយត្រឹមត្រូវ ទើបអាចចេញជាសំលេងភ្លេងប្រគំទៅបានពិរោះល្អ ។

ឯឧបករណ៍ទាំងអស់នេះ ពេលប្រគំគេគោះនឹងអន្លុង ឮស្នូរសំនៀងខ្លាំងហើយស្រួយ ឧបករណ៍ខ្លះឮសំនៀងខ្លាំងហើយរងំពិរោះរណ្ដំ ឧបករណ៍ខ្លះទៀតឮសំនៀងស្រួយស្វាហាប់ ខ្ទងរ៉ង ពិរោះគួរឱ្យចាប់អារម្មណ៍ណាស់ ។

<u>រូបភាពឧបករណ៍គោះ-ដំ</u>



www.elibraryofcambodia.org



ឃ្មោះ



គងឃោះធំ



www.elibraryofcambodia.org



ឈិង



រនាតឯក



www.elibraryofcambodia.org



រនាតដែក



រនាតថោង



រនាតធុង



www.elibraryofcambodia.org



គងវង់តូច



គងវង់ធំ



www.elibraryofcambodia.org

### ចំណុច ឃ_អំពីវង់តន្ត្រីបូរាណខ្មែរ

ឧបករណ៍តន្ត្រីបូរាណខ្មែរទាំង៤ជំពូកនោះ គេអាចយកទៅប្រើប្រាស់ដោយចែកចេញជាពីរប្រភេទវង់ភ្លេងគឺ : ប្រភេទវង់តន្ត្រីសុទ្ធ និងប្រភេទវង់តន្ត្រីល្ខោន ។

#### ១-ប្រភេទវង់តន្ត្រីសុទ្ធ

ប្រភេទវង់តន្ត្រីសុទ្ធគឺជាប្រភេទវង់តន្ត្រីដែលអាចប្រគំតែឧបករណ៍សុទ្ធ ដោយមិនចាំបាច់មានសិល្បករ សិល្បការិនីចម្រៀង របាំ ឬល្ខោនលេងជាមួយទេ ។ គឺគេសំដែង ឬប្រគំតែតន្ត្រីករ តន្ត្រីការិនី សុទ្ធប៉ុណ្ណោះអាចឮសូរសំនៀងពិរោះគ្រប់គ្រាន់ ។

ប្រភេទវង់តន្ត្រីសុទ្ធមាន :
- វង់តន្ត្រី អារក្ស
- វង់តន្ត្រី រៀបអាពាហ៍ពិពាហ៍ ឬ រៀបមង្គលការ
- វង់តន្ត្រី គងស្គរ ឬ ទាំមួង
- វង់តន្ត្រី ខ្លងឆ្នាក់ ( ស្គរយោលឬស្គរឈ្នះ )
- វង់តន្ត្រី ពិណពាទ្យ
- វង់តន្ត្រី មហោរី
- វង់តន្ត្រី មហោរីវៃឆ្ន

#### ២-ប្រភេទវង់តន្ត្រីល្ខោន

ប្រភេទវង់តន្ត្រីល្ខោន គឺជាប្រភេទវង់តន្ត្រីដែលប្រគំរួម ឬ ប្រគំកំដរជាមួយក្នុងវង់របាំ វង់ល្ខោនឬវង់ចម្រៀង ។ វង់សិល្បៈទាំងបីផ្នែកខាងលើនេះ គឺបានផ្សារភ្ជាប់គ្នាយ៉ាងជិតស្និតបំផុតជាមួយនឹងវង់តន្ត្រីល្ខោន គឺហាក់បីដូចជាសង្សាមួយគូ ដែលមិនអាចបែកចេញពីគ្នាបានឡើយឬប្រៀបបីដូចជាចាយនិងម្ហូបដោយខ្វះមួយណាមិនបានដាច់ខាត ។

ប្រភេទវង់តន្ត្រីល្ខោនមាន :
- វង់តន្ត្រីល្ខោនយីកេ
- វង់តន្ត្រីល្ខោនអាប៉េ
- វង់តន្ត្រីល្ខោនប្រមោទ្យ



www.elibraryofcambodia.org

- វង់តន្ត្រីភ្លេងមហោរី
- វង់តន្ត្រីអាយ៉ៃ
- វង់តន្ត្រីភ្លេងតែន
- វង់តន្ត្រីបាសាក់

*សំគាល់* : វង់តន្ត្រីសុទ្ធតែនៅក្នុងពេលប្រគុំមានចំរៀងកំដរជាមួយផងនោះ ពិរោះ ធ្វើឲ្យសំនៀងមានថាមពលពេញលក្ខណៈនៅក្នុងវង់តន្ត្រី ។

## ៤. ភារកិច្ចវង់តន្ត្រីផ្សារភ្ជាប់ជាមួយពិធី

យើងបានឃើញរួចមកហើយអំពីវង់តន្ត្រីបូរាណខ្មែរខាងលើ ។ ជាបន្ទាប់ទៀតនេះសូម បង្ហាញអំពីភារកិច្ចរបស់វង់តន្ត្រីនិមួយៗផ្សារភ្ជាប់ជាមួយពិធីផ្សេងៗ ។

*ក- វង់តន្ត្រីអារក្ស*

វង់តន្ត្រីអារក្សមានភារកិច្ចផ្សារភ្ជាប់ផ្ទាល់ជាមួយពិធីលៀងអារក្ស ។ វង់តន្ត្រីនេះមានអាយុ ចំណាស់ជាងគេក្នុងចំណោមវង់តន្ត្រីខ្មែរទាំងអស់និងមានកំណើតតាំងពីសម័យ កុកក- កជីម៉្លេះ ។ វង់នេះមានឧបករណ៍ភ្លេងចំនួន ៦ មុខ គឺ :

| | |
|---|---|
| ១- ទ្រខ្មែរ | ៤- ប៉ីពក |
| ២- ខ្សែដៀវ | ៥- ចាប៉ីដងវែង |
| ៣- ប៉ីអរ ឬ ប៉ីបបុស | ៦- ស្គរដៃ |

ឯស្គរមានចាប់ត្រឹមចំនួន២រហូតដល់១២ ។ វង់អារក្សនេះមានលក្ខណៈជាភ្លេងពិធីបូ .



www.elibraryofcambodia.org

ប្រពៃណីជំនឿព្រលឹងនិយមតាមរបៀបព្រហ្មញ្ញសាសនាផង និងជានិមិត្តរូបមួយប្រមូ
ផ្តុំនូវស្មារតីសាមគ្គីក្នុងគ្រួសារខ្មែរទូទៅផង ។ សម័យបុព្វកាលមនុស្សដើមខ្មែរយើង
បានកំណត់និងតម្រូវការចាំបាច់នៃវង់ភ្លេងនេះ គឺសំរាប់ប្រគំក្នុងពិធីឡើងរោងគ្រូអារក្ស
និងសំរាប់ប្រគំកំដរក្នុងពិធីរៀបអាពាហ៍ពិពាហ៍កូនប្រុសស្រីផង ។

ក-១ <u>ពិធីឡើងរោងគ្រូអារក្ស</u>

ពិធីឡើងរោងនេះគឺគេកំណត់ធ្វើក្នុងមួយឆ្នាំម្តង ឬបើមានករណីពិសេសណាមួយកើត
គេអាចធ្វើនៅពេលណាក៏បានដែរ ហើយពិធីឡើងរោងប្រចាំឆ្នាំនេះ គឺជាពិធីមួយសំរាប់
ជួបជុំកូនចៅសិស្សគណជិតឆ្ងាយដែលត្រូវមកគោរពបង្ហាញមុខចំពោះគ្រូបាធ្យាយរើរ៉ើ
បន់ស្រន់និងលាបំណន់ ព្រមទាំងសុំពរជ័យឱ្យគ្រូប្រសិទ្ធិ ប្រស់ព្រហ្មតំឡើងភាសិទ្ធិអោ
សិរីសួស្តីរកស៊ីមានបានឈ្នះមារសត្រូវគ្រប់ទិសទី ប្រកបដោយសុភមង្គលគ្រប់ប្រការ ។
ឯករណីពិសេសនោះគឺៈ ឧទាហរណ៍មានអ្នកជម្ងឺម្នាក់ឈឺធ្ងន់សឹងតែអស់សង្ឃឹម ហើយ
បានមកបែរបន់លោកគ្រូអារក្ស ឱ្យជួយព្យាបាលស្តោះផ្លុំបណ្តេញរោគឱ្យជាស្បះស្បើយ
ហើយបើអ្នកជម្ងឺនេះបានជាសះស្បើយមែន ខ្លួនសន្យាថានឹងធ្វើពិធីឡើងរោងថ្វាយភ្លេង
និងនំចំណីសំពត់អាវជាដើម ពេលក្រោយមកអ្នកជម្ងឺក៏បានជាសះស្បើយមែន ពេល
នោះហើយអ្នកបន់ស្រន់ចាំបាច់ត្រូវតែព្រះរៀបធ្វើពិធីឡើងលៀងអារក្សនេះជាបន្ទាន់ ដើម្បី
នឹងលាបំណន់ដែលខ្លួនបានបែរបន់ថ្វាយពីពេលកំពុងឈឺនោះ ។
ក្នុងនេះ មិនបានរៀបរាប់ពីរបៀបរបបនៃពិធី ឱ្យបានលំអិតរបស់គ្រូអារក្សសព្វគ្រប់
សូមបង្ហាញតែឈ្មោះបទភ្លេងនិងទំនុកច្រៀងមួយចំនួនតូចដែលត្រូវប្រគំបំរើក្នុងពិធីឡើង
រោងគ្រូអារក្សខ្លះៗ ដូចតទៅ ៖

ក-២ <u>ចាប់ផ្តើមពិធី</u>

មុនដំបូងត្រូវធ្វើពិធីសែនព្រះពិស្ណុការភ្លេងជាមុន ឯរណ្តាប់មានអង្គរមួយចានជាមួយ
បេកមួយស្និត ស្រាមួយកំប៉ុក ទៀន ធូប សំពត់សមួយអាវ នំចំណីផងៗ កាលណា



www.elibraryofcambodia.org

អុជទៀនធូបប្រកាសអញ្ជើញគ្រូរួចហើយ តន្ត្រីករក៏ចាប់ផ្តើមប្រគំឡើង :

១ <u>បទហោមរោងបូរាណ</u> -សំរាប់ប្រគំរំលឹកគុណគ្រូបាធ្យាយ ដែលបានផ្តល់ឱ្យចំណេះដឹងដល់ខ្លួន ពិសេសលោកតាឥសីជាគ្រូធំផង ។

បទនេះមានទំនុកដូចតទៅ :

-ឱនកាយថ្វាយបង្គំ លើកដៃប្រណម្យថ្លៃវន្ទា ដោយលើកដាក់ដំកល់
 ដល់ដែនមុនី ជាទីបំផុតបុរីរម្យ ។

២ <u>បទនិមន្តប៉ិពក</u> - សំរាប់ប្រគំអញ្ជើញគ្រូកំណើតមកសន្និតជាអធិបតី ។

បទនេះមានទំនុកដូចតទៅ :

-និមន្តតូចឮផំ និមន្តធំឮស្គរពើយៗ អ្នកថ្លៃគ្រូអើយ សូមលោកនិមន្តយាងអក។
-ខ្ញុំអុជទៀនធូប ដំកល់លើតោក សូមគ្រូនិមន្តមក ថ្វាយភ្លេងនិមន្តធំ ។
-ព្រាយហោះព្រាយហើរ ព្រាយដើរលើដី ព្រាយក្បាលប្រាំបី ចេញយកចំនីអាហារ។

៣ <u>បទសុរិន្ទខ្ទង់ភ្នំ ប៉ិពកប៉ិអ</u> -សំរាប់ប្រគំអញ្ជើញគ្រូដែលស្ថិតនៅលើកំពូលភ្នំ សូមនិមន្តមកស្ថិតក្នុងពិធីរោងនេះ ។ សារៈសំខាន់ គឺការថ្លែងទំនាក់ទំនងរវាងខ្មែរយើងនិងខ្មែរសុរិន្ទ ដែលសម័យនោះពុំទាន់ដាច់ការទាក់ទងគ្នានៅឡើយ ។ ខេត្តនេះឈ្មោះសុរិនជាអតីតខេត្តរបស់ខ្មែរ ដែលត្រូវបាត់បង់ដោយរៀតទិនិយមសៀម នៅសតវត្សទី ១៦-១៧ នៃគ្រឹះសករាជ ។

បទនេះមានទំនុកដូចតទៅ :

-បងដើរក្បែរព្រែក ស្តាប់ខ្មែកវាយំ ដើរដោយខ្ទង់ភ្នំ ឮស្រែកស្រដី
ខ្ញុំកាត់ឈើវែង ខ្ញុំសែងឈើខ្លី លីឈើប្អូនស្រី បីថ្ងៃហើយណា ។
-ជង្គង់ខ្ញុំបត់ ដៃខ្ញុំប្រណម្យ ទឹកដីឧត្តម ជាកេរ្តិ៍ជួនតា
គេផាក់ផណ្តើម គួរឱ្យខ្លោចផ្សារ វត្ថុថ្លៃថ្លា មហាស្រណោះព្រៃ ។
-ទឹកចិត្តរន្ធត់ បុត្រលើកប្រណម្យ មេបាតូចធំ សូមទានមេត្តា
ឮផពង្សអំបូរ ជាជាតិខេមរា គោរពមេបា តរៀងទៅអើយ ។



www.elibraryofcambodia.org

៤ ព្រះបវរ ឬ បវរ "ស្មោង" -សំរាប់ប្រគំសរសើរពីលក្ខណៈរបស់តួអង្គគ្រូនិមួយៗ ។
បទនេះមានទំនុកដូចតទៅ :

-អ្នកថ្លៃពាស់ កូនចៅស្រឡាញ់គ្រូណាស់ ថាគ្រូមិនដូចអស់គេ
គ្រូមិនចេះកាញ់ គ្រូមិនចេះគ្នេរមិនដូចអស់គេ ដើរទៅហៅមក
កូនចៅប្រុសស្រី តែងតែចូលជ្រកដើរទៅហៅមក សិស្សរបស់គ្រូទេ ។
-ថ្លៃបវរល្អគ្មានពីរ សមអ្វីម្ល៉េះទេគួរឱ្យគយគន់ ខ្ញុំអុជទៀនធូបមួយកូ
សូមលោកនិមន្ត កូនចៅបន់ស្រន់ ថ្វាយភ្លេងខែឆ្នាំ
ស្តាប់ចុះប៉ីទ្រស្រស្រាក់ ស្រស្រាំរដូវខែឆ្នាំ ក្រសាលលេងសប្បាយ ។

៥ បទតន់តូច -សំរាប់ប្រគំក្នុងពិធីលួងលោមខ្មោចស្រីឈ្មោះតន់តូចឱ្យទន់ចិត្ត ។
បទនេះមានទំនុកដូចតទៅ :

-ឱតន់តូចអើយ ដឹកគោទៅទឹម គោថាយធ្លាក់នឹម និយបងទឹមនិយ ។
-ឱតន់តូចអើយ ដឹកគោទៅចង បងសុំថើបម្តង បងចងគោនិយ ។

៦ បទកែ -សំរាប់ប្រគំបញ្ជោរខ្មោចស្រី ឈ្មោះនាងកែ ។
បទនេះមានទំនុកដូចតទៅ :

-កែអើយស្រីកែ នាងមកពីស្រែ បានអីផ្ញើរបង បានចេកអំបុក
និងលាចបំពង បានអីផ្ញើរបងទងវែង បងឱ្យកក្តាន់ ។
-ស្រីកែៗអើយ នាងអើយរទេញ ខឹងហើយជាវិញ ជាលើសពីដើម ។

៧ បទអ្នក -សំរាប់ប្រគំក្នុងពេលបញ្ជោរខ្មោចបែបលេបខាយ ។
បទនេះមានទំនុកដូចតទៅ :

-អ្នកអើយស្រីអ្នក ពាក់មួកក្រឡឹង ភ្ជាក់ដៃសន្ទឹង សំរាប់ផ្ទែកទឹក
ស្រីផឹកមួយយប់ រហូតទើសព្រឹក អ្នកគ្មានបានទឹក នាងល់កូនចៅ ។

៨បទជួរ -សំរាប់ច្រៀងរៀបរាប់នូវគ្រឿងផង្វាយមានសំពត់អាវជាវស្បែនធំចំណីក្រប់ព្រះ
ខ្វះ ។



www.elibraryofcambodia.org

បទនេះមានទំនុកដូចតទៅ ៖

-អ្នកថ្លៃឧត្ដម ថ្ងៃនេះយើងខ្ញុំ បង្គំឱ្យអ្នកថ្លៃយាងមក កូនចៅប្រុសស្រី តែងតែចូលជ្រក សូមថ្លៃយាងមក ក្រសាលសប្បាយ ។

-បំណីអាហារ រៀបចំត្រៀបត្រា មានទាំងគាល់ថ្វាយ សេពសោយរួចហើយ ដោយចិត្តសប្បាយ និងរៀបចំការ ត្រឡប់វិលវិញ ។

៩ បទស្មោង -សំរាប់ច្រៀងរៀបរាប់អំពីការធ្វើដំណើរនៃមាណពម្នាក់បានជួបនឹងស្រ្តីម្នាក់កំពុងសង្ងំ ក៏បានច្រៀងរៀបរាប់ ។

បទនេះមានទំនុកដូចតទៅ ៖

-មកពីក្រោមឆាយ ហៅមហាសំពាក់ ដេកដោយឆាងចាក ជំនោរដាបដល់ វាដាបទាំងពួក ដាបទាំងឆ្អើយខ្វល់ ជំនោរដាបដល់ ដាបខ្លួនប្អូនស្រី ។

-ទឹកជន់សាយច្រាំង ជនខ្វាំងសាយអួរ សូមលោកអាសូរ ស៊ុតខ្ញុំខ្លួនម្ដង បើក្តិចសន្ទឹក កុំតែកាត់ត្រួយ ខ្លួនខ្ញុំតែមួយ រំពឹងតែលោក ។

-ជំនោរខ្យល់ជូន រៀបឬស្សីធ្វើក្បូន ជូនអូនទៅស្រុក លាទាំងលោកម្ដាយ លាទាំងលោកឪពុក ជូនអូនទៅស្រុក សូមសុខសប្បាយ ។

១០-បទព្រៃឯកើត -សំរាប់ប្រគំប្រើទៅតាមទិសនៃខ្មោចនិមួយៗដែលមកសង្គិត ។

បទនេះមានទំនុកដូចតទៅ ៖

-ព្រលប់ផ្កាយព្រាក អាព្រាគផ្កាយព្រោង សំបូងសំរុង គ្រប់អង្គសង្គិត ទិសទាំងប្រាំបី យាងមកជុំជិត អង្គចូលសង្គិត ក្រសាលសប្បាយ ។

១១-បទកាយខ្ជន

-សំរាប់ប្រគំជំរុញខ្មោចឱ្យចូលសង្គិតជាន់រូបកាន់តែខ្លាំងនិងទទួលបំណីអាហារប្រញ៉ាប់វិលផង ។

-ឪស្រស់ៗប្រឡើង អ្នកអើយកុំខឹងកុំខឹងនឹងបង

ចង់បីៗត្រកង ត្រញីចធ្វើបម្លងៗឱ្យអស់ចិត្ត ។



www.elibraryofcambodia.org

-ព្រាយហោះៗព្រាយហើរ　　បណ្ដើរៗកូនខ្មី
ព្រាយក្បាលៗប្រាំបី　　យកចំណីៗអាហារ ។
-មានទាំងៗពៃយោង　　មានពៃៗសាលា
ចេញយកៗអាហារ　　សោយហើយៗវិលវិញ ។

១២ បទជ្រេងដើមបទ -សំរាប់ច្រៀងគោរពទូវអនុភាពខ្មោច ដែលមានអនុភាពខ្លាំង ឲ្យតែឱ្យយាងមកសន្និតជួយកំចាត់ឧបទ្រព្យចង្រៃ និងព្យាបាលស្ដោះផ្លុំបណ្ដេញរោគឱ្យដាច់ជាសះស្បើយផង ឬប្រើក្នុងពិធីរៀបអាពាហ៍ពិពាហ៍គេច្រៀងគោរពសរសើរលោកមេបាតូចធំ ។

បទនេះមានទំនុកដូចតទៅ :

-ឱព្រះគុណអើយមានបុណ្យចេស្ដា　　សូមឱនសិរសាគោរពពីចំងាយ
សូមព្រះគុណជួយកំចាត់ភ័យអន្តរាយ　　កូនចៅបានសុខសប្បាយតរៀងទៅ។
-កន្ទ្រែងថង់វេងកំណត់ពេលព្រឹក　　លោកមេបាពិសារហើយសូមជូនជ្រេងស្រងាត់
-ថ្ងៃត្រង់ហើយសូមជំរាបទៅលោកមេបា　　សូមលោកខ្ជាក់ស្លាខ្លួលមាត់ពិសារក្រយាក្ដៅៗ　　បាត់តែប្ដឹងទៅអ្នកមេបាកុំបង្អង់នៅ　　សូមជំរាបទៅលោកមេបាប្រុសស្រី
សូមជូនជ្រេងស្រងាត់គំរប់៣បទសូមទានជ្រាប ។

១៣ បទមាន់វងារ- សំរាប់ប្រគំច្រៀងថែចង់ខ្មោចដើម្បីឱ្យខ្មោចឆាប់ចូលសន្និត ។

ទំនុកច្រៀងមានដូចតទៅ :

-បងបីមាន់ផ្ទាក់　　ទៅទាក់មាន់ព្រៃ　　ស្បែរតុម្ពប្ញស្សី　　រំពៃមើលអូន
-វង់ភក្រ័ក្រឡង់　　ហ្មត់ដូចគេសូន្យ　　ផ្កាល់ដូចបេកទូន　　រូបបងនិងអូន
ភូព្រេងនិងផ្កា ។

១៤ បទកំពើរ -សំរាប់ប្រគំបញ្ជោរខ្មោចស្រីឈ្មោះនាងកំពើរ ។

បទនេះមានទំនុកដូចតទៅ :

-អញថាកំពើរ　　ទៅលេងទឹកផ្លុក　　អញថាកំពើរ　　កន្ត្រែបតឹងត្ដដេញខាំកំពើរ



www.elibraryofcambodia.org

អញថាកំពើរ ទៅលេងទឹកស្រះ ដល់ពេលថ្ងៃរះ កាត់រកកំពើរ
បានជួបភ័ក្រហើយ មើលទៅមើលមក បានជួបកំពើរ ចង់និយាយចង់ចើប ។
១៥ បទខែធរាប -សំរាប់ប្រគុំកំដរពេលខ្មោចសង្ឃិតបង់បានភស្តុភារបណ្ណាការ ដែលមានរៀបចំនៅចំពោះមុខនេះស្រាប់ ។
បទនេះមានទំនុកដូចតទៅ :
-ឱខែធរាបអើយថ្ងៃឧត្តម ថ្ងៃនេះយើងខ្ញុំបង្គំឱ្យខែធយាងមក
កូនចៅប្រុសស្រីតែងតែបួលជ្រុក ខែធរាបយាងមកឱ្យកូនចៅសុខសប្បាយ ។
១៦ បទលំអងធ្នង់ -សំរាប់បញ្ជោរសរសើរពីលក្ខណៈសម្បត្តិនិងកិត្យានុភាព រិទ្ធិខ្លាំងពូកែរបស់ខ្មោច ។
បទនេះមានទំនុកច្រៀងដូចតទៅ :
-ជង្គង់ខ្ញុំបត់ ដៃខ្ញុំប្រណម្យ និងកាយថ្វាយបង្គំ សូមលោកគ្រូលំអងធ្នង់យាងមក អុចទៀនទាំងគូ ដំកល់លើតោក លំអងធ្នង់យាងមក និយាយបានដឹងព្រះឱស្ឋ ។
-កញ្ចើឈ្មោះពិរោះ ល្បីលើផែនភព ស័ក្តិសមទាំងគ្រប់ ល្អឥតមានទាស់ សូមយាងមកប្រស់ព្រំ សិស្សគណទាំងអស់ និយាយបានសីរី សួស្តីតរៀងទៅ ។
១៧ បទដំបងដែក -សំរាប់ប្រគុំប្រមូលស្តេចខ្មោចមកជួបជុំ ដើម្បីទទួលទ្រព្យដង្វាយផ្សេងៗ ។ បទនេះពម្ងតានៅពេលប្រគុំត្រូវមានស្គរចំនួន៤-៨ឬរហូតដល់១២ ។
បទនេះមានទំនុកដូចតទៅ :
-អ្នកថ្ងៃឧត្តមលោកគ្រូដំបងដែកជាធំ សូមលោកឧិមន្តយាងមក
ដូចរាមត្រជាក់កូនចៅតែងបួលជ្រក គ្រូដំបងដែកយាងមក
ថ្វាយភ្លេងទាំងរណ្តាប់ ។
-ដំបងដែករិទ្ធិខ្លាំងណាស់បង្ក្រាបអន្តរាយ លត់ភ្លើងបង្ក្រានបានសុខសប្បាយ
កូនចៅទាំងឡាយបានសុខសាន្តតរៀងទៅ ។



www.elibraryofcambodia.org

១៨ បទនាងគីសង្រេង -សំរាប់បំពេរខ្មោចស្រីឈ្មោះនាងគី ។

បទនេះមានទំនុកដូចតទៅ :

-អញបំពេរហើយ រេហ៍ដោយព្រៃ រំពេរំពៃ ឈាងឆាបមន្ថា
នាងគីសង្រេង ធ្វើឱ្យបរឹង ឱ្យបមានរាង ដោះអាវទៅណាង
ឱ្យបងឃើញរាង ឃើញដោះនាងក្បុំ ជាក់គីអើយនាងគីៗ បើនាងអត់ប្ដី
ឱ្យបងសិនទៅ ។



www.elibraryofcambodia.org

រូបភាពរៀបអាពាហ៍ពិពាហ៍



ប្រពៃណីអាពាហ៍ពិពាហ៍របស់ខ្មែរគឺជាសង្គហៈមង្គលនៃមាតាបិតាមកលើបុត្រ និងបង្ហាញពីព្រហ្មចារីយ៍ធម៌នៃមនុស្សទូទៅ ដែលបានបំពេញនូវតំលៃប្រពៃណីជាតិរបស់ខ្លួន ។ ដោយឡែកលក្ខណៈអប់រំផ្នែកសិលធម៌សង្គមនឹងបានទទួលនូវតំបូន្មានដ៏ល្អប្រពៃពីលោកមេបា ពីលោកអាចារ្យ និងតាមរយៈពាក្យពេចន៍នៃបទចំរៀងប្រពៃណីបូរាណមួយចំនួន



www.elibraryofcambodia.org

ផងនោះ ធ្វើឱ្យមនោសញ្ចេតនាក្នុងជីវិតថ្មីទាំងពីរផ្សារភ្ជាប់គ្រួសាររបស់ខ្លួនទៅនឹងកាតិអ៊ីក ដីជាទីស្រឡាញ់ប្ដូរផ្ដាច់រហូតអវសានក្នុងជីវិតរៀងៗខ្លួន ។

*ខ- វង់តន្ត្រីរៀបអាពាហ៍ពិពាហ៍ឬរៀបមង្គលការ*

វង់តន្ត្រីនេះ បានផ្សារភ្ជាប់ជានិច្ចជាមួយពិធីរៀបអាពាហ៍ពិពាហ៍ឬរៀបមង្គលការ ។ បន្តទៅនេះ សូមបង្ហាញវង់តន្ត្រីរៀបមង្គលការនៅក្នុងសម័យកណ្ដាល ដែលសំរាប់ប្រគំកំដរក្នុងពិធីរៀបមង្គលការទៅតាមកម្មវិធីនិមួយៗ ដូចមានខាងក្រោមនេះ :

*កម្មវិធីទី ១* ពិធីដង្ហែកូនប្រុស

ពេលដង្ហែកូនប្រុសទៅកាន់គេហដ្ឋានខាងស្រីឬដង្ហែចូលរោងជ័យ មុនដំបូងគេត្រូវរៀបចំវេញខ្សែទ្រ ខ្សែចាប៉ី នៅឯផ្ទះកូនប្រុស ។ ពេលកំពុងវិញខ្សែនោះ ក្រុមភ្លេងត្រូវប្រគំ : ១-បទផ្សំស្នូត្រ

ពេលរៀបចំភ្លេងសព្វគ្រប់ហើយលោកអាចារ្យក៏ចាប់ផ្ដើមធ្វើពិធីដង្ហែកូនប្រុសទៅកាន់គេហដ្ឋានខាងស្រីតែម្ដងដើម្បីចូលរោងជ័យ ។ នៅពេលដង្ហែនោះត្រូវប្រគំ :

២-បទស្វាកងពល ឬ បទចៅព្រាហ្មណ៍

កាលណាក្បួនដង្ហែកូនប្រុសទៅដល់ទ្វាររបងផ្ទះកូនស្រី ហើយបើទ្វាររបងផ្ទះនោះពិតជិតពេលនោះ អ្នកភ្លេងត្រូវប្រគំ : ៣ -បទរបាំងមាស ឬរបាំងដឹរ (ដើម្បីសុំអនុញ្ញាតិពីលោកមេបាសុំផ្លូវចូលរោងជ័យ ) ។

*កម្មវិធីទី ២* ពិធីជាន់រោង

ពេលដង្ហែកូនប្រុសចូលរោងជ័យហើយលោកអាចារ្យក៏រៀបចំគ្រឿងសក្ការៈបូជាភ្លាមមាននៀនធូប ទេកទុំ នំបំណី បារីស្លាជាដើម ។ល។ ប្រកាសបួងសួងបន់ស្រន់រំលឹកគុណគ្រូបាធ្យាយ ជីដូនជីតា ទេព្ដា មេព្រៃក្ស អ្នកតាចាស់ស្រុករក្សាទឹកដីភូមិករ ពិសេសព្រះពិស្ណុការ សូមអញ្ជើញមកសន្ថិតក្នុងទីរោងជ័យនេះដើម្បីទទួលនូវគ្រឿងសក្ការៈបូជា



www.elibraryofcambodia.org

ទាំងឡាយដែលយើងខ្ញុំបានរៀបចំថ្វាយក្នុងពេលនេះបើបានសេពសោយរួចហើយ សូម
ជួយឱ្យពរជ័យសិរីមង្គលវិបុលសុខគ្រប់យ៉ាងដល់កូនចៅប្រុសស្រីជាគូស្វាមីភរិយាថ្មី ។
ក្នុងពិធីជាន់រោងជ័យនេះភ្លេងត្រូវប្រគំ :

១- បទហោមរោង ២- បទជ័យ

៣- បទអង្គរពេជ្យ ៤- បទស្តេចថ្មី

*កម្មវិធីទី ៣* ពិធីស៊ីស្លាកំណត់

នៅពេលដង្ហែភស្តុភារបណ្ណាការឡើងដល់គេហដ្ឋានលោកមេបាហើយ អ្នកថ្នំវចៅមហា
ចាប់ផ្តើមធ្វើការពិភាក្សាសំពោះសំណាលនិងបែបផ្លូវសុំចងស្ពានមានមេត្រីសុំស្តីដណ្តឹងកូន
ស្រីលោកមេបាឱ្យទៅកូនឈ្មោះ...... កាលបើលោកមេបាប្រុសស្រីបានយល់ព្រមហើយ
ក៏ចាប់ស្លាជ័យ ម្លូជ័យ ស្លាថង់វង់ជូនទៅលោកមេបាខាងកូនស្រីភ្លាម ។ ឯលោកមេបា
ក៏ទទួលហើយក៏ចាប់យកភស្តុភារបណ្ណាការ ផ្លែឈើ នំបំណើមួយចំនួនលើកថ្វាយទៅ
វិញ្ញាណក្ខ័ន្ធជីដូនជីតា ញាតិការទាំងប្រាំពីរសន្តានអញ្ជើញសេពសោយសព្វព្រះហឫទ័យ
ជាកិច្ចតបស្នងសងគុណតាមប្រពៃណីពីបរមបុរាណមក ។ ពេលនោះភ្លេងត្រូវប្រគំ :
១-បទស៊ីនខ្លងភ្នំ (អញ្ជើញជូនតាមកជាអធិបតី )
២-បទកងសោយ ( កំដរជូនតាសេពសោយ )
បន្ទាប់ពីជូនតាសេពសោយរួចហើយ លោកមេបាចាស់ទុំដែលមានមុខក្នុងទីនោះក៏ចាប់
ផ្តើមពិសារស្លាប្រសព្វមុខសុបប្ញួលគ្នាតែម្តង ។ ពេលនោះភ្លេងត្រូវប្រគំ :
៣-បទប៉ុកពីក (កំដរលោកមេបាពិសារស្លាគ្រប់មុខ )
កាលបើលោកមេបាពិសារស្លាគ្រប់មុខហើយទើបគេបន្ទយធ្នូវភស្តុភារបណ្ណាការទាំងអស់
នោះយកទៅដាក់ទុកមួយកន្លែងនិងចែកជូនចំពោះភ្ញៀវពិសារជាទូទៅផង ។ ពេលនោះ
ភ្លេងត្រូវប្រគំ : ៤-សំពៅថយ ឬ បន្ទយស្លូក



www.elibraryofcambodia.org

*កម្មវិធីទី ៤* ពិធីកាត់ផ្កាស្លា

ពេលដង្ហែកូនប្រុសទៅកាន់ដើមស្លាភ្លេងប្រគំបទចៅព្រាហ្មណ៍។ ពេលទៅដល់ដើមស្លាភ្លាមលោកអាចារ្យចាប់ផ្តើមអុជទៀនធូបប្រកាសឧទ្ទិសសុំពរជ័យពីទេវតារក្សាព្រៃព្រឹក្សាភូមិករ សូមមេត្តាប្រទានផ្កាស្លាជ័យនេះមកដល់កូនប្រុសស្រីដែលបានរៀបចំមង្គលការថ្មីនេះឱ្យបានសុខសប្បាយឈ្នះមារសត្រូវគ្រប់ទិសទី ពេលនោះភ្លេងប្រគំ :

១-បទចៅព្រាហ្មណ៍ (ពេលដង្ហែ )

២-បទមួយផ្លូង (ពេលកំពុងកាត់ផ្កាស្លា )

*កម្មវិធីទី ៥* ពិធីសំពះអ្នកតា

ពេលដង្ហែកូនប្រុសដល់ខ្ទមអ្នកតាភ្លេងត្រូវប្រគំបទចៅព្រាហ្មណ៍បន្ទាប់មកលោកអាចារ្យរៀបចំទីបំណី បារីស្លាជាដើមថ្វាយចំពោះអ្នកតារបស់ស្រុកថែរក្សាទឹកដីភូមិករ សូមអញ្ជើញសេពសោយដោយរីករាយ ហើយសូមពរជ័យដល់កូនចៅប្រុសស្រីដែលបានរៀបចំមង្គលការនេះសូមឱ្យបានប្រកបដោយសិរីសួស្តី ជ័យមង្គលវិបុលសុខគ្រប់ប្រការ។ ភ្លេងត្រូវប្រគំ :

១-បទកងសោយ ( កំដរអ្នកតាសេពសោយ )

២-បទចៅព្រាហ្មណ៍ ( ជូនដំណើរកូនប្រុសត្រឡប់ទៅផ្ទះវិញ )

*កម្មវិធីទី ៦* ពិធីកាត់សក់

នៅពេលឪពុកម្តាយកូនប្រុសស្រីទាំងសងខាង ព្រមទាំងញាតិមិត្តជិតឆ្ងាយមកជួបជុំគ្នាអស់ហើយ លោកអាចារ្យក៏រៀបចំពិធីកាត់សក់ ។ ឯពិធីរបៀបកាត់សក់នេះ គេនិយមធ្វើដោយមានការសំដែងទៅតាមរបៀបទស្សនីយភាពជារឿងខ្លីៗ។ គេបានកំណត់ឈ្មោះឪពុកម្តាយកូនប្រុសស្រីទាំងសងខាងនេះជាសេដ្ឋី ដែលបានព្រោរព្ធពិធីរៀបចំអាពាហ៍ពិពាហ៍កូនប្រុសស្រីរបស់គាត់ទាំងពីរក្នុងថ្ងៃនេះ ហើយគាត់បានធ្វើពិធីបួងសួងអំពាវនាវ



www.elibraryofcambodia.org

ចំពោះព្រះភក្រ្តាធិរាជជាស្តេចនៃទេវតាថា បើកូនប្រុសស្រីទាំងពីររបស់គាត់ជាកូនព្រេង និងផ្កាមែន សូមព្រះអង្គប្រទានទ្រព្យវត្ថុទិព្វពីកន្ត្រៃមាស ក្រាសប្រាក់ កញ្ចក់ទិព្វ ការ៉ែក ពោរទឹកអប់ប្រេងម្សៅដើម្បីកាត់សក់កោរសក់ ពំពេញសិរីសួស្តីកូនប្រុសស្រីទាំងពីរ ជាគូស្វាមីភរិយាថ្មីនេះ ឱ្យបានប្រកបដោយសុភមង្គលវិបុលសុខគ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ។ ពេលនោះអ្នកភ្លេងក៏ជាតំណាងទេវតាដែរ ហើយអ្នកភ្លេងចាប់ផ្តើមសំដែងជាឈុតអាយ៉ៃទៅតាមដំណើររាប់រឿងដូចបានរៀបរាប់ជូនខាងលើនេះ ក្រុមភ្លេងមុនដំបូងត្រូវប្រគំ :

១-បទបំពេរក្អាយ ២-បទគេនចារ៉

៣-បទសយសង្ខារឬសយសង្ខាន ៤-បទសែនស្រណោះ

៥-បទពេលាងភិរម្យរ ៦-បទចាបដើរដី

៧-បទសារិកាកែវ ៨-បទត្រពាំងពាយ

៩-បទភ្ញុំភ្នង ។ល។

នៅមានបទមួយចំនួនទៀតយោងទៅតាមពេលវេលាខ្លី ឬ វែង ។

តាមការសង្កេត : ក្នុងពេលសម័យបច្ចុប្បន្ននេះ ក្រុមអ្នកភ្លេងភាគច្រើនពេញចិត្តនិយមប្រើបទភ្លេងបន្ថែមទៅលើលំនាំពីបុរាណផងដើម្បីបំពីរទូវមនោសញ្ចេតនាសប្បាយរីករាយក្នុងពិធីកាត់សក់នេះមានចំនុចខ្វះបំភ្លេចក៏សឹងមាន។ បន្ទាប់មកអ្នកភ្លេងជាតំណាងទេវតាក៏បានជូនទ្រព្យវត្ថុទិព្វទាំងអស់នោះទៅលោកសេដ្ឋី ដើម្បីជាវយកវត្ថុទាំងអស់នេះទៅកោរកេសាកេសីកូនប្រុសស្រីរបស់លោកទាំងពីរតែម្តង។ពេលនោះក្រុមភ្លេងចាប់ប្រគំ :

១- បទត្រពាំងពាយ ២-បទភ្ញុំភ្នង ( ជូនពរចំពោះកូនប្រុសស្រីទាំងពីរ )

*កម្មវិធីទី ៧* ពិធីដង្ហែកូនប្រុសស្រីទៅមុជទឹក

ជំនាន់ពីបុរាណកាលពេលកូនប្រុសស្រីទាំងពីរកាត់សក់រួចហើយ ត្រូវដង្ហែទៅមុជទឹកពត្រពាំងពាយ។ នៅពេលមុជទឹកនោះត្រូវផុះក្បាលជំរះកាយឱ្យគ្នាទៅវិញទៅមកម្តងម្នាក់។



www.elibraryofcambodia.org

ទើបឡើងពីត្រពាំងមកវិញ ក្រុមភ្លេងត្រូវប្រគំ :

១-បទជីតមន ( ដង្ហែកូនប្រុសស្រីទៅមុជទឹក )

២-បទត្រពាំងពាយ ( ប្រគុំកំដរពេលមុជទឹក ) ,

៣-បទជីតមន ( ដង្ហែត្រឡប់មកផ្ទះវិញ )

*កម្មវិធីទី៨* ពិធីក្រុងពាលី

នៅពេលសៀលល្ងាចលោកអាចារ្យបានរៀបចំធ្វើពិធីក្រុងពាលី ។ ពេលនោះលោកអាចារ្យនិងមាតាបិតាចាស់ទុំទាំងអស់មកជួបជុំគ្នា ។ មុនដំបូងលោកអាចារ្យចាប់ប្រកាសបួងសួងដល់គ្រូបាធ្យាយជីដូនជីតា ទេព្តារក្សាព្រៃព្រឹក្សា អ្នកតាចាស់ស្រុក នាងគង្ហីងព្រះធរណី ព្រះពិស្ណុការ ស្តេចក្រុងពាលីម្ចាស់ទឹកដី សូមយាងអញ្ជើញមកស្ថិតនៅទីនេះជាអធិបតីនិងទទួលនូវគ្រឿងសក្ការៈបូជាមាន ចេកទុំ នំចំណី បារីស្លា ផ្កាភ្ញីបង្អែមចង្ហាប់ មានសំពត់អាវឆ្វេងស្តាំតាមចំណាំមានសព្វគ្រប់ សូមទទួលសេពសោយដោយសប្បាយរីករាយហប្ញទ័យរួចហើយ សូមប្រទានពរជ័យសិរីមង្គលដល់គូស្វាមីភរិយាទាំងពីរនេះ ឱ្យបានសុខដុមរមនាចាប់តាំងពីថ្ងៃនេះតរៀងទៅ ពេលនោះភ្លេងក៏ប្រគំ :

១-បទកងសោយ ( កំដរអស់លោកសេពសោយ )

២-បទបាយខុន ( ជាកិច្ចប្រសិទ្ធិពរគូស្វាមីភរិយាថ្មី )

*កម្មវិធីទី ៩* ពិធីសូត្រមន្ត

នៅពេលព្រលប់ក្រោយពីភ្ញៀវពិសារភោជនាហាររួចហើយ លោកអាចារ្យមេបាប្រុសស្រីបាននាំសាមីខ្លួន ដើម្បីចេញមកគោរពព្រះរតនៈត្រ័យគឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃព្រមទាំងចាំស្តាប់ព្រះសង្ឃស្វាធ្យាយធម៌ចំរើនព្រះបរិត្តជាជ័យមង្គល ប្រសិទ្ធិពរសិរីសួស្តីដល់គូស្វាមីភរិយាថ្មីចាប់ពីពេលនេះតទៅ ។



www.elibraryofcambodia.org

__កម្មវិធី១០__ ពិធីចងផ្កាស្លា

មុននឹងបកផ្កាស្លាចងជាកម្រងលំដាប់លំដោយលោកអាចារ្យត្រូវបួងសួងអធិដ្ឋានសុំពរពីទេព្ដាត្រូវតាឡាយ ជីដូនជីតាទាំងអស់ សូមអញ្ជើញមកស្ថិតជួយប្រសិទ្ធពរលើកម្រងផ្កាទាំងបីរៀងនេះ។ឯកម្រងផ្កាទាំងបីរៀងនេះ គឺជានិមិត្តរូបតំណាងមាតាបិតានិងរៀមច្បងជាអ្នកគ្រប់គ្រងនូវបុត្រទាំងពីរនេះតាំងពីតូចរហូតដល់ពេលនេះ និងឱ្យរក្សាថ្នាចាប់ពីពេលនេះរហូតយាវជីវិតផង ។ ពេលនោះភ្លេងត្រូវប្រគំ :

១-បទកន្ធង់រតន៍ ( កំដរពេលកំពុងចងផ្កាស្លា )

២-បទលំអងធ្នង់ ( ជាកិច្ចប្រសិទ្ធិពរលើផ្កាស្លា )

__កម្មវិធីទី ១១__ ពិធីជុំពិលា

ពិធីជុំពិលាគឺជាពិធីពេលជួបជុំនៃលោកមេបាតូចធំ មាតាបិតាទាំងសងខាងអញ្ជើញមកទទួលនូវភោជនាហារសាម៉ីខ្លួនកូនប្រុសកូនស្រីជាអ្នកបំរើ និងជាពេលកំណត់កម្មវិធីមង្គលការទាំងមូលផង ។ ពេលនោះភ្លេងត្រូវប្រគំ :

១-បទក្លោងធំ ( គោរពអញ្ជើញលោកមេបាឡើងលើកំរាល )

២-បទចំបក់ភេយ ( សរសើរពើកព្វំាសនាលោកមេបា )

__កម្មវិធីទី ១២__ ពិធីបុកល័ក្ខ

បន្ទាប់ពីពិធីជុំពិលារួចហើយលោកមេបាបានបង្គាប់ឱ្យគេទៅរកស្លឹកវេចនំ និងល័ក្ខជុំក្រឡង់សំរាប់មកផ្សំជាឱសថ ដើម្បីធ្វើថ្នេញបំពេញលក្ខណៈកូនស្រីលោកមេបា ។ មុនដំបូងអ្នកបំរើក៏បានចេញដំណើរទៅតាមជើងទឹកគឺទៅតាមទូក ដើម្បីទៅរកស្លឹកនិងល័ក្ខមកជូនលោកមេបាឱ្យទាន់ពេលវេលា ។ ពេលនោះក្រុមភ្លេងចាប់ប្រគំ :



www.elibraryofcambodia.org

១- បទអុំទូក (ចេញដំណើរតាមទូក)

លុះទៅដល់ឯត្រើយម្ខាងក៏ដើរទៅដល់ព្រៃជ្រៅនាំគ្នាដើររកស្លឹកនិងរកលក្តិជុំក្រឡង់គ្រប់ទិសទី ប៉ុន្តែរកមិនទាន់បានក៏នាំគ្នាទៅសំរាកនៅក្រោមឈើធំមួយ ។ ជួនពេលនោះក្រឡេកទៅឃើញលក្តិជុំក្រឡង់ដុះជាប់នឹងមែកឈើមានចំនួនយ៉ាងច្រើនក៏នាំគ្នាឡើងបេះយ៉ាងប្រញាប់ប្រញាល់ ។ កំពុងតែបេះស្រាប់តែមានឃ្មុំជាច្រើនហើរព្រោងព្រាតដេញទិច អ្នកខ្លះសំរូតធ្លាក់ពីលើដើមឈើមើលទៅមិនអាចបេះល័ក្តនេះបានទេ អ្នកទាំងអស់នោះក៏នាំគ្នាទៅរកគ្រូបញ្ជាន់អារក្សដើម្បីសាកសួរតើហេតុអ្វីបានជាសត្វឃ្មុំមកពីណាដេញទិចច្រើនម្ល៉េះ? រូបអារក្សស្ថិតហើយឆ្លើយថា អ្នកទាំងអស់គ្នាហ្នឹងខុសមាត់និយាយផ្តេសផ្តាស់ហ៊ានមើលងាយយើងហ៊ានទាំងនោមប្រាសក្បាលយើងផង ដូច្នេះយើងត្រូវកាច់យករូបឥឡូវនេះហើយ ។ ឯពួកអ្នករកល័ក្តក៏ភ័យខ្លាចសូមអង្វរ សូមបន់ស្រន់ថ្វាយកាទន់ពាក់កនិងអាការសាហាវទើបខ្មោចអារក្សអ្នកតានោះសុខចិត្ត។ ពេលបញ្ជាន់អារក្សភ្លេងប្រគំ :

១-បទព្រៃឯកើត ឬ បទកាត់ស្លឹក

២-បទបាយខុន ( ពេលអារក្សជាន់កាន់តែខ្លាំង )

បន្ទាប់ពីនាំគ្នាឡើងបេះលក្តិបានហើយក៏ត្រឡប់មកផ្ទះវិញ។ នៅពេលត្រឡប់មកដល់ផ្ទះភ្លាមនោះ ក៏យកល័ក្តមកផ្សំជាមួយសាច់ជូរនិងថ្នាំមួយមុខទៀតបុកបញ្ចូលគ្នារួចហើយយកទៅជូនលោកមេបា ដើម្បីធ្វើម្ជុលបំពេញល័ក្តកូនស្រីលោកមេបាផង ។ ភ្លេងប្រគំបទ : ១-បទបុកលក្តិ ( កំដរពេលបុកលក្តិ )

*កម្មវិធីទី១៣* ពិធីជាវខន្ទស្លា

មុននឹងធ្វើពិធីជាវខន្ទស្លា លោកអាចារ្យបានអញ្ជើញលោកមេបាជាឪពុកម្តាយកូនប្រុសស្រីមកជួបជុំគ្នាឱ្យអញ្ជើញឡើងលើកំរាលព្រំ ពេលនោះសាម៉ីខ្លួនកូនប្រុសស្រីបានយាំងឆត្រជូនឪពុកម្តាយទាំងសងខាង ភ្លេងត្រូវប្រគំ :



www.elibraryofcambodia.org

១-បទជ្រេងកាល់ក្រយា ( អញ្ជើញមេបាឡើងលើកំរាលព្រំ )
២-បទទឹកទប់ ( រៀបរាប់ពីគុណសម្បត្តិនិងសិទ្ធគ្រប់គ្រងនៃលោកមេបាចំពោះកូន)
បន្ទាប់មកទៀតអ្នកភ្លេងច្រៀងរៀបរាប់ពីគុណធម៌និងព្រហ្មវិហារធម៌របស់មាតាបិតាដែល លោកបានចិញ្ចឹមបីបាច់ថែរក្សាបកូនទាំងពីរតាំងពីកូនមកចាប់ផ្ទៃ ប្រសូតចេញមកបាន រស់ដឹងក្តីមកទល់ពេលនេះ ហើយបានទុកដាក់ឱ្យមានគូស្រករស្វាមីភរិយាថ្មីមានខន្ធស្លា តាមប្រពៃណីជាតិ ប្រកបដោយទឹកចិត្តដ៏ត្រជាក់ក្នុងន័យសង្គហធម៌ពីមាតាបិតា ។
ពេលនោះភ្លេងប្រគំ :
១-បទលោមនាង ឬ បទចាន់ទ្រលាំ
នៅពេលកាត់ខ័ន្ធស្លានិងជាវខ័ន្ធស្លា លោកមេបាត្រូវកាត់តម្លៃ : ឧទាហរណ៍ ៩ដំឡឹង ៥ស្លឹង២បាតប្រាក់ប្រាង្គប្រាសាទស្រគំស្រគាំដើមដៃ ហើយត្រូវមានបន្ថែមបង្គ្រប់ពីលើ ចំនួនទៀតដើម្បីជាកិច្ចបំពេញព្រលឹងកូនស្រីលោកមេបាផង ។

_កម្មវិធីទី១៤_ ពិធីទទួលយកពេលាភាសី
ដើម្បីទទួលយកពេលាភាសីឱ្យបានប្រកបដោយសុភមង្គលវិបុលសុខល្អប្រពៃពិតប្រាកដ នោះ លោកអាចារ្យត្រូវដេញស្មានហោរាសាស្ត្រទៅតាមឆ្នាំកំណើតរបស់កូនប្រុសនិងកូន ស្រីផ្សំគ្នាព្រោះពេលាភាសីនោះមានបីយ៉ាងគឺ :
១- ពេលាសព្វអប្សរ : នៅពេលម៉ោងបួនជិតភ្លឺ
២- ពេលាជាន់ឆាយ : ពេលព្រលឹមស្រាងៗ
៣- ពេលាពេញវង់ : ពេលព្រះអាទិត្យបំភ្លឺច្បាស់
តំបូងលោកអាចារ្យធ្វើកិច្ចនមស្សការព្រះរតនៈត្រ័យនៅកន្លែងរានទេវតាមុខផ្ទះ សូត្រប្រ កាសអញ្ជើញទេវតាបារមីព្រះអាទិត្យព្រះច័ន្ទបំភ្លឺទ្វីបលោក សូមព្រះអង្គប្រទានទូវរាសីនិង សិរីសួស្តីចំពោះកូនប្រុសស្រីទាំងពីរ ដែលបានរៀបចំមង្គលការថ្មីឱ្យទទួលនូវពរជ័យ សិរីសួស្តី ។ ពេលនោះភ្លេងប្រគំ :



www.elibraryofcambodia.org

១-បទផាត់ពពក ( សុំពន្លឺភសី )

*កម្មវិធីទី១៥* ពិធីដង្ហែកូនប្រុសឡើងសំពះផ្ទឹម

នៅពេលដង្ហែកូនប្រុសឡើងសំពះផ្ទឹម កាលណាឡើងដល់មាត់ទ្វារមុននឹងចូលទៅដល់កន្លែងផ្ទឹម ត្រូវឈប់បង្អង់ជាន់លើថ្មមួយដុំ ដែលគេដាក់នៅចំកណ្តាលមាត់ទ្វារនៃកាំជណ្តើរវង់ចាំកូនស្រីយកទឹកមកលាងជើងឱ្យ ។ លុះលាងជើងរួចហើយទើបកូនប្រុសឡើងសំពះផ្ទឹម ។ ភ្លេងត្រូវប្រគំ :

១-បទស្តេចយាង

*កម្មវិធីទី១៦* ពិធីកែផ្កាស្លា

ក្នុងពិធីកែផ្កាស្លានេះគឺជានិមិត្តរូបនៃការគោរពតបគុណអ្នកទាំងបី គឺ លោកឪពុកអ្នកម្តាយនិងរៀមច្បងបង្កើត ។ ដូច្នេះផ្កាស្លាទាំងបីនេះ កូនប្រុសត្រូវលើកជូនទៅលោកទាំងបី ដើម្បីជាកិច្ចតបស្នងសងគុណ ភ្លេងត្រូវប្រគុំ :

១-បទដំរីយោលដៃ

*កម្មវិធីទី១៧* ពិធីសំពះរួមឱ្នឹយ

ពេលនោះ លោកអាចារ្យក៏បានពីងពាក់អ្នកភ្លេងឱ្យឡើងរាំច្រៀងបើកវាំងននសុំកូនស្រីមកផ្ទឹមព្រោះពេលាល្អមកដល់ហើយ ។ ពេលនោះភ្លេងត្រូវប្រគំ :

១-បទផាត់ជាយ ( សុំបើកវាំងនន )

កាលណាកូនស្រីបានមកអង្គុយផ្ទឹមគ្នាហើយ លោកអាចារ្យក៏រៀបចំពិធីបង្វិលពពិល ។ ឯពិធីបង្វិលពពិលនេះ គេត្រូវរកអ្នកដែលមានគូស្រករ គ្រួសារប្តីប្រពន្ធណាដែលមិនបាក់បែកមែកធាងឱ្យមកអង្គុយជុំវិញសាម៉ីខ្លួនកូនប្រុសស្រីទាំងពីររួចហើយលោកអាចារ្យចាប់ផ្តើមសូត្រធម៌នមោគស្សៈ៣ចប់ ហើយសូត្រជយន្តោរហូតគ្រប់ជុំនៃពពិលនោះជា



www.elibraryofcambodia.org

កិច្ចប្រទាក់សិណអភិសេក ប្រសិទ្ធិពរជ័យចំពោះគូស្វាមីភរិយាថ្មី ជាថ្ងៃនក្ខត្តឫក្សល្អ ជាអរុណរះល្អ ជាមង្គលដ៏ល្អប្រកបដោយវាចាចិត្តដ៏ល្អជាមង្គលដ៏ល្អ។ ពេលនោះភ្លេងត្រូវប្រគំ :

២-បទធាតពន្លំ ( និមិត្តរូបចំណងគូជីវិតថ្មី )

៣-បទជុំព្រៃ ( រក្សាសាមគ្គីភាពគ្រួសារទាំងអស់ )

បន្ទាប់ពីពិធីបង្វិលពពិលរួចហើយ ត្រូវធ្វើពិធីរាំដាវសុំពរជ័យសិរីមង្គលកំចាត់មារសត្រូវគ្រប់ទិសទីជាកិច្ចតំឡើងរាសីនៃពិធីនេះ ពេលនោះភ្លេងត្រូវប្រគំ :

៤-បទផាត់ជាយ ( រាំដាវទទួលជ័យជំនះ )

បន្ទាប់ពីរាំដាវចប់ហើយ ត្រូវរាំបើកបាយព្រះស្រីឬរាំបើកទៀប ។ ឯទៀបមួយគូនេះជានិមិត្តរូបនៃទឹកដោះម្ដាយថ្ងៃ ដែលបានឱ្យអាយុជីវិតដល់រូបកូនទាំងពីរប្រកបដោយសុភមង្គលមកដល់ពេលនេះ ។ ពេលនោះភ្លេងត្រូវប្រគំ :

៥-បទអង្គរាជ ស្ដេចផ្ទំ ( បើកទៀប )

បន្ទាប់ពីបើកបាយព្រះស្រីរួចហើយនឹងមានធ្វើពិធីសំពះរួមខ្នើយ ឬពិធីចងដៃ ។ តាមធម្មតា គេឱ្យកូនប្រុសស្រីទាំងពីរនាក់អង្គុយយ៉ាងកៀកគ្នា ហើយសំពះលើខ្នើយរួមគ្នាតែមួយ ។ ពេលនោះលោកមេបានឺពុកម្ដាយបងប្អូនញាតិមិត្តចូលមកចងដៃឱ្យពរជ័យគ្រប់ៗគ្នា ។ ពេលនោះភ្លេងប្រគំ :

៦-បទបាយខុន : ពិធីចងដៃ

លុះពិធីចងដៃសព្វគ្រប់អស់ហើយ លោកអាចារ្យក៏ធ្វើការណែនាំអំពីសង្គហៈធម៌រវាងគូស្វាមីភរិយាថ្មី។ ប្រការចាំបាច់បំផុត គឺអ្នកទាំងពីរត្រូវមានធម៌សង្គ្រោះទៅវិញទៅមកយល់ចិត្តថ្នើមគ្នាទៅវិញទៅមកបើខឹងខំអត់ធ្មត់បើខ្សត់ខំរកស៊ីឡើងកុំក្បត់ចិត្តគ្នា ពិសេសត្រូវរក្សាភ្នក់ភ្លើងទាំងបីឱ្យបានល្អ ភ្នក់ភ្លើងទីមួយគឺមាតាបិតាបង្កើត ភ្នក់ភ្លើងទីពីរគឺមាតាបិតាក្មេក ភ្នក់ភ្លើងទីបីគឺខ្លួនឯងជាប្ដីប្រពន្ធថ្មីថ្មោងនេះឯង ចាប់ពីពេលនេះទៅត្រូវថែរក្សាគ្នាឱ្យបានសុខដុមរមនាអស់មួយជីវិតរៀងខ្លួន កុំបីឱ្យមានសៅហ្មងឡើយ ។



www.elibraryofcambodia.org

បន្ទាប់ពីលោកអាចារ្យប្រសិទ្ធិពរហើយកូនប្រុសស្រីទាំងពីរក៏ងើបឈរឡើង កូនប្រុសក៏ចាប់តោងជាយស្បៃរបស់កូនស្រីជាប់ អ្នកទាំងពីរក៏ធ្វើដំណើរទៅក្នុងបន្ទប់របស់កូនស្រី ដូចជំនាន់កាលស្តេចព្រះថោងតោងស្បៃនាងនាគចុះទៅឋានព្រះភុជង្គនាគដូច្នោះឯង ។

*កម្មវិធីទី ១៨* ពិធីសាកន្ទេល

បន្ទាប់ពីកូនប្រុសតោងជាយស្បៃកូនស្រីចូលទៅក្នុងបន្ទប់រួចហើយ បន្ទាប់នោះគូស្វាមីភរិយាថ្មីនេះត្រូវចេញក្រៅវិញមកអង្គុយត្រង់កន្លែងសំពះផ្ទឹម ដើម្បីរង់ចាំជាវកន្ទេលខ្នើយថ្មីទុកសំរាន្តទាំងពីរនាក់ប្តីប្រពន្ធ។ ជូនពេលនោះមាណពពីរនាក់ប្តីប្រពន្ធបានយកកន្ទេលមកលក់ឱ្យអ្នកដែលទើបនឹងរៀបការថ្មីនេះ ហើយបានធ្វើពិធីផ្សងថា បើគូស្វាមីភរិយាថ្មីនេះមានភ័ព្វវាសនាល្អមែន សូមសំរាន្តលើកន្ទេលនេះទៅកើតមាសកើតប្រាក់ដូចការផ្សងអធិដ្ឋាននេះផង។ពេលនោះលោកមេបាឪពុកម្តាយទាំងពីរក៏ធ្វើការពិសោធន៍ឱ្យអ្នកលក់កន្ទេលពីរនាក់ប្តីប្រពន្ធសំរាន្តលើកន្ទេលនោះ។លុះសំរាន្តលង់លក់មួយស្របក់ស្រាប់តែយល់សប្តិឃើញកើតមាសកើតប្រាក់ជាច្រើនត្រេកអរភ្ញាក់ឡើងឃើញមានមាសនិងប្រាក់ច្រើនដូចការផ្សងនេះពិតប្រាកដមែន ។ ឃើញជាក់ស្តែងដូច្នេះហើយ ទើបគូភរិយាថ្មីនេះសុំជាវយកកន្ទេលនេះទៅសំរាន្តទាំងពីរនាក់ប្តីប្រពន្ធតែម្តង ។ ពេលនោះអ្នកទាំងពីរក៏បីយកកន្ទេលនោះទៅក្នុងបន្ទប់របស់ខ្លួនយ៉ាងត្រេកអរបំផុត។ បន្ទាប់ពីទុកដាក់កន្ទេលខ្នើយរួចហើយ ឪពុកម្តាយកូនស្រីក៏នាំកូនទាំងពីរទៅកាន់រោងផ្កាស្លាខាងកូនប្រុសដើម្បីធ្វើពិធីចងដៃសំរេច និងសំពះលោកអាចារ្យព្រមទាំងគោរពសុំស្គាល់បងប្អូនសាច់ញាតិសណ្តានខាងកូនប្រុសចាប់ពីថ្ងៃនេះតទៅ ។

*កម្មវិធីទី ១៩* ពិធីផាន់រោងបញ្ចប់ពិធីមង្គលការ

ក្រោយពីគូស្វាមីភរិយាថ្មីបានជួបគ្នាក្នុងបន្ទប់កូនស្រីរួចហើយ បន្ទាប់មកឪពុកម្តាយខាងកូនស្រីក៏នាំសាមីខ្លួនទាំងពីរចុះទៅកាន់រោងផ្កាស្លា ដើម្បីគោរពសូមខមាលទោសចំពោះឪពុកម្តាយខាងកូនប្រុសនិងសុំស្គាល់រាប់អានបងប្អូនញាតិមិត្តសាច់សណ្តានខាងប្តី



www.elibraryofcambodia.org

របស់ខ្លួនចាប់តាំងពីពេលនេះតរៀងទៅ ។ ពេលនោះត្រូវធ្វើពិធីចងដៃបញ្ចប់ពិធីមង្គលការ ។ ភ្លេងត្រូវប្រគំ :

១-បទបាយខុនចងដៃ ( បញ្ចប់ពិធីមង្គលការ )

*គ- វង់តន្ត្រីគងស្គរ ឬ ទាំម្ពង*

តាមការស្រាវជ្រាវនៅតាមប្រាសាទបុរាណនានាដូចជាប្រាសាទបាគង-បាយ័ន អង្គរតូច និងប្រាសាទប្រែរូបជាដើម គេឃើញមានរូបចំលាក់ឧបករណ៍តន្ត្រីបុរាណមួយចំនួន ដូចជាឧបករណ៍ ពិណ ខ្សែដៀវ ចាប៉ីដងវែង គង ស្គរ និងឧបករណ៍ផ្លុំ ។ រកឃើញដោយលោកហ្សាក សេដែស ជនជាតិបារាំង ។ ឯឧបករណ៍ពិណចេញមកពីប្រទេសឥណ្ឌានៅស.វទី១នៃគ.ស ក្រៅពីនោះជាឧបករណ៍របស់ខ្មែរ។ គេបានសន្និដ្ឋានថា វង់ភ្លេងនេះមានកំណើតនៅ ស.វទី២ស.វទី៣នៃគ.ស ។ ក្រោយមកគេបានភ្ជាក់ទុកជាសក្ខីភាពឧបករណ៍តន្ត្រីក្នុងវង់តន្ត្រីគងស្គរឬទាំម្ពងនេះមាន ៤មុខគឺ :

១-ស្គរធំ ឬស្គរយាម (មានទំហំ៦០ស.ម បណ្ដោយប្រវែង៩០ស.ម ពាសអំពីស្បែកក្របី ) ។

២-គងរងោះធំពីរ (មានគងមេនិងគងកូន។ គងមេមានទំហំ៦០ស.ម គងកូនមានទំហំ៥០ស.ម ) ។

៣-គងវង់មានផ្លែចំនួន៩ ( មានរូបភាពដូចជាគងវង់ពិណពាទ្យដែរ ) ។

៤-ស្រឡៃធាង (ធ្វើអំពីឈើខ្ទឹមរាងភរកំពោងខាងចុង ចងបង្គុំជុំវិញមានរន្ធចំនួន៧)។

វង់តន្ត្រីនេះសព្វថ្ងៃប្រជាជនយើងបានថែរក្សាប្រើប្រាស់ជាប្រពៃណីទំនៀមទំលាប់ នៅភូមិភាគពាយព្យខេត្តសៀមរាប បាត់ដំបងនិងពោធិសាត់សំរាប់ប្រគំក្នុងពិធីបុណ្យប្រពៃណីសាសនានិងសំរាប់ប្រគំកំដរបុណ្យសព។ជាពិសេសនៅតាមភូមិស្រុកឆ្ងាយៗ គេត្រូវប្រគំកំដរហ្លួតដើម្បីឱ្យអ្នករស់នៅក្នុងភូមិទាំងអស់បានដឹងនិងជួយរួមកាន់មរណៈទុក្ខ ។



www.elibraryofcambodia.org

*ការវិភាគពិចារណានូវសំនៀងឧបករណ៍នីមួយៗ*

ក-សំនៀងឧបករណ៍ស្រឡៃឆាង : នៅពេលប្រគំ គេផ្លុំឡើងសូរសំនៀងវែងគ្រលួចលន្លង់លន្លោច អាណោចអាធម្មបង្ហាញនូវមនោសញ្ចេតនារម្មណ៍នៃវិញ្ញាណខ័ន្ធ មានការអាឡោះអាល័យយ៉ាងខ្លាំងមុននឹងចាកចោលរូបចាស់អន្ទោលរកចាប់ភពថ្មីទៀត ។
ខ-សំនៀងឧបករណ៍គងវង់តូចមានផ្លែ ៩ : កាលណាគេប្រគំឡើង សូរសំនៀង តិង តង់ តិកតក់ៗ សូរដូចជាដំណក់ទឹកភ្លៀងមួយតំណក់ៗធ្លាក់មកលើស្លឹកឈើឬមកលើព្រះធរណីប្រៀបបាននឹងជីវិតមនុស្ស ដែលកើតមកហើយតែងតែប៉ះទង្គិចនូវសេចក្តីសុខឬសេចក្តីទុក្ខជាធម្មតា តាមកម្មនិងផលជាអ្នកកំណត់ឱ្យរៀងៗខ្លួន។
គ-សំនៀងឧបករណ៍គងរោះធំពីរ : កាលណាគេប្រគុំវាយឡើង សូរសំនៀងម៉ឹងម៉ូងៗឆ្លើយឆ្លងពួសូរដូចផ្គលាន់នៅលើមេឃឬអាកាស ធ្វើឱ្យដើមទ្រូងណែនស្មើរប្រេះ គិតពីបញ្ហាជីវិតរបស់ខ្លួន ដែលមានភាពមិនស្ថិតស្ថេរឬទៀងទាត់ឡើយ ។
ឃ-សំនៀងឧបករណ៍ស្គរយោម : ឧបករណ៍ស្គរយោមនេះគេប្រគំមួយៗ សំរាប់ផ្តាច់សង្វាក់ក្នុងឃ្លានៃបទនិមួយៗពួសូរសំនៀងធ្លងត្រាំៗ ដូចជាស្គររន្ទះវាយផ្ទុំពពកបំបែកខ្ចាយធ្លាក់មកជាទឹកភ្លៀង បីដូចជានៅពេលមច្ចុរាជមកផ្តាច់អាយុសង្ខារធាតុទាំងបួនបែកចេញពីគ្នាវិញ្ញាណខ័ន្ធចុះចោលរូបកាយ រូបកាយក៏ក្លាយទៅជាអសុពដេកស្តូកស្តឹងប្រៀបបាននឹងអង្កត់ឧសរកប្រយោជន៍គ្មាន ។

ឃ- *វង់តន្ត្រីខ្លងឆ្នាក់ ( ស្គរយោល ឬស្គរឈ្មះ )*

វង់តន្ត្រីស្គរយោលនេះ មានកំណើតប្រហាក់ប្រហែលជាមួយនឹងវង់តន្ត្រីគងស្គរឬទាំម្ហូងនេះដែរ ។ វង់តន្ត្រីនេះមានមុខងារសំខាន់គឺសំរាប់បំរើនៅក្នុងពិធីប្រដាល់និងប្រគុំដង្ហែរសពទៅបញ្ចុះឬបូជាតែប៉ុណ្ណោះ ។ ឧបករណ៍ក្នុងវង់តន្ត្រីស្គរយោលនេះ មានចំនួន ៣ មុខគឺ :

១-ស្រឡៃឆាង



www.elibraryofcambodia.org

២-ស្គរមុខពីរ ឬ សាំងណា

៣-ស្គរយោល (សំរាប់វាយផ្ចាច់សង្វាក់)

*ការវិភាគពិចារណានូវសំនៀងឧបករណ៍និមួយៗ*

លក្ខណៈនិងទឹកដមនៃបទភ្លេងក្នុងវង់នេះ នៅពេលប្រគុំបន្ទឺឡើងសំនៀងស្រឡៃ ឮស្គរខ្លាំងវែងគ្រលួចសែនឆ្ងាយគួរឱ្យសង្វេគអាណោចអធម្មពន់ប្រមាណ។ បានបញ្ជាក់ច្បាស់ពីការកើត ចាស់ ឈឺ ស្លាប់ ស្ថិតក្នុងវង្វង់អនិច្ចតាធម៌គឺ : រូបំ ទុក្ខំ អនិច្ចំ អនត្តា តែមានរូបតែងមានទុក្ខ។ រូបនេះមិនទៀងទាត់តែងប្រែប្រួលជានិច្ចមិនស្ថិតស្ថេរយឺនយូរព្រោះមិនមែនជារបស់ខ្លួនឡើយ ទីអវសានត្រូវផុតរលត់អស់ទៅនៃជីវិតនេះមិនខាន ។

៥- *វង់តន្ត្រីវាទ្យភណ្ឌ ឬ ពាទ្យភណ្ឌតន្ត្រី ឬ ពិណពាទ្យ*

ការស្រាវជ្រាវនៅតាមសិលាចារឹកជាអក្សរសំស្ក្រឹតមានពាក្យថា វាទ្យភណ្ឌតន្ត្រីនិងពាទ្យភណ្ឌតន្ត្រី រកឃើញដោយលោក ហ្សក សេដែស ជនជាតិបារាំង ។ ពាក្យនេះមានន័យថាវង់តន្ត្រីមួយដែលមានឧបករណ៍៥មុខដូចនេះគេបានសន្មត់ថាជាវង់តន្ត្រីពិណពាទ្យវង់តូចដែលមានគ្នាចំនួន៥នាក់ជាអ្នកសំដែងនេះឯង ។ គេបានសន្និដ្ឋានវង់តន្ត្រីនេះថាមានកំណើតបន្ទាប់ពីវង់តន្ត្រីស្គរយោល ឬ ខ្លងឆ្នាក់ដែរ ។ ឧបករណ៍តន្ត្រីក្នុងវង់នេះមាន :

១-ស្គរធំពីរ . ២-សំភោរ . ៣-ស្រឡៃ . ៤-រនាតឯក . ៥-គងវង់ធំ (មានផ្លែ ១៦ឬ១៧) ។

តន្ត្រីពិណពាទ្យវង់តូចនេះគេបានប្រើប្រាស់តាំងពីសម័យនោះមកទល់សព្វថ្ងៃនេះផង ។ ភារកិច្ចសំខាន់នៃវង់តន្ត្រីនេះ សំរាប់ប្រគុំកំដរក្នុងពិធីបុណ្យប្រពៃណីជាតិ ប្រពៃណីព្រះពុទ្ធសាសនា កំដរក្នុងរបាំបុរាណ ល្ខោនបុរាណ ពិធីបួងសួងសំពះគ្រូធំ-តូច ឬកំដរក្នុងពិធីបុណ្យសព ។ល។



www.elibraryofcambodia.org

*ការវិវត្តន៍នៃឧបករណ៍និងវង់តន្ត្រីពិណពាទ្យ*

បន្ទាប់ពីស.វទី៣ចំណេរក្រោយមក អ្នកឯកទេសខាងជាតិពន្ធុតន្ត្រីវិទ្យា គេមានទេព កោសល្យធ្វើការស្រាវជ្រាវនូវប្រពន្ធ័នៃសំនៀង និងប្រពន្ធ័នៃឧបករណ៍តន្ត្រីដែលមាន ពាក់ពន្ធ័ធ្វើឱ្យថាមពលនៃសំនៀងតន្ត្រីឱ្យមានសុក្រិតភាពពេញលេញ។ គេរកឃើញនិង កែច្នៃបង្កើតបាននូវឧបករណ៍គោះដំមួយចំនួនទៀត ដូចជាឧបករណ៍ : រនាតថុង រនាតដែក រនាតថោងថុង គងវង់តូច(មានផ្លែចំនួន១៦ដូចគងវង់ធំដែរ)និងស្រឡៃតូច ឬស្រឡៃណាក ។ ឧបករណ៍ដែលគេរកឃើញក្រោយទាំងប៉ុន្មាននេះ គេបានបញ្ចូលទៅ ក្នុងវង់តន្ត្រីពិណពាទ្យវង់តូចនេះទៀតធ្វើឱ្យសំនៀងមានសុក្រិតភាពស្ទាហាប់ ពិរោះរណ្តំ លើសពីសំនៀងវង់តន្ត្រីពិណពាទ្យពីមុន ។ ក្រោយមកគេឱ្យឈ្មោះថា :

១-វង់តន្ត្រីពិណពាទ្យវង់តូច មានគ្នាចំនួន ៥ នាក់

២-វង់តន្ត្រីពិណពាទ្យវង់ធំ មានគ្នាចំនួន ១១ នាក់

ឧបករណ៍តន្ត្រីពិណពាទ្យវង់ធំនេះមាន :

១-ស្គរធំពីរ ២-សំភោរ ៣-រនាតឯក ៤-រនាតថុង ៥-រនាតដែក ៦-រនាតថោងថុង ៧-គងវង់ធំ ៨-គងវង់តូច ៩-ស្រឡៃធំ ១០-ស្រឡៃតូច ១១-ឈឹង ។

តន្ត្រីពិណពាទ្យវង់ធំនេះ នៅពេលប្រគំម្តងឮស្នូរសំនៀងខ្លាំងស្រួយពិរោះរណ្តំ ប្រកប ដោយឯកទេសនិងទេពកោសល្យខ្ពស់នៃអ្នកនិពន្ធជំនាន់ដើម។ ក្នុងបទភ្លេងនិមួយៗមាន លក្ខណៈស្ទាហាប់គួរឱ្យចាប់អារម្មណ៍ពិចង្វាក់និងសាច់បទ ។ តួនាទីរបស់វង់តន្ត្រីនេះពី ជំនាន់ដើមគឺ :

១-សំរាប់ប្រគំអបអរសាទរទទួលក្បួនទព័ ដែលត្រឡប់ចូលព្រះនគរវិញក្រោយពីបាន ច្បាំងរួចហើយទទួលបានជ័យជំនះ ។

២-សំរាប់ប្រគំកំដរក្នុងពិធីបុណ្យប្រពៃណីជាតិទ្វាទសមាស ព្រះរាជពិធីបួងសួង ព្រះ រាជពិធីតាំងតុ ព្រះរាជពិធីអុំទូក-អកអំបុក-សំពះព្រះខែ ព្រះរាជពិធីចុះដែ ព្រះរាជ



www.elibraryofcambodia.org

ពិធីច្រត់ព្រះនង្គ័ល ។ល។

៣-ផ្នែកប្រពៃណីព្រះពុទ្ធសាសនាតី : ប្រគំកំដរពិធីបុណ្យភ្ជុំបិណ្ឌ បុណ្យកឋិន បុណ្យផ្កា បុណ្យបញ្ចុះសីមាស្រង់ព្រះ កំដរបុណ្យខ្មោច ។ល។

៤-សំរាប់ប្រគំកំដរជាមួយរបាំបុរាណ ដូចជា : របាំជូនពរ របាំទេពមនោរម្យ របាំអប្សរា របាំមនីមេខលា របាំសុវណ្ណមច្ឆា ។ល។ និងប្រគំកំដរជាមួយល្ខោនបុរាណ ដូចជា : ល្ខោនខោល ល្ខោនស្រមោលស្បែកធំ ស្បែកតូចអាយ៉ង ល្ខោនពាក់មុខ និងល្ខោនបុរាណរឿងរាមកេរ្តិ៍ជាដើម។ល។ ជួនកាលវង់ភ្លេងនេះ អាចចូលប្រគំក្នុងពិធីបុណ្យឡើងអ្នកតាបួងសួងបន់ស្រន់សូមឱ្យប្រទេសយើងបានសុខសន្តិភាព មានទឹកភ្លៀងបង្អុរចុះបរិបូណ៌ ឱ្យប្រជាកសិករប្រកបរបរកសិកម្មផ្សេងៗបានផលល្អនុផលពេញលេញ ជីវភាពធូរធារសំបូរសប្បាយកុំឱ្យមានរោគាពាធិជំងឺដង្កាត់អ្វីឡើយ។ មុខងារចាំបាច់បំផុតរបស់វង់តន្ត្រីនេះគឺផ្សារភ្ជាប់នឹងពិធីសំពះគ្រូតូចនិងគ្រូធំ ។

<u>សំណូមពរចាំបាច់</u>

រយៈពេលជាយូរឆ្នាំមកហើយដែលយើងទាំងអស់គ្នាបានឮផ្ទាល់នឹងត្រចៀកគ្រប់មជ្ឈដ្ឋានទូទាំងប្រទេសបងប្អូនខ្មែរយើងទាំងអស់ក្មេងចាស់ប្រុសស្រី ភាគច្រើនបានសំគាល់ថា ភ្លេងពិណពាទ្យនេះជាភ្លេងសៀមហើយនិយាយតាមគ្នារអិលមាត់ហៅថា ភ្លេងសៀមៗតែម្តងដោយមិនបានគិតពិចារណាវែងឆ្ងាយ។ គួរពិនិត្យមើលតើជារបស់សៀមមែន ឬជារបស់ខ្មែរយើង ? ដើម្បីជាភស្តុតាងពិតប្រាកដសូមបងប្អូនមើលរូបចំលាក់សិលាចារឹកមាននៅតាមថែវប្រាសាទបូរាណរបស់ខ្មែរយើង សម្រាប់ទុកជាសក្ខីភាពចំពោះពង្សសាវតាខ្មែរ ។ នេះជាសម្បត្តិវប្បធម៌ជាតិខ្មែរយើងពិតប្រាកដ ជាស្នាដៃនិងទេពកោសល្យនៃបុព្វបុរសយើង ដែលបានប្រតិស្ឋានទុកឱ្យកូនចៅជំនាន់ក្រោយៗបានឃើញច្បាស់គ្រប់គ្នា ។ ជាការចាំបាច់សូមបងប្អូនហៅថាភ្លេងពិណពាទ្យវិញទើបត្រឹមត្រូវ ។



www.elibraryofcambodia.org

### ឆ- *វង់តន្ត្រីមហោរី*

បន្ទាប់ពីវង់ភ្លេងនេះទៅ សូមបង្ហាញជូនវង់ភ្លេងមួយទៀតហៅថា វង់តន្ត្រីមហោរី ។ ប្រទេសកម្ពុជាយើងគេស្គាល់វង់តន្ត្រីមហោរីជាវង់តន្ត្រីគ្រឿងខ្សែ ប៉ុន្តែមានលាយឡំជាមួយឧបករណ៍គោះដំមួយចំនួនតូច ។ ពិនិត្យជាក់ស្តែង ឧបករណ៍ក្នុងវង់តន្ត្រីនេះមួយចំនួនធំចេញមកពីវង់ភ្លេងការ មួយចំនួនទៀតចេញមកពីវង់ភ្លេងពិណពាទ្យបញ្ចូលជាមួយគ្នា គេសន្មត់ថាវង់ភ្លេងមហោរីប៉ុណ្ណោះ ។ ប្រភពនៃពាក្យដែលហៅថាមហោរី គឺចេញមកពីពាក្យសំស្ក្រឹត ។ សំស្ក្រឹតហៅថាមនោហរមនោហរី ជាវង់ភ្លេងមួយដែលមានឧបករណ៍ច្រើនមុខ ប្រគំដោយបុរសនិងនារីមានឡបចម្លាក់នៅតាមថែវអង្គរអ្នកប្រគំភ្លេងមនោហរមនោហរីនេះ នៅពេលប្រគំមានរហូតដល់គេបាំងក្បោះឱ្យផងក៏មាន ។ ជាក់ស្តែងនៃការស្រាវជ្រាវនូវពាក្យសំស្ក្រឹតមនោហរមនោហរី មានសិលាចារឹកនៅប្រាសាទប្រែរូបសតវត្សទី៩និងនៅលើផ្ទាំងសិលាចារឹកមួយទៀតទាសតវត្សទី១០ ដែលលោកហ្សឺក សេដែស ជនជាតិបារាំងបានសិក្សាស្រាវជ្រាវរកឃើញពាក្យ មនោហរមនោហរីនេះបានក្លាយទៅជាមហោរីមកដល់សព្វថ្ងៃនេះតែម្តង ។ វង់តន្ត្រីមហោរីនេះចំនេរក្រោយមកមានការរីកចំរើនកាន់តែល្បីសុះសាយឡើងអ្នកប្រគំវង់ភ្លេងនេះមានសុទ្ធតែនារីៗផង ។

*លក្ខណៈពិសេសនៃវង់ភ្លេងមហោរី*

ភ្លេងមហោរីជាវង់ភ្លេងមួយមានក្បួនខ្នាតជាក់លាក់ច្បាស់លាស់ទាំងសាច់បទទាំងចង្វាក់ទាំងសំនៀង ទាំងពាក្យពេជន៍នៃចំរៀង ប្រកបដោយកំណាព្យកាព្យជូនរស់រវើកយ៉ាងប្រណិត ។ សំឡេងនិងសំនៀងស្រទន់រំភើប លន្លង់លន្លោច អណ្តែតគ្រលួច មូលក្រអួន។ ស្តាប់ទៅច្រើនលើកពីអ្វីៗពិតនៅក្នុងខ្លួនមនុស្ស ទៅអ្វីដែលមើលឃើញច្បាស់នឹងភ្នែកមានការប្រៀបធៀបទៅនឹងឧបមាណវិធី មានការសរសើរពីធម្មជាតិ ពីមេឃពីផ្កាយ ពីព្រះចន្ទ ពីបារមី ពីព្រះទ័យសន្តោសនៃព្រះមហាក្សត្រ ពីមន្ត្រី ពីសំរស់នារី ពីខ្យល់បក់ពីព្រៃព្រឹក្សា ៉ពីមច្ឆាជាតិពីទឹករលកពពករសាត់។ល។ ដែលអាចទាញ



www.elibraryofcambodia.org

នូវមនោសញ្ចេតនារម្មណ៍ឱ្យអណ្តែតអណ្តូង ស្រមើស្រមៃក្នុងក្តីសង្ឃឹមឱ្យមកបំរើនូវជីវិតពិតឱ្យសុខផ្លូវកាយផ្លូវចិត្ត ឬអាចបែរឆ្ពោះទៅរកភាពត្រេកត្រអាលនិងកាមគុណផង ។ ព្រោះអ្នកប្រគុំឬសំដែងក្នុងវង់ភ្លេងនេះ សុទ្ធតែមានសមត្ថភាពកំរិតខ្ពស់ ឯអ្នកនិយមចូលចិត្តស្តាប់វិញក៏សុទ្ធតែមានការចេះដឹងជ្រៅជ្រះ។ តន្ត្រីមហោរីនេះមិនទាមទារតែទៅលើភ្នែកឬត្រចៀកប៉ុណ្ណោះទេ គឺទាមទារទៅលើខួរក្បាលពោរពេញទៅដោយចំណេះគ្រប់បែបយ៉ាង ។

<u>ការវិភាគ</u> :

ពេលណាគេកំពុងស្តាប់ឬក្រោយពីពេលស្តាប់ភ្លេងនេះ ធ្វើឱ្យអារម្មណ៍របស់គេនឹកមមៃបន្តមិនចេះចប់ពិរោះប្រាកដជាពិរោះ ពិរោះនូវសោភណ៍របស់បទនិមួយៗបង្ហាញជាក់ស្តែងច្បាស់ពីលក្ខណៈបច្ចេកទេសនៃឧបករណ៍និមួយៗ ដែលកំពុងប្រគុំមានពាក់ពន្ធ័រវាងផ្លូវឧបករណ៍និងទេពកោសល្យ ទឹកដៃបញ្ជារឧបករណ៍ ។ ឧបករណ៍ខ្លះជាអ្នកហៅ ឧបករណ៍ខ្លះជាអ្នកឆ្លើយខ័ន្ត ឃ្លាវែងម្នាក់ម្តង ខ័ន្តឃ្លាខ្លីម្នាក់ម្តង ខ័ន្តផ្លាស់ប្តូរ ខ័ន្តប្រដេញ ខ័ន្តជាន់ដានបន្ទីឧបករណ៍និមួយៗឬដៀវប្រើសុទ្ធតែទេពកោសល្យដ៏ប៉ិនប្រសព្វរបស់តន្ត្រីករម្នាក់ៗ ធ្វើឱ្យបទនិមួយៗមានគុណធម៌និងខ្លឹមសារល្អប្រពៃ។ ចំណោមអ្នកស្តាប់ទាំងឡាយតែងមានស្មារតីត្រិះរិះពិចារណានឹកឃើញទៅដល់បុព្វបុរសរបស់ខ្លួនដែលស្ថាបនានូវមហាសមិទ្ធិជាអច្ឆរិយវត្ថុដ៏មានតំលៃទុកជាគ្រឹះ និងជាក្បួនខ្នាតឱ្យកូនចៅជំនាន់ក្រោយព្រមទាំងបានបង្ហាញពីនិស្ស័យរបស់ខ្មែរជំនាន់នោះ ដែលធ្លាប់មានវប្បធម៌និងអរិយធម៌ខ្ពង់ខ្ពស់ ធ្លាប់មានទំនាក់ទំនងផ្នែកវប្បធម៌ជាមួយនឹងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ ដូចមានចារនៅក្នុងឈ្មោះបទភ្លេងមួយចំនួនជាអាទិ៍ ដូចបទអំបូរមន អំបូរជ្វា អំបូរចិន អំបូរក្លឹង អំបូរភូមា អំបូរលាវ ។ល។ ក្រៅពីនេះមានការទំនាក់ទំនងនៅក្រៅប្រទេសឆ្ងាយទៀត ដូចជាប្រទេសបារាំង និងជប៉ុនជាដើម ។



www.elibraryofcambodia.org

__ភារកិច្ចវង់តន្ត្រីមហោរី__

វង់តន្ត្រីមហោរីមានភារកិច្ចដូចតទៅ ៖

១-សំរាប់ប្រគំបំពីក្នុងវង់ល្ខោនមហោរី

២-សំរាប់ប្រគំអបអរសាទរគោរពក្នុងព្រះរាជពិធីបួងសួងពិធីបុះ ផែអកអំបុកសំពះព្រះខែ ឬពិធីជប់លៀងទទួលភ្ញៀវរដ្ឋ និងសំរាប់ប្រគំកំដរក្នុងវង់ល្ខោនគែនផង ។

ឈ្មោះឧបករណ៍តន្ត្រីមហោរីមាន ៖

| | |
|---|---|
| ១-រនាតឯក | ៧-ទ្រអ៊ូធំ |
| ២-រនាតធុង | ៨-ក្រពើឯក |
| ៣-រនាតថោងធុង | ៩-ក្រពើ |
| ៤-ទ្រសោ | ១០-ខ្លុយតូច |
| ៥-ទ្រជេ | ១១-ខ្លុយធំ |
| ៦-ទ្រអ៊ូ | ១២-ថូនរមនា |

១៣-ឈឹង និងអ្នកចំរៀងមួយចំនួនទៀត ។

__ការពិនិត្យ__ ៖

ជាទូទៅវង់តន្ត្រីនេះ ជាវង់ភ្លេងអ្នកប្រាជ្ញ ។ មានប្រភពកើតឡើងពីក្នុងបរមរាជវាំង អ្នកប្រាជ្ញជុំវិញស្តេចជាអ្នករួមចំណែកបង្កើតឡើង ។ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា វង់ភ្លេងនេះមិនសូវសំបូរណាស់ណាទេ ។ មានច្រើននៅក្នុងរាជធានី ទីរួមខេត្ត ស្រុក ឃុំមានមួយៗប៉ុន្តែទីកដៃសំដែងនៅមានកំរិតនៅឡើយ ដោយឡែកមាននៅតាមដំណាក់ព្រះអង្គម្ចាស់ ផ្ទះមន្ត្រីធំៗ មានមេទព័ជាដើម ។ ឯប្រជារាស្ត្រមានតិចបំផុត ។ បន្ទាប់ពីវង់ភ្លេងមហោរីនេះ សូមជូនវង់តន្ត្រីមួយទៀតគឺវង់មហោរីផ្លេ ។



www.elibraryofcambodia.org

ឆ -វង់តន្ត្រីមហោរីច្នៃ

វង់ភ្លេងនេះ គេប្រើឧបករណ៍សំលេងស្រាល ក្នុងនេះមានឧបករណ៍តន្ត្រីបុរាណមួយចំនួនបញ្ចូលជាមួយនឹងឧបករណ៍តន្ត្រីសាកលផង ។ ឧបករណ៍តន្ត្រីបុរាណមាន :ទ្រអ៊ូ ខ្លុយតូច ខ្លុយធំ ស្គរថូនរមនានិងឈឹង ។ ផ្នែកឧបករណ៍សាកលមាន : វិយោឡុង ហ្វ្លឹតាសាំ បង់ហ្សោ បង់ហ្សោអាល់តូ អាម៉្លីនីញ៉ូមតូច អាម៉្លីនីញ៉ូមធំ អ៊ុងទីវ និងអ្នកច្រៀង។ ឧបករណ៍ទាំងពីរផ្នែកបញ្ចូលគ្នានេះ គេសន្មត់ឱ្យឈ្មោះថា វង់ភ្លេងមហោរីច្នៃ គឺច្នៃឧបករណ៍បញ្ចូលគ្នាតែប៉ុណ្ណោះ ឯបទភ្លេងនិងចំរៀងនៅដដែល វង់ភ្លេងមហោរីច្នៃនេះមានកំណើតចេញមកពីបរមរាជវាំងដូចជាវង់ភ្លេងមហោរីសុទ្ធដែរព្រោះសមាសភាពតន្ត្រីករ ក៏ជាអ្នកមានសមត្ថភាពនិងទេពកោសល្យខ្ពស់ ។

ការវិភាគ :

សូរសំនៀងទឹកដមនៃបទភ្លេងនិមួយៗកាលណាគេប្រគុំឡើង សូរសំឡេងបែបទន់ភ្លន់ពីរោះផ្អែមល្ហែមប្រៀបបាននឹងនារីភេទម្នាក់ ដែលមានរូបរាងស្រស់ប្រិមប្រិយគ្រប់លក្ខណ៍គួរចាប់ចិត្តចេតនា និងគួរឱ្យចង់ស្តាប់នូវសំនៀងនោះផង ។

ភារកិច្ចវង់តន្ត្រីមហោរីច្នៃ

ភារកិច្ចនៃវង់មហោរីច្នៃនេះ សំរាប់ប្រគុំកំដរក្នុងពិធីបុណ្យជាតិផ្សេងៗ ឬប្រគុំកំដរបរិយាកាសក្នុងពិធីជប់លៀង ដោយឡែកសំរាប់បំរើក្នុងវង់ល្ខោនព្រាមោទ្យតែម្តង ។ ក្រៅពីនេះសំរាប់ប្រគុំ លេងកំសាន្តនៅពេលណាក៏បាន ។

បន្ទាប់ពីវង់តន្ត្រីមហោរីច្នៃនេះ ទៅសូមបង្ហាញជូននូវវង់ភ្លេងមួយទៀតដែលសំរាប់ប្រគុំបំរើក្នុងវង់ល្ខោនយីកេ ។



www.elibraryofcambodia.org

.៨ -វង់តន្ត្រីយីកេ

វង់ភ្លេងយីកេនេះ ជាទំរង់ភ្លេងមួយមានលក្ខណៈជាភ្លេងបូរាណ ហើយមានប្រជាប្រិយភាពក្នុងចំណោមប្រជាជនទូទៅដែលនិយមចូលចិត្តទស្សនាផង ។ តាមការស្រាវជ្រាវវង់ភ្លេងយីកេនេះ ប្រភពដើមមកពីប្រទេសម៉ាឡេ ប្រទេសចាម ។ សម័យនោះ ប្រទេសខ្មែរនិងប្រទេសចាមមានការទាក់ទងគ្នាជាមិត្តភាពផ្នែកវិស័យនយោបាយ សេដ្ឋកិច្ចនិងវប្បធម៌តាមរយៈគណៈប្រតិភូជាផ្លូវរដ្ឋ ចូលមកប្រទេសកម្ពុជាយើងនៅឆ្នាំ ១៨៧៦ ក្រោមរជ្ជកាលសម្តេចព្រះនរោត្តម ។ ចាប់តាំងពីជំនាន់នោះមក សិល្បៈយីកេបានទទួល និងថែរក្សារហូតមកដល់សព្វថ្ងៃនេះ ។ ឧបករណ៍ក្នុងវង់តន្ត្រីយីកេនេះពីជំនាន់នោះ មានតែស្គរមួយមុខតែប៉ុណ្ណោះ ។ ឯស្គរនោះមានចាប់ត្រឹមចំនួន៣រហូតដល់១៣ ។ ជនជាតិម៉ាឡេគេបានចាត់ទុកឧបករណ៍ស្គរយីកេនោះជាគ្រឿងសក្ការៈបូជាចំពោះព្រះអាឡា។ គេច្រើនប្រគំនៅក្នុងព្រះវិហារឬបុណ្យប្រពៃណីជាតិម៉ាឡេជាដើម ។ នៅពេលប្រគំមានសូត្រធម៌លោកអាចារ្យឬលោកសង្ក្រាចវត្ត ចាប់ផ្តើមសូត្រធម៌នាំមុខទើបទាំងអស់សូត្រតាមព្រមគ្នាជាមួយនិងស្គរចំនួន៣ចប់ ទើបគេប្រែបទផ្សេងៗទៀតរហូតដល់ចប់ពិធីតែម្តង ។

ការពិនិត្យវង់តន្ត្រីយីកេ

វង់ភ្លេងយីកេនេះជាទំរង់សិល្បៈមួយបែប ដែលមានលក្ខណៈខុសប្លែកពីសិល្បៈប្រជាប្រិយ។ ក្បាច់រាំនិងក្បាច់សំដែងឬកាយវិការរបស់តួសំដែងនីមួយៗ មួយចំនួនចេញមកពីក្បាច់បាតនៃរបាំបុរាណនិងល្ខោនបុរាណ ។ វង់សិល្បៈយីកេនេះ មានលទ្ធភាពក្នុងការសំដែងរឿងបុរាណដូចជា : រឿងព្រះជិនវង្ស រឿងទិព្វសង្វារ រឿងចៅស្រទបចេក រឿងម៉ាក់ថឺង រឿងទុំទាវនិងរឿងដទៃទៀតជាច្រើន ។ល។ ជំនាន់ពីមុនមកមានការលំបាកបន្តិចបន្តួចក្នុងពេលច្រៀងរួមគ្នាម្តងៗ ។ ការអបសំឡេងគ្នា មិនសូវបានមួយរយភាគរយ មានតឹង ធូរ លើសគ្នាបន្តិចបន្តួច ប៉ុន្តែនៅពេលក្រោយមកគេបានបន្ថែម



www.elibraryofcambodia.org

ឧបករណ៍ទ្រអ៊ូមួយ ដោយយកសំឡេងទ្រអ៊ូនេះធ្វើជាខ្នាតនៃសំនៀងមុននឹងច្រៀង ។ ទ្រអ៊ូត្រូវនាំមុខទើបអ្នកច្រៀងៗតាម ដូច្នេះសំនៀងភ្លេងនិងច្រៀងវេញចូលគ្នា ធ្វើឱ្យពិរោះល្អប្រពៃ។ចំណេរក្រោយមកទៀតអ្នកឯកទេសក្នុងវង់យីកេនេះ គេចង់ធ្វើឱ្យសិល្បៈល្ខោនយីកេនេះ មានសកម្មភាពស្វាហាប់ក្នុងការបំរើតួនិមួយៗមានប្រសិទ្ធិភាពនិងមានសោភ័ណភាពល្អគេបានបន្ថែមឧបករណ៍តន្ត្រីមួយមុខទៀតគឺឧបករណ៍ស្រឡៃជាការគ្រប់គ្រាន់ដើម្បីបំរើនូវតួសំដែងដែលមានរឹទ្ធិខ្លាំងពូកែដូចជាតួយក្ស តួហនុមាន តួស្តេចមានប្រើសិលវេទមន្ត ហោះហើរ ជ្រែកទឹកដី ប្រយុទ្ធយ៉ាងខ្លាំងក្លា ដូច្នេះប្រើឧបករណ៍ទាំងអស់នេះមានប្រសិទ្ធិភាពល្អប្រាកដមែន ។ ប៉ុន្តែនៅតាមមូលដ្ឋាននានា វង់ល្ខោនយីកេច្រើនមានតែឧបករណ៍ស្គរ ទ្រអ៊ូនិងក្រាបប៉ុណ្ណោះ មិនសូវមានស្រឡៃទេ ពីព្រោះមិនសូវមានអ្នកចេះផ្លុំ ។ ឯអ្នកចេះផ្លុំច្រើនចេញមកពីវង់ភ្លេងពិណពាទ្យ ។ ទម្រង់ល្ខោនយីកេនេះតាំងពីក្បាច់រាំការសំដែងសំលៀកបំពាក់ ឧបករណ៍ភ្លេងនិងចំរៀងរាល់ឯកទេសទាំងប៉ុន្មានបានសម្របសម្រួលក្លាយមកជាយីកេខ្មែរទៅហើយ ប្រជាជនខ្មែរបានទទួលនិងថែរក្សាទុកក្នុងបេះដូងរបស់គេគ្រប់ៗរូបដែរ ។
បន្ទាប់នៅនេះ សូមបង្ហាញជូននូវវង់តន្ត្រីមួយទៀត ដែលសំរាប់បំរើនៅក្នុងវង់ល្ខោនអាប៉េ ។

*ឈ -<u>វង់តន្ត្រីល្ខោនអាប៉េ</u>*

តាមការស្រាវជ្រាវ វង់តន្ត្រីល្ខោនអាប៉េមានកំណើតនៅខេត្តកំពង់ចាម ស្រុកមេមត់ ខេត្តតាកែវភាគខាងត្បូង, ខេត្តកំពតនិងពីក្នុងព្រះបរមរាជវាំង ។ ប៉ុន្តែសព្វថ្ងៃនេះស្ទើងតែបាត់ឈ្មោះបោះសំឡេងអស់ទៅហើយ ដោយសារយើងរក្សាតំលៃនិងទំរង់នេះមិនបានដិតដល់ ។ ក្រោយមកសិល្បៈទម្រង់នេះ អាចចុះឥទ្ធិពលបន្តិចម្តងៗស្ទើងតែបាត់បង់តែម្តង ។ ក្នុងនេះយើងគ្រាន់តែធ្វើការពិនិត្យទៅលើឧបករណ៍ភ្លេង និងឈ្មោះបទភ្លេងដែលត្រូវប្រគុំនិងការសំដែងដោយសង្ខេបខ្លី។ ទម្រង់សិល្បៈអាប៉េនេះ ក៏មានប្រជា



www.elibraryofcambodia.org

ប្រិយភាពក្នុងចំណោមប្រជាជនណាស់ដែរ។ ឧបករណ៍ភ្លេងក្នុងវង់តន្ត្រីអាប៉េនេះ មានចំនួនឯមុខគឺ :

១-ស្គរដៃ ២-ស្គរយីកេ ៣-ទ្រសោ ៤-ឈឹង ៥-ទ្រអ៊ូ ៦-ក្រាប ។

*របៀបសំដែង*

ទី១ -រំលឹកគុណគ្រូភ្លេង គ្រូល្ខោន ប្រគំបទហោមរោងប្រពៃណីភ្លេងការ ។

ទី២ -បទសំរាប់សំដែងក្នុងរឿងនិមួយៗគឺបទ : អាឡេវខាត់ ក្រសាំងទាប កន្ទុបម៉ែមួយ កន្ទុបតុយ សារិយ៉ាំង ជំនោរកន្ត្រឹក យោលយោក ។ល។ ក្រៅពីនោះមានច្រើនបទមហោរីមួយចំនួនបទយីកេខ្លះ បទអាយ៉ៃខ្លះ ។ល។ ឯការសំដែងច្រើនតែប្រើកាយវិការកំប្លែកទៅតាមពាក្យពេជន៍នៃចំរៀងនិមួយៗ។ ឯតួតុកច្រើនប្រើកាយវិការក្បាច់ឡូក កំផ្លុកកំប្លែងសើចតែរាល់ឈុតឆាកជាការចាំបាច់តែម្តង ។ វង់សិល្បៈអាប៉េនេះអាចសំដែងរឿងព្រេងបុរាណរឿងបច្ចុប្បន្នឬរឿងកំប្លែង ស្រេចតែទៅលើអ្នកដឹកនាំរឿងមានការប៉ិនប្រសព្វ ។ ទីកន្លែងសំដែងគេអាចសំដែងនៅក្នុងរោង នៅក្នុងពិធីបុណ្យទានផ្សេងៗឬនៅកន្លែងណាក៏បាន ដូចសិល្បៈអាយ៉ៃដែរ ។

*ញ-វង់តន្ត្រីអាយ៉ៃ*

សូមបង្ហាញជូននូវវង់ភ្លេងមួយទៀត ដែលបំរើក្នុងវង់សិល្បៈអាយ៉ៃ ។ វង់សិល្បៈអាយ៉ៃជាសិល្បៈមួយប្រភេទ ដែលមានប្រជាប្រិយភាពយ៉ាងខ្លាំងក្លាក្នុងចំណោមប្រជាជនទូទៅព្រោះសិល្បៈនេះគឺផុសចេញពីប្រភពប្រជាជនសុទ្ធសាធដូចជាល្បែងប្រជាប្រិយ លោតអន្ទាក់ ចាប់កូនខ្លែង បោះឈូង បោះអង្គុញ ចំរៀងប្រកកៃជាដើម ។ល។ ឯចំរៀងប្រកកៃនេះគេចាត់បញ្ចូលក្នុងប្រភេទសិល្បៈច្រៀងកំទៅហើយ នៅពេលខ្លះគេបានបញ្ចូលជាមួយវង់ភ្លេងផង ។ ការច្រៀងជាមួយវង់ភ្លេងនេះញឹកញាប់ទៅ ធ្វើឱ្យអារម្មណ៍អ្នកច្រៀងមានអារម្មណ៍ស្វាហាប់ បែកបញ្ញាស្មារតីចងចារិកចំរើនជាលំដាប់ ។



www.elibraryofcambodia.org

ផ្ទះអ្នកភ្លេង និងអ្នកច្រៀងប្រគំបញ្ចូលគ្នាមួយក្រុមជាវង់តែមួយជារៀងរហូតទៅ ។ ចំណេរក្រោយៗមកអ្នកចម្រៀងណាមួយមានបញ្ញាស្មារតីឈ្លាសវាងវៃ មានទេពកោសល្យប៉ិនប្រសព្វក្នុងការច្រៀងចោទឆ្លើយ ដោះសាររាល់បញ្ហាបានល្អ មានឈ្មោះល្បីជាងគេនៅក្នុងវង់និមួយៗ។ កាលពីជំនាន់នោះឧទាហរណ៍ជាក់ស្តែងដូចជាឈ្មោះអន្ទិតយ៉ៃជាដើមគាត់ច្រៀងពូកែជាងគេ តៗគ្នា ក្រោយមកគេតែងតែហៅសិល្បៈវង់នេះថា វង់អន្ទិតយ៉ៃៗឯប្រជាជននិងក្មេងៗដែលមិនធ្លាប់ស្គាល់អន្ទិតយ៉ៃនាំគ្នាហៅថាវង់អាយ៉ៃៗ តៗគ្នាជារៀងរហូតមកទល់សព្វថ្ងៃនេះតែម្តង ។ សិល្បៈអាយ៉ៃនេះនៅពេលសំដែងម្តងៗ គេប្រើពុទ្ធិជាអារម្មណ៍បានន័យថា : គេប្រើបញ្ញា ការឈ្លាសវៃជាធំ ក្នុងការរៀបពាក្យពេជន៏ខ្លឹមសារ ជាកំណាព្យចាប់ចុងជួនពាក្យ៤ ពាក្យ៧ពាក្យ៨ឬពាក្យ៩ជាដើម ។ គេច្រៀងចោទឆ្លើយសារសង ដោះសារនូវបញ្ហាផ្សេងៗទៅវិញទៅមក មានល្បះឃ្លាគួរជាទីពេញចិត្តនៃទស្សនិកជន អ្នកស្តាប់ភាគច្រើននៅតាមមូលដ្ឋានជនបទតែម្តង ។ តាមការពិនិត្យទៅឃើញថា គោលបំណងនិងឧត្តមគតិអ្នកគាំទ្រសិល្បៈអាយ៉ៃនេះ :

១-ចង់រក្សានូវប្រពៃណីនិងទំនៀមទំលាប់ជាតិរបស់ខ្លួន ជាជាតិមួយឈ្លាសវៃមានអរិយធម៌ឧត្តុងឧត្តម ខ្ពង់ខ្ពស់ ។

២-ចង់លើកតំលៃអក្សរសិល្ប៍ ពាក្យពេជន៏ខ្លឹមសារអក្ខរាវិរុទ្ធជាសម្បត្តិវប្បធម៌ជាតិខ្លួន។

៣-ចង់បញ្ចេញនូវទេពកោសល្យដ៏ប៉ិនប្រសព្វនៃការសំដែងរបស់អ្នកច្រៀងម្នាក់ៗផង ។

ឯឧបករណ៍តន្ត្រីដែលបំរើក្នុងវង់អាយ៉ៃនេះមានចំនួន៥មុខ គឺ : ទ្រសោ ទ្រអ៊ូ តះខេ ខ្លុយ ស្គរនិងឈឹង ។ ប៉ុន្តែពេលបច្ចុប្បន្ននេះ គេមានបន្ថែមឧបករណ៍មួយមុខទៀត គឺឧបករណ៍ឃឹម ។ ឃឹមនេះ វាបានរស់នៅជាមួយវង់ភ្លេងការនិងវង់ភ្លេងអាយ៉ៃ តាំងពីឆ្នាំ១៩៣៥មកទល់សព្វថ្ងៃនេះ ។

ឯបទភ្លេងដែលប្រើក្នុងវង់អាយ៉ៃនេះមានចំនួន ១៥បទ គឺ :

| | |
|---|---|
| ១-បទហោមរោង | ៩-បទសែនស្រណោះ |
| ២-បទកន្សែងក្រហម | ១០-បទចាប់ឆាយ |



www.elibraryofcambodia.org

| | |
|---|---|
| ៣-បទនមស្សការអាយ៉ៃ | ១១-បទយោលយោគ |
| ៤-បទបំពេរក្ងាយ | ១២-បទភ្ញុំភ្ញួង |
| ៥-បទគេនចារ | ១៣-បទតិកាមុង |
| ៦-បទនីលឡា | ១៤-បទចាបដើរដី |
| ៧-បទការ៉េយោនសា | ១៥-បទព្រានព្រៃឬចៅភីម |
| ៨-បទសយសង្ខារ "សយសង្ខាន" | |

ការពិនិត្យពិចារណា: ការវិវឌ្ឍន៍រីកចំរើននៃសិល្បៈអាយ៉ៃពីអតីតកាលមកដល់បច្ចុប្បន្នកាលនេះ យើងឃើញថាមានការរីកចំរើនគួរជាទីពេញចិត្តផ្នែកបទភ្លេង ក៏ដូចជាអ្នកសំដែង គេបានប្រើបទភ្លេងបំរើក្នុងការសំដែងច្រៀងឆ្លើយឆ្លងឬសំដែងជារឿងទៅតាមតួនិមួយៗឬក្នុងឈុតឆាកកំប្លែងជាដើមគេមានស្មារតីខ្ពស់ ធ្វើឱ្យសិល្បៈនេះមានលទ្ធភាពបំរើនូវសំណូមពររបស់ប្រជាជនមានប្រសិទ្ធិភាពគ្រប់ទិសទី ពិសេសបំរើនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលយើងផង ។

បន្ទាប់ពីវង់តន្ត្រីអាយ៉ៃនេះទៅ សូមបង្ហាញជូនវង់ភ្លេងមួយទៀតដែលបំរើក្នុងវង់ល្ខោនមហោរី ។

## ឌ- *វង់តន្ត្រីល្ខោនមហោរី*

ជាទំរង់ល្ខោនមួយ ដែលមានប្រជាប្រិយ ភាពក្នុងចំណោមប្រជាជនណាស់ដែរ ។ ល្ខោននេះ ច្រើនសំដែងចង្អុលបង្ហាញពីសកម្មភាព ពីហិនភាព ពីឧត្តមភាព ឥទ្ធិពល និងអាថ៌កំបាំងនៃសភាវៈនោះឱ្យលេចចេញជាធាតុភូតិពិត ។

វង់ល្ខោនមហោរីនេះមានកំណើតបន្ទាប់ពីវង់តន្ត្រីមហោរីនេះដែរគឺកើតពីក្នុងបរមរាជវាំងតែម្តង ។ ល្ខោននេះគេអាចសំដែងរឿងព្រេងបូរាណ រឿងពុទ្ធបវត្តិ រឿងព្រះវេស្សន្តរជាតក រឿងសុវណ្ណសាមជាតក រឿងក្រុងសុភមិត្ត រឿងប្រវត្តិសាស្ត្រជាតិ រឿងពពួកសត្វប្រៀបធៀបមកមនុស្ស និងរឿងកំប្លែងក្នុងបច្ចុប្បន្នកាលផង ។



www.elibraryofcambodia.org

បទភ្លេងដែលបំរើក្នុងរឿងល្ខោននេះ គឺប្រើបទភ្លេងចង្វាក់១ជាន់ ២ជាន់ និង៣ជាន់ ដែលមានច្រើនរយបទឯការសំដែងគឺភ្លេងនិងច្រៀងនាំមុខបន្ទាប់ពីនោះ ត្រូវមានពោលបន្ថែមបង្ហាញតួនិមួយៗផង ។

*កម្មវិធីសំដែង*

ល្ខោននេះសំដែងសំរាប់បំរើក្នុងព្រះរាជពិធីបុណ្យប្រពៃណីជាតិ សំដែងថ្វាយព្រះរាជាដើម្បីទតកំសាន្តព្រះរាជហរទ័យក្រោយពីព្រះអង្គនឿយហត់ព្រះកាយពលក្នុងការបំពេញព្រះរាជកិច្ចដឹកនាំប្រទេសជាតិ សំដែងជូនភ្ញៀវវជូនិងសំដែងផ្សព្វផ្សាយជូនប្រជារាស្ត្រទូទាំងប្រទេសទស្សនា ។

៨- *វង់តន្ត្រីល្ខោនព្រាហ្មោឡ*

បន្តពីនេះ សូមបង្ហាញជូននូវវង់តន្ត្រីដែលសំរាប់បំរើក្នុងវង់ល្ខោនព្រហ្មោឡដូចតទៅ :

សំស្ក្រឹត : ព្រហ្មោឡ ┐
បរិយាកាសរីករាយ
បាលី : ពហ្មោជ្ជ: ┘

ល្ខោនព្រហ្មោឡនេះ ជាល្ខោនមួយច្រើនសំដែងពីរឿងខ្លីៗ ហើយបរិយាកាសរីករាយមិនសូវសំដែងពីរឿងកំសត់ព្រាត់ប្រាស់ ឬមានការតស៊ូ ប្រើវេទមន្តយ៉ាំងគ្នាខ្លាំងក្លាអ្វីឡើយ ។ ល្ខោននេះពិតជាមានវត្តមានតាំងពីសម័យមុនអង្គរ តែទើបក្នុងសម័យចតុមុខទេដែលមានឥទ្ធិពលយ៉ាងខ្លាំងក្លា។ សូមបញ្ជាក់ថា វង់តន្ត្រីដែលបំរើឱ្យល្ខោននេះគឺវង់តន្ត្រីមហោរីតែម្តង ប៉ុន្តែក្រោយមកនៅសម័យចតុមុខគេអាចយកវង់ភ្លេងមហោរីផ្សេបំរើក្នុងវង់ល្ខោននេះតមករហូតមកទល់សព្វថ្ងៃនេះ ។

មុននឹងធ្វើការសំដែងគេមានរៀបចំពិធីរំលឹកគុណគ្រូបាធ្យាយដូចជាល្ខោនមហោរីដែរ ។ បទភ្លេងសំរាប់បំរើនូវតួនិមួយៗគេប្រើបទមហោរីចង្វាក់ ១ជាន់និង២ជាន់តែប៉ុណ្ណោះ ។



www.elibraryofcambodia.org

ចំនោរក្រោយមកភាគច្រើនគេ និយមយកបទដែលកើតនៅសម័យចតុមុខផង ។ ក្នុងចំណោមបទទាំងអស់នេះក៏មានប្រើនៅក្នុងវង់ភ្លេងបាសាក់មួយចំនួនដែរ។ ការសំដែងសាច់រឿងនីមួយៗច្រើនតែមានន័យស្នេហា ពាក្យពេជន៏កាយវិការមានលក្ខណៈទន់ភ្លន់និងទន់ជ្រាយផង។ កម្មវិធីសំដែងគឺបំរើជូនភ្ញៀវអន្តរជាតិភ្ញៀវវេជ្ជ ភ្ញៀវជាតិនិងសំដែងជូនទស្សនិកជនទូទៅ ។

## ខ- វង់តន្ត្រីភ្លេងតែន

សូមបង្ហាញនូវវង់តន្ត្រីមួយទៀត ដែលបំរើក្នុងវង់ភ្លេងតែន ។ ប្រជាជននៅភូមិភាគឥសាន្តជាអ្នកថែរក្សានិងគោរពប្រពៃណីជាតិរបស់ខ្លួនជាក់លាក់ ពិសេសគេបានថែរក្សាសម្បត្តិវប្បធម៌សិល្បៈ បទភ្លេងចម្រៀង របាំប្រជាប្រិយ របាំតែននិងភ្លេងតែនដែលមានលក្ខណៈផ្សារភ្ជាប់ទៅនឹងទំនៀមទំលាប់ពិធីបុណ្យចូលឆ្នាំជារៀងរាល់ឆ្នាំ ។ ឯភ្លេងតែនជាទំរង់ភ្លេងមួយដែលច្រើនតែប្រើបទចំរៀងជាបរិយាកាស និងបង្ហាញនូវតួអង្គនីមួយៗសាសងគ្នាតាមរយៈនៃបទចំរៀងដែរ ។នៅពេលពិធីបុណ្យចូលឆ្នាំម្តងៗ បងប្អូនខ្មែរយើងនៅភូមិភាគនោះ តែងតែប្រារព្ធធ្វើពិធីបុណ្យនៅតាមវត្តអារាមឬនៅក្នុងទីប្រជុំជនតាមភូមិផ្សេងៗ ដើម្បីជួបជុំគ្នាអបអរសាទរទទួលទេវតាថ្មី និងសុំពរជ័យសិរីសួស្តីសុភមង្គល វិបុលសុខគ្រប់ប្រការ និងបានបញ្ចេញទឹកចិត្តសោមនស្សសប្បាយរីករាយ រាំច្រៀងតាមសប្បាយ មានរបាំប្រជាប្រិយ របាំតែន រាំវង់ រាំក្បាច់ និងភ្លេងតែនជាដើម ។ ឯភ្លេងតែននេះ មុននឹងចាប់សំដែង គេត្រូវរៀបចំពិធីរំលឹកគុណគ្រូពាធ្យាយ ព្រះពិស្ណុការជាមុនសិន ។

### ការសំដែង

ដំបូងឧបករណ៍តែនចាប់ផ្តើមប្រគុំឡើង អ្នកច្រៀងក៏ចាប់រងាវជាមួយតែនចំនួនពាចប់ បន្ទាប់មកអ្នកច្រៀងចាប់ច្រៀងបទឧទ្ទិសរៀបរាប់អំពីគុណូបការៈ បុព្វទេវតានិងព្រះពិស្ណុការសូមជួយប្រសិទ្ធិសិល្បករសិល្បការនីក្នុងវង់ភ្លេងតែននេះ ឱ្យបានសុខសប្បាយ



www.elibraryofcambodia.org

មានជ័យជំនះគ្រប់ទិសទី ។ លក្ខណៈបែបបទក្នុងវង់ល្ខោនតែននេះ របៀបប្រើបទភ្លេងភាគច្រើនជាបទមហោរីចង្វាក់១ជាន់ ២ជាន់និងបទភ្លេងវង់បុរាណ ។ ឯបទមហោរីដូចជាបទនួនស្រី បទស្ទឹងចន្ទ័ បទផ្កាក្រង បទបុប្ផាអណ្តែត បទដួងចិត្តា បទក្លូឡាបជាក់សេ បទក្លូឡាបឈាងម៉ៃ បទឡាវល្ហមសំផាន់ បទឡាំកេវ បទឡាំលាវ ។ល។ ឯការសំដែងច្រើនតែជារឿងខ្លីៗក្នុងមនោសញ្ចេតនាសប្បាយរីករាយ និងមានការទំនាក់ទំនងគ្នាទៅវិញទៅមកមានការផ្តោះផ្តងសាសងវវាងគូរសង្សាស្នេហាបរិសុទ្ធ តាមមូលដ្ឋានរបស់ខ្លួន និងច្រើនលើកសរសើរពី ធម្មជាតិ ទឹក ដី ព្រៃព្រឹក្សាមផ្កាជាតិផង ។

## ធ- វង់តន្ត្រីល្ខោនបាសាក់

បន្ទាប់ពីវង់នេះទៅសូមបង្ហាញជូននូវវង់តន្ត្រីមួយទៀត ដែលសំរាប់បំរើប្រចាំការក្នុងវង់ល្ខោនបាសាក់។ វង់ល្ខោនបាសាក់នេះ អ្នកនិពន្ធគ្រាន់តែរៀបរាប់ជូនដោយសង្ខេបខ្លីៗមិនបានរៀបរាប់ពីប្រវត្តិពិស្តានៃវង់នេះ សូមអភ័យទោសជាមុន ។

តាមការស្រាវជ្រាវ វង់ល្ខោនបាសាក់នេះ គឺមានកំណើតកើតជានៅក្នុងខេត្តបាសាក់កម្ពុជាក្រោម ។ ពីដើមឡើយគេហៅថាល្ខោនទ្រើងឃ្លោក ព្រោះល្ខោននេះគេបានហ្វឹកហ្វឺនបានចេះដឹងក្រោមទ្រើងឃ្លោកនោះឯង ។ នៅពេលនោះគ្មានរោង គ្មានកន្លែងហាត់ត្រឹមត្រូវទេ គឺហាត់នៅក្រោមទ្រើងឃ្លោកតែម្តង ប្រសូតចេញពីទ្រើងឃ្លោកហើយបានបង្ហាញខ្លួន សំដែងជូនប្រជាជននៅពេលធ្វើបុណ្យទានតាមវត្តអារាមផ្សេងៗនៅតាមស្រុកនានាក្នុងខេត្តនិងឆ្លងពីខេត្តមួយទៅខេត្តមួយទូទាំងទឹកដីកម្ពុជាក្រោម ។ លុះមកដល់ឆ្នាំ១៩៣០ វង់ល្ខោននេះបានចូលមកដល់រាជធានីភ្នំពេញយើង ដឹកនាំដោយថៅកែម្នាក់ឈ្មោះឆាគ្រួន ជាអ្នកគ្រប់គ្រងវង់ល្ខោននេះ ។

ដំបូងល្ខោននេះបានសំដែងនៅលើទូកប៉ុកចាយចតនៅចំពីមុខវត្តឧណ្ណាលោមភ្នំពេញ ។ នៅពេលក្រោយមកទៀតល្ខោននេះបានចូលសំដែងនៅក្នុងរោងតែម្តង។ ចំណេរក្រោយមកសិល្បករសិល្បការនីនៅភ្នំពេញមួយចំនួន បានទំនាក់ទំនងសហការណ៍គ្នាមកលំាំង



www.elibraryofcambodia.org

និងរឿងនស្ត្រពីក្នុងបង្កើតស្នាដៃជារឿងបូរាណក៏ដូចជាបទចម្រៀងនិងភ្លេងបញ្ចូលបន្ថែមមួយទៀតធ្វើឱ្យឥទ្ធិពលនិងសោភ័ណនៃល្ខោននេះ បានល្បីប្រណិតទាក់ទាញទឹកចិត្តទស្សនិកជនចូលរួមទស្សនាជាច្រើនតាំងពីពេលនោះរហូតមកទល់សព្វថ្ងៃនេះ ។

ឧបករណ៍តន្ត្រីសំរាប់បំរើក្នុងវង់ល្ខោននេះមានចំនួន១១មុខគឺ : ១-ស្គរធំ ,២-ស្គរតូច, ហៅឡុក, ៣-ឡោ, ៤-ឈឹងចៅ , ៥-ឡោតា ,៦-ចាំង , ៧-ឆាប, ៨-ទ្រអ៊ូ ៩-ទ្រដេ,១០-ឃឹមតូចនិង១១-ឃឹមធំ។ ក្រៅពីនេះ មានឧបករណ៍សំរាប់តាមតួសំដែងនីមួយៗដូចជា ហ្លួនធំបង ហ្លួនធ្មិត ហ្លួនធ្នូ ហ្លួនដាវ និង ចាក់សាប ។ល។

<u>*របៀបសំដែង*</u>

មុននឹងបើកឆាកសំដែងរឿងផ្សេងៗជូនទស្សនិកជនទស្សនាកំសាន្ត គេត្រូវធ្វើពិធីហោមរោង ដើម្បីបួងសួងរំលឹកនឹកគុណគ្រូបាធ្យាយ ព្រះពិស្ណុការ លោកតាឥសី ព្រះឥសូរ ព្រះនាយរាជ សូមនិមន្តអញ្ជើញយាងមកស្ថិតនៅលើអសនៈនេះ ដើម្បីប្រសិទ្ធិប្រទានពរ សិស្សគណកូនចៅទាំងអស់គ្នា បានសុខសួស្តីស្ងាត់ចងចាំរាល់ការសំដែងទូទៅឱ្យឈ្មោះពិរោះល្បីទៅសព្វទិសទី ។

តាមការពិនិត្យពិចារណាទៅលើរូបភាពនៃល្ខោននេះ ចំពោះបទភ្លេង ចំរៀង សំលៀកបំពាក់និងហ្លួនជាទូទៅគឺ: ជាទម្រង់ល្ខោនមួយដែលបានទទួលនូវវប្បធម៌ចំរុះ ព្រោះក្នុងចំណោមក្បួនក្បាច់នៃការសំដែងផ្នែកចំរៀងក៏ដូចជាបទភ្លេង គឺមានឥទ្ធិពលមកពីប្រភពចិនមួយចំនួន ពីប្រភពវៀតណាមមួយចំនួនតូច ពីប្រភពក្លិង្គមួយចំនួននិងចេញពីប្រភពអារ៉ាប់មួយចំនួនដែរ ក្រៅពីនោះគឺបទរបស់ខ្មែរទាំងអស់ប្រហែល៨០ភាគរយ ។

របៀបរបបសំដែងរបស់ល្ខោនបាសាក់មុននឹងសំដែងរឿងផ្សេងៗជូនទស្សនិកជនទស្សនា គឺត្រូវធ្វើពិធីហោមរោង រំលឹកគុណគ្រូបាធ្យាយ ព្រះពិស្ណុការ ដើម្បីសូមយាងអញ្ជើញបារមីមកស្ថិតលើទីអសនៈ ។ បទដែលត្រូវប្រគំថ្វាយក្នុងពិធីហោមរោងនោះមាន : ១-បទសាធុកា( បាសាក់), ២-បទលើកករបង្គំ,៣-បទសារ៉ាន់១ឡា១, ៤-បទសារិយ៉ាំង និង ៥-បទសាំងកាសេន (សំរាប់រាយតួឬបង្ហាញតួមាន : តួស្តេច តួនាង តួនាម៉ឺន



www.elibraryofcambodia.org

ត្លុយក្ស ត្លុក។ល។) ។ ឯបទភ្លេងពាសាក់សុទ្ធមានចំនួន៣០បទ មានឈ្មោះដូចខាងក្រោម :

១-បទលោមធូ ២-បទលោមតឹង

៣-បទលោមស្មើ ៤-បទលោមចំហៀង

៥-បទលោមក្មេង ៦-បទផាត់ជាយ

៧-បទផាត់ជាយយក្ខ ៨-បទស៊ុរិយង់

៩-បទសំពោង ១០-បទអង្គរាជស្តេចថ្មី

១១-បទអង្គរាជយក្ខ ១២-បទបំពេរពាសាក់

១៣-បទទំនួញពាសាក់ ១៤-បទទំនួញពាភ្លំង

១៥-បទចំពីកើត ១៦-បទចំពីយក្ខ

១៧-បទសទ្ទែសទ្ទឹក ១៨-បទកធរាវ

១៩-បទរាប់សួន ២០-បទរ៉ែយាង

២១-បទវណ្ណត ២២-បទភ្លឹងតឹងតាំង

២៣-បទភ្លឹងកង់ជីវ ២៤-បទភ្លឹងចែកទំព

២៥-បទភ្លឹងកំសត់ ២៦-បទភ្លឹងយុងក្ខ

២៧-បទភ្លឹងហៃណាំ ២៨-បទឡេងស៊ុ

២៩-បទផ្លូវយឺសាស៊ុ ៣០-ហ៊ាឡូម៉ាន

ក្រៅពីនោះនៅមានបទម៉ហោរីមួយចំនួនបន្ថែមទៀត :

១-បទណាយរ៉េ ២-បទរ៉ាំងស៊ុក្ខ

៣-បទរបាំក្លឹង ៤-បទចាក់សាប

៥-បទម៉ែអន ៦-បទកញ្ច្រែកចោកបាច

៧-បទទំនួញព្រះកែវ ៨-បទសរកាមទេព

៩-បទស្រើស្រណោះ ១០-បទឡាវលាង



www.elibraryofcambodia.org

១១-បទនារីកាគី
១២-បទនារីលង្វែក
១៣-បទស្រីស្រណោះ
១៤-បទអាភ័ប់ថ្វាយពរ
១៥-បទដាយីដាយ៉រ
១៦-បទក្លូឡាបឈាងម៉ៃ
១៧-បទក្លូឡាបប៉ៃលិន
១៨-បទក្លូឡាបបាត់ដំបង
១៩-បទស្នេហាពេញចិត្ត
២០-បទស្នេហាអស់សង្ឃឹម
២១-បទផ្កាស្រពោន
២២-បទកន្ទង់ក្រេបផ្កា
២៣-បទផ្លូងចំប៉ា
២៤-បទទោចយំ
២៥-បទផ្លូងចំប៉ាក្លាយ
២៦-បទសយលំហួន
២៧-បទសយភ្លេង
២៨-បទបុប្ផអណ្តែត
២៩-បទឡាវខ្សឹន
៣០-បទភ្លូងម៉ាខ្សៃ
៣១-បទខ្មែរឡើងព្រះពន្លា
៣២-បទទេពធីតា
៣៣-បទឆទីរងហាយ
៣៤-បទនរោត្តម
៣៥-បទរ៉ូទី
៣៦-បទជីណ្ណារឿ
៣៧-បទភ្លូងមរកត
៣៨-បទណាងគ្រួន
៣៩-បទស្រែងចន្ទ័
៤០-បទសែងធឿន
៤១-បទទឹកណាស់
៤២-បទលេកផ្ទប់ច្រាំង
៤៣-បទជីនចាំងឡាង
៤៤-បទជីនតាយ៉រ
៤៥-បទសំឡឹងព្រះចន្ទ័
៤៦-បទក្លូឡាបភោយ
៤៧-បទក្លូឡាបក្រពុំ
៤៨-បទខ្មែរស្រម័យ
៤៩-បទបុប្ផរៀងចាង់
៥០-បទចៅព្រាហ្មណ៍
៥១-បទដំណើរខ្មែរ
៥២-បទចុងពឹម
៥៣-បទបិទដំដែក
៥៤-បទកែវជីភ៉
៥៥-បទក្លិកក្លក់
៥៦-បទជំនោរខែច្រាំង



www.elibraryofcambodia.org

៥៧-បទភាំល់តូច
៥៨-បទអានីយើហាវៃ
៥៩-បទដំរីលេងភ្លុក
៦០-បទនាងកង្រី
៦១-បទបុងស្រល់
៦២-បទចាពុនឆាអន
៦៣-បទបុងអូ
៦៤-បទកញ្ញែកអ
៦៥-បទសេតាងកហាត់
៦៦-បទសេតាយសថ្វែង
៦៨-បទបុងតាបក
៦៩-បទកាបិលឡេឡា

ក្នុងនោះនៅមានបទភ្លេងមួយចំនួនទៀត ដែលត្រូវយកមកប្រើនៅក្នុងវង់ពាសាក់នេះ ប៉ុន្តែការស្រាវជ្រាវយកមកបង្ហាញជូនដោយសង្ខេបតែប៉ុណ្ណោះ សំរាប់កំណត់សំគាល់នូវប្រភេទបទភ្លេងផង ។

## ៤_ពិធីសំពះគ្រូផ្នែកតន្ត្រីបុរាណខ្មែរ

ជាក្បួនក្នុងបរមរាជវាំងមានអាយុជាច្រើនស.វមកហើយ មកដល់សព្វថ្ងៃនេះយើងខ្ញុំបានចម្លងតាមដើមទាំងស្រុង ទុកសំរាប់កូនចៅជំនាន់ក្រោយរៀនសូត្រតាម ។ ពិធីសំពះគ្រូនេះជាពិធីមួយមានសារៈសំខាន់ណាស់ សំរាប់កម្មសិក្សាការីនិងសិល្បករសិល្បការនីព្រមទាំងនរជនទូទៅដែលមានជំនឿទៅលើបុព្វការីជន មានមាតាបិតានិងគ្រូបាធ្យាយជាដើម ។ ព្រោះរូបភាពនៃទង្វើរនេះ មានលក្ខណៈអប់រំផ្លូវកាយវាចារចិត្តនិយាយរួមអប់រំផ្នែកសីលធម៌សង្គម ។ម្យ៉ាងទៀតជាចិត្តសាស្រ្តមួយនាំមកនូវកត្តានុម៉ែតនៃមនោសញ្ចេតនាផ្សារភ្ជាប់រវាងមាតាបិតានិងបុត្រ-បុត្រីការវាងគ្រូបាធ្យាយនិងសិស្ស



www.elibraryofcambodia.org

ជាប្រពៃណីល្អពីបុរាណមក ជានិមិត្តរូបឬជារូបមន្តនៃការបណ្តុះបណ្តាលនូវពុទ្ធិ និង គុណធម៌សំរាប់សិស្សានុសិស្សគ្រប់រូប ។

<u>រូបភាពពិធីសំពះគ្រូ</u>



*ក. <u>ពិធីសំពះគ្រូធំ ក្នុងវង់ពិណពាទ្យ</u>*

ពេលប្រារព្ធពិធីមុនដំបូង ត្រូវនមស្សការព្រះរតនត្រ័យ " នមោតស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស " (៣ចប់ ) ពុទ្ធំ អរធនំ ករោមិ .ធម្មំ អរធនំ ករោមិ. សឃំ អរធនំ ករោមិ " ។

យើងខ្ញុំព្រះករុណាទាំងឡាយសូមក្រាបថ្វាយបង្គំ ប្រណម្យអញ្ជលី ថ្វាយបង្គំចំពោះព្រះ



www.elibraryofcambodia.org

បរមគ្រូ បរមនាថ បរមបពិត ស្ថិតនៅលើផែនភពព្រះធរណី គិរីបុព្វតា ពីក្សាព្រៃភ្នំក្រំថ្ម បឹងបួ ទន្លេជលសា ទេព្តាស្ថិតនៅលើវិមានអណ្តែតសោឡស់ជាន់ ពំនូក្រឡាមហាប្រថពី ស្តេចក្រុងពាលី ម្ចាស់ទឹកម្ចាស់ដី អ្នកតាចាស់ស្រុក ភូមិដ្ឋានវត្តសីមា សូមអញ្ជើញយាងព្រះគ្រូកំណើតបង្កើតរូបរាងកាយយើងខ្ញុំមកស្ថិតក្នុងទីនេះសូមអញ្ជើញគ្រូធំប្រគុំតន្ត្រីស្រឡៃ គងស្គរ សំភោរ រនាត ពាទ្យពិណ សូមមកប្រសិទ្ធិពរបវរសួស្តីជ័យមង្គល វិបុលសុខដល់កូនចៅគ្រប់ៗគ្នាហោង ។ ភ្លេងប្រគំ : ១-បទសាធុការ ។

- ឱ កា ស យើងខ្ញុំអញ្ជើញព្រះគ្រូព្រាហ្មណ៍មកស្ថិតនាពិធីរោងនេះ ឱ កា ស វន្ទិអាចារិយំ ។ ភ្លេងប្រគំ : ២-បទត្រាក់ធំ ។

- ឱ កា ស វន្ទាឥសីសិទ្ធ ព្រហ្មចតុលោកបាលនាថ ឥសីសិទ្ធ អនុត្តរំ ។ ភ្លេងប្រគំ : ៣-បទផ្លិត ។

- វន្ទាបាទេ អាចារិយោសិទ្ធ ទមត្តយាំយំ អហំវន្ទាមិ។ ភ្លេងប្រគំ : ៤-បទពញាដើរ ឬ "ផ្សាជិន" ។

- ឱ កា ស ពិយោថេរ មនុស្សានំ ឱកាសតេ កាមេបរូបេ អថចក្ខា សយរ សខរខេ ចន្ទរខេ វិមានេ ទិបេរ ថេចរមេត វណ្ណធុម្មាធុម បច្ចយំ ទថេ រោចវត្ថរេ សណៃយជន្តា បឌិណាមាទវជតាសទ្ធ ថេយំ មុទិវច្ចនំ សាធុមេ សុទន្តុ ។ ភ្លេងប្រគំ : ៥-បទ ហក់ ។

-ទ រ ម នៈ ប ពិតើយ យើងខ្ញុំសូមស្តេចយាងទេវបុត្រទេពធីតាទេព្រក្ស ដែលស្ថិតនៅគ្រប់ទិសទីតំបន់ សព្វដោយព្រៃភ្នំក្រំថ្ម សមុទ្រ ទន្លេ បឹងបួរ វាលរាបតូចធំនិងទួលអង្គនិងរក្សានូវស្វេត្រឆ័ត្រ ស្ថិតនៅទិស្ថានវិមានអណ្តែតគ្រប់អង្គទាំងអស់ខ្ញុំសូមអុជទៀនធូបថ្វាយ សូមពរជ័យឱ្យទានឈ្នះមារសត្រូវទាំងឡាយ ធុកៗ ថោៗស្វាហាយៈ ។ ភ្លេងប្រគំ : ៦-បទត្លុំ ។

-នមោមិ សក្ការមិ សក្ការំ សូមអញ្ជើញឥន្ទ្រាធិរាជទាំងព្រះបរមនាថ ព្រះចិត្តលោកបាល ព្រះពិស្ណុការ ដែលស្តេចយាងមកទីនេះ សូមព្រះគុណប្រសិទ្ធិឱ្យកូនសិស្សប្រុស



www.elibraryofcambodia.org

ស្រីឈ្នះមារសត្រូវគ្រប់ទិសទី សូមឱ្យបានដូចផ្កាីរីកចេកទុំ សិទ្ធិស្វាហា: ។ ភ្លេងប្រគំ :
៧-បទ រោទិ៍ភពពាត់

-ពិឃោប្រំ បនត្តរ ឧ កា ស ខ្ញុំសូមព្រះអង្គសូមអរធនា ព្រះបរមឈីណា ភឹតទីណា កទិគុណា អត្ថុំទិទ្យេ អេបិនម៉ុងខំជំឡូកកាឡេ សូមអញ្ជើញមកសករថុតតុ ថៅពុស្វាហា: ។ ភ្លេងប្រគំ : ៨-បទតំបងកាល់ ។

-ឱ កា ស ខ្ញុំសូមទេវព្រក្សមែន មានសិទ្ធសក្តិស្ថិតនៅផែនស្ថានសាសព្វ បព្វតា ខ្ញុំសូមអញ្ជើញសម្តេចសាមណេរិទ្ធស្តែងនូវកំហែងបរិសទ្យ ព្រះនាគរិទ្ធក្រៃ កំហែង ព្រះសច្ចៈអ្នកតែងឡានមកជាសាក្សីកំហែងពេជ្រ ឱ្យជ័យព្រះស្រីវត្តត្រ័យឱ្យសាធុការ ឱ្យសូមបង្គំ សច្ចំ ខន្តី ព្រះបារមីទិព្វញាណ ព្រះបាទទស្សមរៈរាជផ្តើងផ្កានូវអស់សត្វ បំបាំងបាត់ សូមអញ្ជើញបង់បត់សព្វព្រះធរណីសំដែងរិទ្ធិឱ្យពរយើងខ្ញុំ ។ ភ្លេងប្រគំ :
៩-បទកាម៉ាន់ ។

-បពិតើយ យើងខ្ញុំទាំងឡាយសូមឌិនកាយ ថ្វាយបង្គំ សូមនិមន្ត លោកគ្រូកំហែង ហនុមានដែលស្ថិតដោយបព្វតានានាផងទាំងឡាយ ខ្ញុំសូមអញ្ជើញស្តេចព្រះវេស្សវ័ន្ត ស្តេចកុវេរោរាជវែឆក់ ឆក់វៃ អ្នកតាចាស់ស្រុករក្សាដែនភពគ្រប់តំបន់ សូមអញ្ជើញ សំដែងរិទ្ធិទាំងឡាយគ្រប់ៗគ្នាហោង ។ ភ្លេងប្រគំ : ១០-បទម ហារិទ្ធិ ។

-ឱ កា ស ខ្ញុំអរធនា សម្តេចព្រះគ្រូអាចារ្យ ព្រះសហំ ព្រះត្រី ព្រះខ្វាយព្រះបុតី ព្រះក័សី១៨អង្គនិងព្រះពិស្ណុការ ព្រះវេស្សកម្មបញ្ច ខេ ខេ ទេវបុត្រ ព្រះមហោសថ សូមព្រះអង្គទ្រង់មេត្តាស្តេចយាងមកគង់ប្រថាប់លើទីបូជា សូមព្រះអង្គប្រសិទ្ធិឱ្យសិស្ស ទាំងឡាយបានសុខជវនណាជីតៗ ។ ភ្លេងប្រគំ : ១១-បទស្រសាម៉ា "ព្រាជាន់" ។

-ឱ កា ស បពិតើយ ខ្ញុំទូលព្រះបង្គំសូមអរធនា និមន្ត ស្តេចយាងព្រះអាទិត្យ ព្រះចន្ទ័ទាំងពីរព្រះអង្គដែលមានស្មើបំភ្លឺមនុស្សលោកទាំង៤ទ្វីបនេះ សូមឱ្យពរប្រសិទ្ធិ មានរិទ្ធី បារមី សុខសៅណៃ ចយុជវាចិត ។ ភ្លេងប្រគំ : ១២-បទស្វឹខណ្ឌសមុទ្រ ។

-ពិឃោធមនុស្សធំ មទរ: នុតថេបញ្ញ វច្ចសាត តយោ អលោករោតិ យោប



www.elibraryofcambodia.org

ចេយ សិទ្ធិគោរជ្ជោ ថបសទភំ វេទ្ធនៈ សុវណ្ណរចថ ចមំហិធិថានៈតេវ៉្វហន្តិ ។ ភ្លេង
ប្រគំ : ១៣-បទជើតឈាន។

-ឱ កា ស រស្មីថ្ងៃនេះជាថ្ងៃជោគជ័យ សិរីសួស្តីល្អ ពួកខ្ញុំទាំងអស់គ្នាសូមនមស្ការ
ថ្វាយបង្គំព្រះឥសូរ ដែលជាគ្រូយក្ខ័ទាំងឡាយ សូមយាងមកឱ្យពរសាធុការ ឱ្យបានដូច
សេចក្តីប្រាថ្នា ។ ភ្លេងប្រគំ : ១៤-បទសទ្ធិកក្នុង ។

-ពិ យោ ស ភន ទំ ។ ភ្លេងប្រគំ : ១៥-បទរាំព្រះបាទសត្ថា

-ពិ និស យំ ន មាមិ ហំ ។ ភ្លេងប្រគំ : ១៦-បទភិភីប៉ាវង ។

-បពិតើយ យើងខ្ញុំសូមអញ្ជើញនាងខិណីជាក្សត្រិយ៍ ដែលមានរិទ្ធចេស្តាស្ថិតក្នុងបុព្វ
កាលមហាសមុទ្រ ព្រៃហេមពាន្តផងទាំងឡាយនានា ព្រាយពិសៀ សន្ធមា សន្ធរស់
ធ្វវខណីទាំងឡាយ សូមជូនពរផ្សាយដល់យើងខ្ញុំទាំងអស់គ្នា មានសិរីសួស្តីជ័យមង្គល
គ្រប់ៗគ្នាហោង ។ ភ្លេងប្រគំ : ១៧-បទខែកបរឆេក ។

-ឱ កា ស វន្ទាព្រហ្ម សមេទាទិមន្តព្រះមហាឥសីជាច្បង ដែលមានរិទ្ធិសែងសាយ
គ្រប់ដំពូទ្វីពនេះ សូមនិមន្តព្រះឥសីអគ្គិនេត្រ ឥសីភ្នែកគោណាំ ឥសីភាសព្វ ឥសីធ្មេច
នេត្រ ឥសីភក្រវែង ឥសីពុទ្ធមង្គល ឥសីមុនីតេជ្ជា ឥសីតាបស ព្រះមហាឥសីទាំង
អស់គ្រប់អង្គសូមនិមន្តមកឱ្យពរកូនសិស្សគ្រប់ៗគ្នាហោង។ ភ្លេងប្រគំ : ១៨-បទជើត។

-ឱ កា ស យើងខ្ញុំទាំងអស់គ្នាលើកហត្ថាដាក់លើសិរសី ថ្វាយបង្គំបួងសួងអញ្ជើញ
ព្រះឧមា នាងទេវេត សូមស្តេចយាងមកឱ្យពរជ័យសព្វសាធុការដល់កូនសិស្សគ្រប់ៗ
គ្នាសូមអញ្ជើញទេពធិតាទេពអប្សរបរវកញ្ញា ព្រមទាំងព្រះនាងព្រះធរណីមណីមេខឡា
ទេវីមែព្រះយោស៊ិកឆោមស៊ុមានគុណធ្ងន់ដ៏ក្រៃលែង សូមយាងមកផាប់ៗយើងនឹងថ្វាយ
សក្ការៈបូជាហើយសូមពរបានសុខសុវត្ថិកំចាត់ភ័យ។ ភ្លេងប្រគំ : ១៩-បទជើតឈឹង។

-ឱ កា ស ពិយោការវណ្ណំ ។ ភ្លេងប្រគំ : ២០-បទបថម ។

-ផរិ ស៊ុរិយំ ភំណាំ នមាមិហំ ។ ភ្លេងប្រគំ : ២១-បទរុករុន ។

-យើងខ្ញុំបង្គំបាទទាំងពីរព្រះស៊ុរិវង្ស ដែលទ្រង់មានរិទ្ធជាច្បងក្នុងលោកា យើងខ្ញុំបង្គំ



www.elibraryofcambodia.org

ព្រះនរាយណ៍ភាមាអស់ពួកអសោរិភពផង ព្រះបក្រវង្សទ្រង់ប្រសិទ្ធិពរឱ្យយើងទាំងឡាយគ្រប់ៗគ្នាហោង ។ ភ្លេងប្រគំ : ២២-បទជើតឆាប់ ។

-ស្តិរមេថ្វ ថថេវថ្វនះ លោកានំថេវថ្វា មឡមេសតេវេថ កេចរូកាន់ ចេព្រះស៊ីព្រះតាម្នាព្រះសិទ្ធិមេ ។ ភ្លេងប្រគំ : ២៣-បទមហាជ័យ ។

-ឱ កា ស ខ្ញុំព្រះករុណាទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា លើកគ្រឿងសក្ការៈបូជាថ្វាយចំពោះសម្តេចព្រះគ្រូគ្រប់អង្គសូមស្តេចទ្រង់ទសនី ទទួលដោយហរទ័យសោមនុស្សគ្រប់ៗព្រះអង្គហោង ។ ភ្លេងប្រគំ : ២៤-បទសាធុកា ។

-ឱ កា ស យើងខ្ញុំសូមនិមន្តអញ្ជើញព្រះពុទ្ធភូមិ ព្រះពុទ្ធតេជ្ជៈទាំងពីរព្រះអង្គដែលយាងមកគង់នៅទីនេះសូមទ្រង់ឱ្យពរជ័យសិរីមង្គលដល់សិស្សគ្រប់ៗគ្នាហោង ។ ភ្លេងប្រគំ : ២៥-បទផាយរឿ ។

-ឱ កា ស ពុទ្ធំ ធម្មំ សំឃំ ថេរ ឯទិធ ឯហិ ។ ភ្លេងប្រគុំ : ២៦-បទលោហើ ។

-ឱ កា ស យើងខ្ញុំសូមនិមន្ត ស្តេចយាងព្រះបាទកងចក្រ ព្រះបាទកងព័ន្ធទាំងពីរព្រះអង្គសូមយាងមកឱ្យពរជ័យដល់សិស្សគ្រប់ៗគ្នាហោង ។ ភ្លេងប្រគំ : ២៧-បទក្លុះគុនម៉ាយ ។

- វន្ទា មិភន្តេ ខ្ញុំព្រះករុណាសូមអរធនានិមន្តព្រះមហាឥសី១០៨ សឹងមានរិទ្ធិសែងសាយព្រះបារមីឆោមឆាយសូមស្តេចយាងព្រះព្រហ្មឥន្ទ្រាទេវបុត្រ ទេវតាសម្តេចព្រះគ្រូគ្រប់ព្រះអង្គ សូមយាងកំចាត់បង់នូវជម្ងឺឈឺថ្កាត់ ឧបទ្រពចង្រៃអ្វីៗកុំបីខានឡើយ ។ ភ្លេងប្រគំ : ២៨-បទព្រហ្មគិបវ៉ែន ។

-ខ្ញុំព្រះករុណា ទូលព្រះបង្គំខ្ញុំក្រាបថ្វាយបង្គំ និមន្តស្តេចយាង អញ្ជើញគ្រប់ព្រះអង្គជំរះព្រះកាយព្រះអង្គឥឡូវនេះហោង ។ ភ្លេងប្រគំ : ២៩-បទឡុងសុង ។

-យើងខ្ញុំព្រះករុណាសូមអរធនានិមន្តស្តេចយាងអញ្ជើញព្រះគ្រូគ្រប់ព្រះអង្គទាំងអស់ឆាន់សោយនូវបង្កាន់ព្រះស្ងោយក្រយា ចំណីតាមតែសព្វព្រះរាជហរទ័យគ្រប់ៗអង្គហោង។ ភ្លេងប្រគំ : ៣០-បទសែនឡាវ "សែនព្រេន" ។



www.elibraryofcambodia.org

- យើងខ្ញុំសូមអញ្ជើញស្តេចព្រាយ ដែលនៅគ្រប់តំបន់ជិតឆ្ងាយសូមអញ្ជើញព្រះបារមី ព្រាយក្បាល៨ ព្រាយអាកាស ព្រាយសំពោងសក់ធំ ព្រាយបិសាចរាជទូតទាំងឡាយ សូមមកទទួលថ្វាយជូនមាន់ទាំងផ្កាលាចនេះជាដើមម្ហូបចំណីគ្រប់មុខគ្មានខ្វះអ្វីឡើយ ។ ភ្លេងប្រគំ : ៣១-បទប្រួយខៅតែក ។

- ឱ កា ស ខ្ញុំព្រះករុណា ទូលព្រះបង្គំទាំងឡាយ សូមបួងសួងរំលឹកដល់គុណព្រះគ្រូគ្រប់ព្រះអង្គ ដែលទ្រង់និមន្តស្តេចយាង អញ្ជើញមកគង់ក្នុងរោងរម្យនេះ (រោងសំពះគ្រូហើយនឹងបានទទួលនូវវត្ថុគ្រឿងសក្ការៈបូជាដែលយើងខ្ញុំរៀបចំថ្វាយជូនជាសំរេច ហើយនេះសូមក្រាបថ្វាយបង្គំយាងអញ្ជើញព្រះគ្រូគ្រប់ព្រះអង្គ ទៅកាន់ទីស្ថានព្រះអង្គដូចដើមវិញហោង ។ ភ្លេងប្រគំ : ៣២-បទរៀនធៀន (បង្វិលពពិលរាំថ្វាយបូស្វគ្រ ធម៌ជ័យន្តោ) ,៣៣-បទជើតជូនគ្រូ , ៣៤-បទឈប់ ( ក្រាវរាំ )- បញ្ចប់ពិធី ។

<u>រណ្តាប់រៀបចំពិធីសំពះគ្រូធំ ផ្នែកតន្ត្រី</u>

១- បាយសី ៩ជាន់ ១គូ
២- បាយសី ៧ជាន់ ១គូ
៣- បាយសី ៥ជាន់ ១គូ
៤- បាយសី ៣ជាន់ ១គូ
៥- បាយសីចាំឆាម ១គូ
៦- ស្លាធម៌ ធម្មតា ១គូ
៧- ដូងខ្ចៅ ១គូ
៨- សំពត់អាវឆ្វេងស្តាំ
៩- បេកទុំ២ស្និត
១០- ផ្លែឈើ ១គូ
១១- បង្អែម ១គូ
១២- ចង្អាប ១គូ
១៣- មាន់ស្ងោ ១គូ
១៤- ក្បាលជ្រូកឆ្អិន ១គូ
១៥- ទឹកបូណាត ១គូ
១៦- បារី ៥
១៧- ស្លា ៥
១៨- ប្រេងម្សៅ
១៩- ទឹកអប់ ១គូ
២០- ទឹកមួយផ្តិលធំ



www.elibraryofcambodia.org

## <u>*បទភ្លេងសំរាប់ប្រើប្រាស់ក្នុងពិធី*</u>

ផ្នែកនេះ គឺសូមបង្ហាញបញ្ជាក់ជូននូវអត្ថប្រយោជន៍នៃឈ្មោះបទភ្លេងនិមួយៗ ដែលសំរាប់ប្រគំថ្វាយជូនចំពោះបារមីនិមួយៗនៅពេលប្រារព្ធពិធីសំពះគ្រូ ៖

១-<u>បទសាធុការ</u> : -សំរាប់ប្រគំគោរពរំលឹកគុណគ្រូបាធ្យាយ ដែលបានដឹកដៃបំភ្លឺផ្លូវផ្តល់នូវចំណេះវិជ្ជាដល់ខ្លួនឬប្រគំនៅពេលឧទ្ទិសអនុមោទនាផលល្អានិស្សង់ ត្រេកអរនូវអំពើល្អនោះផង ។

២-<u>បទត្រាក់ធំ</u> :-សំរាប់ប្រគំកំដរអ្នកមានឫទ្ធិចេស្តា ឧទ្ទិសសិលវេទមន្ត មានព្រះឥសូរព្រះនរាយណ៍និងអវលោកិស្វរៈ ជាដើម ។

៣-<u>បទផ្លិត</u> :-សំរាប់ប្រគំជូនដំណើរឥសីរិទ្ធិព្រហ្មចតុលោកបាយ និងស្តេចសិម្ពលីក្រុងនៅពេលហោះហើរប្រពាតព្រៃពីក្សាកំសាន្តកាយឬយាងទៅកាន់នគរសិរីលង្កា ។ ដោយខ្សែកទ្រង់យាងទៅកាន់បង្ក្រាបក្រុងរាមណាសូរ ជាកងសេនាយោធាសុភឥន្ទជិតផង ។

៤-<u>បទពញាដើរ</u> :-សំរាប់ប្រគំអមព្រះដំណើរព្រះមហាក្សត្រនិងមន្ត្រីជាន់ខ្ពស់ឬដំណើរក្រុមទេពមនោរម្យ ចេញទៅក្រសាលឧទ្យាន និងវិលត្រឡប់ចូលក្នុងនគរវិញ ។

៥-<u>បទ [illegible] ហក់</u> :-សំរាប់ប្រគំជូនដំណើរសម្តេចព្រះមហាសុធន្នុមេហោះហើរ ជួយសង្គ្រោះមនុស្សសត្វទាំងឡាយឆ្លងកាត់ពីទិតមួយទៅទិតមួយទៀត ។

៦-<u>បទគ្និ</u> :-សំរាប់ប្រគំជូនដំណើរទេវបុត្រធិតាទេព្រក្ស័ដែលស្ថិតនៅស្ថានវិមានអណ្តែតសោឡស់ជាន់ស្ថិតនៅលើព្រះមហាស្វេតឆ័ត្រ ឬព្រៃព្រឹក្សា ជ្រោះភ្នំក្រំថ្ម ជ្រលងជងអូរបឹងបួរ រាណរាប ។

៧-<u>ពេចិ[illegible]</u> :-សំរាប់ប្រគំដំណើរព្រះឥន្ទ្រាធិរាជនិងព្រះបាទយមរាជ ព្រះចិន្តលោកបាលមានរិទ្ធិចេស្តា សូមយាងមកប្រសិទ្ធិពរបវរសួស្តីឱ្យសិស្សគណ បានសុខចំរើនរុងរឿងតរៀងទៅ ។

៨-<u>បទដំបងកាល់</u> : -សំរាប់ប្រគំបង្គំអរធនាព្រះបរមណីណាភិត់ទីណា ប្រកបដោយបារមីខ្លាំងក្លាលើលោក សូមយាងមកប្រក់ព្រំដល់កូនចៅសិស្សគណឱ្យបានសុខគ្រប់គ្នា។



www.elibraryofcambodia.org

៩-បទកាម៉ាន់ : -សំរាប់ប្រគំយាងអ្នកសច្ចំ ខន្តិ បារមីទិព្វញាណ ទស្សបរៈកំហែងពេជ្រ ព្រះអាទិត្យ ព្រះចន្ទ័ ចមក្សត្រ៨កោដិ រិទ្ធិខ្លាំងក្រៃ សូមយាងមកប្រសិទ្ធិពរដល់កូនចៅបានជោគជ័យផង ។

១០-បទមហារិទ្ធិ : -សំរាប់ប្រគំយាងអញ្ជើញស្តេចហនុមាន កំហែងបាដាលនិងស្តេចយាងព្រះវេស្សវន្តកុមេរុរាជ រៃគក់គក់រៃ មកសំដែងរិទ្ធិបាដិហារ្យគ្រប់ព្រះអង្គទាំងអស់ក្នុងពិធីមហារោងជ័យនេះ ។

១១-បទស្រមាញ៉ី ឬរោទិ៍ពជាន់ : -សំរាប់ប្រគំអរធនា សម្តេចព្រះគ្រូអាចារ្យព្រះមហាឥសី១៨អង្គ ព្រះពិស្ណុ ព្រះវេសកម្មទេវបុត្រមកប្រស់ព្រហ្មឱ្យកូនចៅបានសុខគ្រប់គ្នា ។

១២-បទស៊ីរខន្ធសមុទ្រ : -សំរាប់ប្រគំយាងព្រះអាទិត្យ ព្រះចន្ទ័មកបំភ្លឺទិបទាំងបួនឆ្លងផ្លែផលសាដើម្បីរក្សាសុខ។

១៣-ជើត ... ឈាន : -សំរាប់ប្រគុំជូនដំណើរអ្នកមានសីលព្រហ្មវិហារធម៌ សច្ចំ ខន្តិ ឥសី តាបស និមន្តប្រស់ព្រហ្ម ។

១៤-បទសន្ទីកក្តេ [illegible] : - សំរាប់ប្រគំជូនដំណើរព្រះឥសូរជាគ្រូនៃយក្ខ ឬ ដំណើរនៃពួកទពយក្ខ ដែលចេញទៅប្រយុទ្ធនឹងបច្ចាមិត្តនៅសមរភូមិផ្សេងៗ ។

១៥-របាំព្រះបាទសន្តិ : -សំរាប់ប្រគំថ្វាយព្រះមហាភជតេជ្ជៈរិទ្ធិ យាងមកទទួលដង្វាយផ្សេងៗនិងក្រសាលនូវរបាំសេះគន្ធី ជាទិសព្វព្រះរាជហរទយ័ផង ។

១៦-បទភិរិបរ៉េង : -សំរាប់ប្រគំថ្វាយអ្នកមាននរិទ្ធិបាដិហារ្យតម្កើងសីលវេទ្ធមន្តបែងភាគបំបាំងកាយយ៉ាងខ្លាំងក្លា ។

១៧-បទខែកបរឆេត : -សំរាប់ប្រគំយាងអញ្ជើញ និងកំដរគោលបំរើក្សត្រិយក្ខិណីមានរិទ្ធិនិងព្រាយពិលៀមកប្រក់ព្រំប្រសិទ្ធិពលិការឱ្យកូនចៅ ឬប្រគំជូនដំណើរនាងព្រាហ្មណីទាំងបួន ក្នុងរឿងព្រះវេស្សន្តរ ។

១៨-បទជើតប្ញើរ : -សំរាប់ប្រគំព្រះមហាឥសីជាចំបង និងនិមន្តឥសីអគ្គិនេត្រ ឥសីផ្លេចនេត្រឥសីភ្នែកគោណ៌ ឥសីភក្រវែង ឥសីពុទ្ធវង្ស ឥសីមុខិតេជ្ជោទាំងអស់អង្គមក



www.elibraryofcambodia.org

ប្រសិទ្ធិឱ្យសិស្សគណបានសុខសាន្ត ។

១៩-<u>បទជើតឈើង</u> : -សំរាប់ប្រគំបួងសួងឱ្យសូមយាងព្រះនាងទេវត ទេពអប្សរ បវរកញ្ញានិងព្រះមន៑មេខឡាទេវីរិទ្ធិក្រៃ ឧបទ្រព្យទាំងឡាយឱ្យកូនចៅបានសុខតរៀងទៅ ។

២០-<u>បទបឋម</u> : -សំរាប់ប្រគំនៅពេលទ័ពហនុមានឬស្វាចេញទៅច្បាំងធ្វើពិធីសមយុទ្ធនៃពលរេហ៍ ។

២១-<u>បទរុករុន</u> : -សំរាប់ប្រគុំថ្វាយបារមីផាវិសុរិយ៍នមាមិហាំជាបារមី ប្រកបដោយអង្គសច្ចៈវរៈមង្គលក្រៃកន្លង ។

២២-<u>បទជើតផាប់</u> : -សំរាប់នៅពេលទព័ស្វា និងទ័ពយក្ខ័ប្រយុទ្ធគ្នា ខ្ទួទល់ខ្លួនជាប់គ្នា ប្រយុទ្ធយកស្លាប់រស់រៀងខ្លួន ។

២៣-<u>បទមហាជ័យ</u> : -សំរាប់ប្រគំថ្វាយព្រះមហាក្សត្រអាសោរិភព មានរិទ្ធិតេជ្ជៈខ្លាំងក្រៃ ទ្រង់ប្រសិទ្ធិឱ្យកូនចៅបានសុខ ។

២៤-<u>បទសាធុការ</u> : -បានបកស្រាយពីខាងលើរួចហើយ ។

២៥-<u>បទជាយរឿ</u> : -សំរាប់ប្រគំថ្វាយក្សត្រីយក្ខិណី នាងសទ្ធមារនិងស្តេចព្រាយពិសៀមកទទួលដង្វាយជាទីគាប់ចិត្ត ។ លុះសេពសោយរួចហើយ សូមប្រសិទ្ធិកូនចៅបានសុខផង ។

២៦-<u>បទណោហ</u> : -សំរាប់ប្រគំនៅពេលអមព្រះរាជដំណើរ ក្រសាលប្រពាទ្យតាមផ្លូវជលសានិងប្រើក្នុងរឿងរាមកេរ្តិ៍ គ្រង់ឈុតសពនាងសេតាអណ្តែតទឹក ។

២៧-<u>បទខ្វះតុនម៉ាយ</u> : -សំរាប់ប្រគំយាងព្រះបាទកងចក្រ័ ព្រះបាទកងពន្ធ័លាន់រន្ទឺបំភ្លឺរិទ្ធិប្រសិទ្ធិពរកូនចៅ ។

២៨-<u>បទព្រាហ្មណ៍ដោះចិញ្ចៀនឬព្រាហ្មណ៍គិបរែន</u> : -សំរាប់ប្រគំយាងបារមី១០៨អង្គនិងព្រះគ្រូព្រាហ្មណ៍ព្រមទាំងព្រះឥន្ទ្រាធិរាជ និមន្តមកកំចាត់ឧបទ្រព្យចង្រៃឱ្យវិនាសសាបសូន្យទៅ ហើយប្រសិទ្ធិប្រក់ព្រំឱ្យកូនចៅបានសុខផង ។

២៩-<u>បទឡុងសុង</u> : -សំរាប់យាងបារមីគ្រប់ព្រះអង្គស្រង់ព្រះគង្គាជំរះកាយ សប្បាយ



www.elibraryofcambodia.org

ព្រះហឫទ័យត្រជាក់ត្រជុំ  បរមសុខសួស្តី  ប្រសិទ្ធិឱ្យកូនចៅបានសុខផង ។
៣០-<u>បទសែនព្រេនស៊ីឡាវ</u> : -  សំរាប់ប្រគំយាងនិងកំដរពារមីគ្រប់អង្គឆាន់និងសោយព្រះស្ងោយ  ដោយសោមនស្សហើយឱ្យពរសព្វសាធុការដល់កូនចៅផង ។
៣១-<u>បទបាចលាច "ប្រួយខៅផែក"</u> : -សំរាប់ប្រគំអញ្ជើញព្រាយក្បាលប្រាំបី  ព្រាយអាកាសសំពោងសក់ធំ  បិសាចរាជភូត  ទាំងអស់មកទទួលនូវចំណីអាហារ  បារីស្លាផ្កាភ្ញី  មានបំពងលាចគ្រប់មុខគ្មានខ្វះអ្វីឡើយ ។
៣២-<u>បទរៀនយៀន</u> : - សំរាប់ប្រគំនិងភ្ជំច្រៀងបង្ហិលពពិលថ្វាយពារមីក្រសាលយ៉ាងសប្បាយឬស្សត្រធម៌ជន្លោផង ។
៣៣-<u>បទដើតជូនគ្រូ</u> : -សំរាប់ប្រគំជូនដំណើរពារមីគ្រប់អង្គដែលស្ថិតក្នុងទីនេះសូមយាងត្រឡប់ទៅកាន់ទីស្ថានកន្លែងដើមវិញ ។
៣៤-<u>បទក្រៅភិបូភ្លេងឈប់</u> : -សំរាប់ប្រគំក្រោយពីពារមីយាងផុតពីមន្ទីរោងជ័យទៅកាន់កន្លែងរៀងៗខ្លួន ។

## ខ- <u>*ពិធីសំពះគ្រូតូច  ក្នុងវង់ពិណពាទ្យ*</u>

ឯរណ្តាប់រៀបចំគ្រឿងសក្ការៈបូជានិងជង្វាយផ្សេងៗ  មានរៀបចំប្រហាក់ប្រហែលជាមធ្យមនៃពិធីសំពះគ្រូធំដែរ ។ មុនដំបូងធ្វើការកិច្ច នមស្សការ ព្រះរតនត្រ័យ :
-នមោតស្ស:  ភគវតោអរហតោ  សម្មាសម្ពុទ្ធស្ស:(៣ចប់)  ពុទ្ធំអរធនំករោមិ  ធម្មំអរធនំករោមិ  សំឃំអរធនំករោមិ ។
-យើងខ្ញុំព្រះករុណាទាំងឡាយសូមថ្វាយវន្ទាប្រណាម្យអញ្ជលី  ថ្វាយបង្គំចំពោះព្រះបរមគ្រូបរមបពិតស្ថិតលើផែនភពព្រះធរណីគិរីបព្វតា  ព្រឹក្សាព្រៃភ្នំ  ក្រំថ្ម  បឹងបួ  ទន្លេជលសាទេព្តាស្ថិតនៅលើស្ថានវិមានអណ្តែតសោឡស់ជាន់ពន្លំក្រលាមហាប្រថពីស្តេចក្រុងពាលីម្ចាស់ទឹកដីរុក្ខសីមាអ្នកតាចាស់ស្រុករក្សាភូមិដ្ឋានបានសុខសួស្តី  សូមអញ្ជើញយាងគ្រូកំណើតបង្កើតរូបរាងកាយ  ផ្តល់ចំណេះចេះដឹងដល់យើងខ្ញុំរាល់គ្នា  សូមអញ្ជើញគ្រូធំ



www.elibraryofcambodia.org

ប្រគុំស្រាឡែកងស្គរ សំភោរ រនាត ពាទ្យពិណ មកប្រសិទ្ធិពរបវរសួស្តីឱ្យកូនចៅសិស្ស គណាមានជោគជ័យសិរីមង្គលវិបុលសុខគ្រប់ៗគ្នាហោង។ភ្លេងប្រគំ : ១-បទសាធុការ។

-ឱ កា ស វន្ទិ អាចារយំសុខំហោន្តុ សូមអញ្ជើញព្រះគ្រូព្រាហ្មណ៍ទ្រង់សិលបរិសុទ្ធ មកសន្និតក្នុងពិធីរោងនេះជាអធិបតី ។ ភ្លេងប្រគំ : ២-បទថានះតូច "ត្រាក់តូច"។

-ឱ កា ស ខ្ញុំសូមអញ្ជើញទេព្រ័ក្ស មេ ធមានុរិទ្ធិស័ក្តិ ស្ថិតនៅលើដែនសាសព្វបុព្វតា សូមយាងសម្តេចសាមណោរិទ្ធិក្រៃកំហែងព្រះសច្ចៈ អ្នកតែងឡានជាសាក្សីព្រះស្រីរត្នត្រ័យឱ្យពរសព្វសាធុការ ។សូមបង្គំនូវអង្គសច្ចំខន្តីបារមីទិព្វញាណទស្សមរៈ សច្ចំបំបាំងបាត់សព្វព្រះធរណី សំដែងរិទ្ធិឱ្យពរជ័យហោង ។ ភ្លេងប្រគំ : ៣-បទកាម៉ាន់

។

-ឱ កា ស ពិឃោគាររណំ សូមអញ្ជើញស្តេចហនុមានរិទ្ធិខ្លាំងក្រៃ មកស្តែងសិលកំកាត់ឧបទ្រព្យចង្រៃឱ្យបានសុខសាន្តរៀងទៅ ។ ភ្លេងប្រគំ : ៤-បទបថម ។

-ឱ កា ស ពុទ្ធំ ធម្មំ សំឃំ ថេរៈ ឯទិធឯហិ សូមយាងបារមីព្រះត្រ័យរ័ត្នក្រសាលតាមឆ្នេរ ព្រះគង្គាកំសាន្តព្រះរាជហរទ័យផង ។ ភ្លេងប្រគំ : ៥-បទលោហ៊ី ។

-ឱ កា ស បពិតើយ ទូលព្រះបង្គំសូមអរធនាទិមន្តយាងព្រះអាទិត្យ ព្រះចន្ទ័ដែលមានរស្មីបំភ្លឺទ្វីពលោកទាំង៤ បារមីសុខសេណែចយុជវាចិតៈ ។ ភ្លេងប្រគំ : ៦-បទស្ទីស។

-ឱ កា ស យើងខ្ញុំសូមលើកហត្ថាដាក់លើសិរសី ប្តូងសួងចំពោះព្រះឧមាទេវតមុធីមេខលាទេវីមៃព្រះស៊ុកឆោមស៊ុ យើងឱ្យសូមថ្វាយសក្ការៈបូជា សូមពរជ័យសុវត្ថិបំបាត់ភ័យហោង ។ភ្លេងប្រគំ : ៧-បទជើតឈឹង ។

-ឱ កា ស ចព្រហ្ម អរធនាទិមន្តព្រះមហាឥសីជាច្បង និមន្តឥសីអគ្គីនេត្រ ឥសីធ្មេចនេត្រ ឥសីមុនីតេជោ ឥសីតាបស គ្រប់អង្គ និមន្តមកឱ្យពរជ័យដល់សិស្សគណាបានសុខគ្រប់ៗគ្នាហោង ។ ភ្លេងប្រគំ : ៨-បទជើត ។



www.elibraryofcambodia.org

-ឱ ការ ស ទវេទ បពិតើយ យើងខ្ញុំសូមយាង ទេវបុត្រ ទេពពិតា ទេពព្រឹក្ស គ្រប់ទីតំបន់ព្រៃភ្នំក្រុំថ្ម សមុទ្រទន្លេបឹងបួ វាលរាប ទួលអង្គ ទេព្ឋារក្សាស្មេត្រឆត្រ័ សូមយាងមកកំចាត់សត្រូវ ធុកៗ ចៅៗ ស្វាហាយៈ ។ ភ្លេងប្រគំ : ៩-បទភ្នំ ។
-ឱ ការ ស វន្ទាមិសរណំ ពាថេវៈអាចារយ៍ជាទាមិ សូមអញ្ជើញព្រះគ្រូជំនាញវេទមន្ត ជាទីពឹងមកជួយប្រក់ព្រំដល់សិស្សគណគ្រប់ៗគ្នាហោង។ ភ្លេងប្រគំ : .១០-បទចំណាន ឬជំនាញ ។

-ឱ ការ ស យើងខ្ញុំទាំងឡាយសូមថ្វាយបង្គំចំពោះព្រះឥសូរ ព្រះនារាយណ៍ភមាត្រូយក្ខ សូមយាងមកប្រស់ព្រហ្មសិស្សគណឱ្យបានសុខសប្បាយតរៀងទៅ ។ ភ្លេងប្រគំ : ១១-បទ សទ្ធិកក្នុង ។
-ឱ ការ ស យើងខ្ញុំទាំងឡាយសូមយាងបារមីទាំងអស់ សេពសោយក្រយាបូជាកូនចៅ សូមច្រៀងរាំកំដរថ្វាយជាទីគាប់រាជហាទ័យ ។ ភ្លេងប្រគំ : ១២-បទក្រៅរាំ ។
-ឱ ការ ស យើងខ្ញុំទាំងឡាយ សូមហែរហមជូនដំណើរបារមីទាំងអស់យាងទៅកាន់ ទីកន្លែងដើមវិញដោយសុវត្ថិភាព ។ ភ្លេងប្រគំ : ១៣-បទលា ។

<u>បទភ្លេងសំរាប់ប្រើប្រាស់ក្នុងពិធី</u>

១-<u>បទសាធុការ</u> : -សំរាប់ប្រគំគោរពរំលឹកគុណគ្រូបាធ្យាយ ដែលបានដឹកនាំបំភ្លឺផ្លូវ ផ្តល់នូវចំណេះវិជ្ជាដល់ខ្លួនឬប្រគំនៅពេលឧទ្ទិសអនុមោទនា ត្រេកអរជាមួយនឹងស្ទូងនូវ អំពើល្អនោះផង ។

២-<u>បទថាន់ៈតូចឬគ្រាក់តូច</u> : - សំរាប់ប្រគំកំដរគ្រូអង្គអ្នកមានរីទ្ធិបេស្តាឧទ្ទិសសិល វេទមន្តដល់ព្រះឥសូរ ព្រះនារាយណ៍ និងអវលោកិស្វៈជាដើម ។
៣-<u>បទកាម៉ាន់</u> : -សំរាប់ប្រគំអញ្ជើញទេព្រឹក្សស្ថិតនៅដែនបព្វតា សូមយាងស្ដេចសាមណោរមានរីទ្ធិស្ដែងនូវកំហែងបរិស័ទ្យ ព្រះនាគរីទ្ធិក្រៃ កំហែងព្រះ សប្ដៈអ្នកទាំងឡាយនិងអង្គសច្ចំខន្តិបារមីទិព្វញាណទស្សមរៈសច្ចំបំបាំងបាត់ យាងមក ប្រសិទ្ធិពរឱ្យពរជ័យដល់កូនចៅសិស្សគណបានគ្រប់ៗគ្នាហោង ។



www.elibraryofcambodia.org

៤-បទបឋម : -សំរាប់ប្រគំអញ្ជើញស្តេចហនុមាន មានរិទ្ធិខ្លាំងក្រៃមកស្តែងសិល កំចាត់ឧបទ្រពចង្រៃឱ្យបានសុខសាន្តរៀងទៅ ។

៥-បទលោហ៏ : -សំរាប់ប្រគំហែរហមបារមីយាងក្រសាលតាមផ្លេះព្រះគង្គាកំសាន្តរាជហរទ័យ ។

៦-បទស្មឹស: -សំរាប់ប្រគំអរធនានិមន្តបារមីរិទ្ធិខ្លាំងក្លានិងសូមយាងព្រះអាទិត្យព្រះចន្ទ័ដែលមានរស្មីបំភ្លឺទ្វីបលោកទាំងបួន មកជាអធិបតីផង ។

៧-បទជើតឈឹង : -សំរាប់ប្រគំបួងសួងចំពោះព្រះឧមាទេវេតមុនីមេខឡាទេវិមៃ ព្រះស៊ុកឆោមស៊ី មកប្រសិទ្ធិកំចាត់គ្រោះថ្នាក់បំបាត់ភ័យហោង ។

៨-បទជើត : -សំរាប់ប្រគំអរធនានិមន្តព្រះមហាឥសីជាច្បង និមន្តឥសីអគ្គីនេត្រឥសីធ្មេចនេត្រឥសីតាបសគ្រប់អង្គ និមន្តប្រក់ព្រំឱ្យពរដល់កូនចៅសិស្សគណបានសុខគ្រប់ៗគ្នាហោង ។

៩-បទគុំ : -សំរាប់ប្រគំសូមយាងទេវបុត្រ ទេពធិតា ទេព្រក្ស គ្រប់ទីតំបន់ ព្រៃភ្នំក្រំថ្មលើទួលអង្គសមុទ្រទន្លេជលសាភលភប ទេព្ធារក្សាព្រះស្វេត្រឆ័ត្រ យាងមកកំចាត់សត្រូវ ធុកៗ ថេាៗ ស្វាហាយះ ។

១០-បទចំណានឬជំនាញ : -សំរាប់ប្រគំយាងអញ្ជើញព្រះគ្រូទ្រង់សិលវិសេសជំនាញវេទមន្តជាទីពឹងមាននាមថាវន្នាមិ សរណំ ចាថេវះ អចរិយំជានាមិ មកជួយប្រក់ព្រំកូនចៅសិស្សគណឱ្យបានសុខដុមរមនាតរៀងទៅ ។

១១- បទសន្ទឹកក្នុង ____ : -សំរាប់ប្រគំកំដរថ្វាយព្រះឥសូរ ព្រះនរាយណ៏ជាគ្រូយក្ខសូមយាងទតកំសាន្តសប្បាយនិងប្រស់ព្រហ្មកូនចៅ សិស្សគណគ្រប់ៗគ្នាហោង ។

១២-បទក្រៅរាំឬរាំថ្វាយ :-សំរាប់ប្រគំច្រៀងរាំថ្វាយបារមីសេពសោយគ្រឿងក្រយាបូជាជាទីគាប់ហរទ័យផង ។

១៣-បទលា : -សំរាប់ប្រគំហែរហមជូនបារមីទាំងអស់យាងទៅកាន់ទីកន្លែងដើមវិញក្រោយពីបានទទួលនូវសក្ការៈបូជាពីកូនចៅសិស្សគណរួចហើយដោយសុវត្ថិភាព។



www.elibraryofcambodia.org

*ក-ពិធីសំពះគ្រូភ្លេងវង់មហោរី*

របណ្ដាប់រៀបចំគ្រឿងសក្ការៈអាសនៈ ស្លាធម៌ បាយសីគ្រប់ថ្នាក់និងគ្រឿងដង្វាយផ្សេងៗ មានដូចជាពិធីសំពះគ្រូភ្លេងពិណពាទ្យដែរ ។ ប៉ុន្តែឈ្មោះបារមីត្រូវសន្និតនិងបទភ្លេងមានឈ្មោះខុសគ្នា ។ កម្មវិធីមានដូចតទៅ : មុនដំបូងប្រកាសអញ្ជើញបារមី

នមោតស្សៈ ភគវតោ អរហតោ សម្មា សម្ពុទ្ធស្សៈ (៣ចប់) ពុទ្ធំ អរធនំ ករោមិ ធម្មំ អរធនំ ករោមិ សំឃំ អរធនំ ករោមិ

-ឱ កា ស យើងខ្ញុំទាំងឡាយសូមថ្វាយបង្គំប្រណម្យ អញ្ជលី វន្ទាចំពោះព្រះបរមនាថបរមបពិតស្ថិតនៅលើស្ថានសោឡស់ជាន់ពាន់ក្រឡាមហាប្រថពី គីរីបព្វតាព្រឹក្សាព្រៃភ្នំក្រាំថ្មជ្រោះជ្រលងដងអូរ បឹងបួ សមុទ្រ ជលសា វាលរាប ប្រៃញាតិស្បាត ភូមិដ្ឋានបូរីវដ្តសីមា អ្នកតាចាស់ស្រុក ស្ដេចក្រុងពាលី ម្ចាស់ទឹកដីជាប្រធាន ។

សូមយាងអវលោកិស្វរៈ ព្រះឥសូរ ព្រះនារាយណ៍រាមា ព្រះពិស្ណុការវិទ្ធីខ្វាំងក្លា សូមនិមន្តព្រះមុនីឥសីទាំង១០៨អង្គ មកគង់ក្នុងទីនេះជាអធិបតី ។

សូមអញ្ជើញគ្រូតន្ត្រី ស្រមៃ ប៉ុអរ ទោត គង ជួង ឈឹង ត្រូទ្រសោ ទ្រអ៊ូ តះខេ ឃឹម ខ្លុយ ស្គរ រមនាជាទីមនោរម្យ ។

សូមអញ្ជើញយាងបារមីទាំងអស់មកគង់ស្ថិតលើអាសនៈនេះ ដើម្បីអបអរសាទរទទួលនូវគ្រឿងសក្ការៈបូជាមាន•ផ្លែឈើ នំចំណី បង្អែមចង្ហាប បារីស្លា ផ្កាភ្ញី សំពត់អាវសារស្បៃ គ្រឿងក្រអូបគ្រឿងលាបផ្សេងៗ ដែលកូនចៅសិស្សគណបានរៀបចំថ្វាយនៅចំពោះមុខនេះ សូមយាងបារមីទាំងអស់សេពសោយដោយសោមនស្ស ។ កាលបើបានសេពសោយរួចហើយសូមបារមីគ្រប់អង្គប្រទានពរសព្វសាធុការ ដល់សិស្សគណទាំងអស់ឱ្យបានសុខសប្បាយ ចំរុងចំរើនឈ្នះមារសត្រូវគ្រប់ទិសទីចាប់តាំងពីថ្ងៃនេះតទៅ :

-សូមអញ្ជើញព្រះគ្រូកំណើតបង្កើតរូបរាងកាយយើងរាល់គ្នា អប់រំឱ្យចំណេះដឹងបានសុខសួស្ដី សិរីមង្គលគ្រប់ប្រការ ។ ភ្លេងប្រគំ : ១-បទអាយុយឺនយូរឬអាយុវែង ។

-សូមអញ្ជើញទេព្ដាទាំង៨ទិសមកគង់ក្នុងមន្ទីររោងនេះ ដើម្បីឱ្យពរជ័យដល់កូនចៅសិស្ស



www.elibraryofcambodia.org

គណបានសុខតរៀងទៅ ។ ភ្លេងប្រគំ : ២-បទទេពរាំថ្លៃ ។

-សូមយាងទេព្តាគ្រប់អង្គព្រារព្ធ ឧទ្ទិសវេទមន្តប្រទក្សិណជុំវិញពិធីរោង ។ ភ្លេងប្រគំ : ៣-បទទេពព្រារព្ធ ។

-សូមទេព្តាគ្រប់អង្គទ្រង់និមិត្តបារមី ប្រសិទ្ធិដល់កូនចៅសិស្សគណឱ្យបានប្រកបដោយសុខសួស្តិគ្រប់ៗគ្នា ។ ភ្លេងប្រគំ : ៤-បទទេពនិមិត្ត ។

-សូមអញ្ជើញទេព្តាគ្រប់អង្គយាងផ្ទំ ទតក្រសាលនៅលើទីអាសនៈជាទីមនោរម្យ ។ ភ្លេងប្រគំ : ៥-បទទេពបន្ទំឬទេព្តាផ្ទំ ។

-សូមយាងបារមីស្តេចត្រដំត្រៃនិងព្រះគ្រូព្រាហ្មណ៍មកស្ថិតនៅលើមន្ទីររោងនេះ។ ភ្លេងប្រគំ : ៦-បទដំត្រួតពាជាន់ ។

-សូមយាងព្រះវិស្វកម្ម ទេវបុត្រមករួបរួមក្នុងពិធីរោងនេះ ។ ភ្លេងប្រគំ : ៧-ភ្លេងបទវិស្វកម្មពាជាន់ ។

-សូមយាង ព្រះនាងទេវីមុនីមេខឡា រិទ្ធិអស្ចារ្យមកគង់ប្រថាប់ប្រក់ព្រំឱ្យពរដល់កូនចៅសិស្សគណបានសុខក្រប់ៗគ្នាហោង ។ ភ្លេងប្រគំ : ៨-បទទេវេក ។

-សូមយាងសក្កទេវរាជចតុលោកបាលជាស្តេចនៃទេវតា មកគង់ប្រថាប់លើអាសនៈនេះជាអធិបតី ។ ភ្លេងប្រគំ : ៩-បទខ្វបចក្រវាឡពាជាន់ ។

-ន្ទ កា ស ចន្ទ្រាអាទិត្យវង្ស សូមយាងព្រះអាទិត្យ ព្រះចន្ទ បំភ្លឺទីបទាំងបួន មកប្រទានទូវសច្ចៈយុត្តិធម៌ សុខមាលភាពដល់មនុស្សលោកទូទៅ។ ភ្លេងប្រគំ : ១០-បទចន្ទ្រចៅខា ។

-សូមយាងព្រះមុនីឥសីទាំង១០៨អង្គ មកប្រសិទ្ធិដល់កូនចៅសិស្សគណឱ្យបានសុខសប្បាយតរៀងទៅ ។ ភ្លេងប្រគំ : ១១-បទតាយ៉ៃពាជាន់ ។

-សូមយាងស្តេចព្រះថោងវិរៈក្សត្រដ៏ឧត្តមមកជួយអបអរសោទរក្នុងពិធីនេះ ជាប្រពៃណីផង ។ ភ្លេងប្រគំ : ១២-បទព្រះថោង ។

-យើងខ្ញុំព្រះករុណា សូមថ្វាយបុប្ផ ផ្កាភ្ញី គ្រឿងក្រអូប គ្រឿងលាបពិដោឈ្មុយឈ្ងប់



www.elibraryofcambodia.org

សូមទទួលដោយសោមនស្សចេតនា ។ ភ្លេងប្រគុំ : ១៣-បទបុប្ផាស្ថានសួគ៌ ។

-យើងខ្ញុំសូមថ្វាយនូវផ្កាចំប៉ី ជាទីគាប់រាជហឫទ័យដល់បារមីគ្រប់អង្គ ។ ភ្លេងប្រគុំ : ១៤-បទមេលីម ។

-សូមយាងអញ្ជើញបារមីគ្រប់ព្រះអង្គសេពសោយក្រយាបូជា ដែលកូនចៅសិស្សគណបានរៀបចំថ្វាយនៅចំពោះមុខនេះដោយរីករាយ។ភ្លេងប្រគុំ : ១៥-បទធូរាំងបាយប្ដូរ ។

-យើងខ្ញុំទាំងឡាយសូមថ្វាយនៅបទភ្លេងកំដររបាំអភិវន្ទតាមប្រពៃណីពីបុរាណ សូមទតកំសាន្តរាជហឫទ័យ ។ ភ្លេងប្រគុំ : ១៦-បទបារលុត ។

-សូមយាងបារមីគ្រប់អង្គទាំងអស់ចុះទតសួនឧទ្យានមានបុប្ផារីកបំរុះពណ៌មាស ពណ៌ប្រាក់ប្រទាក់ប្រទងរងផ្ការត្នរជាទីសព្វរាជហឫទ័យផង ។ ភ្លេងប្រគុំ : ១៧-បទក្រសាលឧទ្យានបាជាន់ ។

-សូមយាងបារមីគ្រប់អង្គស្រួលព្រះកាយមុននឹងត្រឡប់ទៅកាន់លំនៅដើមវិញ ។ ភ្លេងប្រគុំ : ១៨-បទស៊ីន្ទូន ។

-ជាទីអវសាន្តនេះ សូមបារមីគ្រប់អង្គទាំងអស់ បានទទួលនូវគ្រឿងសក្ការៈបូជាសេពសោយទតក្រសាលគ្រប់សព្វអស់ហើយ យើងខ្ញុំសូមជូនដំណើរបារមីគ្រប់អង្គយាងទៅកាន់ទីឋានកន្លែងដើមវិញដោយសុវត្ថិភាព ។ ភ្លេងប្រគុំ : ១៩-បទអុំទូក ។

-ក្រោយពីបារមីយាងចេញទៅអស់យើងខ្ញុំជាកូនចៅសិស្សគណទាំងអស់ សូមអបអរសាទរជូនដំណើរនិងទទួលនូវពរជ័យគ្រប់ប្រការគ្រប់ៗគ្នាហោង។ ភ្លេងប្រគុំ :២០-បទការប៉ីបាយសេ ។

<u>បទភ្លេងសំរាប់ប្រើប្រាស់ក្នុងពិធី</u>

១-<u>បទអាយុយឺនយូរឬអាយុវែង</u> :-សំរាប់អញ្ជើញព្រះគ្រូកំណើតបង្កើតរូបរាងកាយយើងរាល់គ្នា អប់រំឱ្យចំណេះដឹងបានសុខសួស្តី សិរីមង្គលគ្រប់ប្រការ ។

២-<u>បទទេពវិថ្លល</u> : -សំរាប់អញ្ជើញទេវតាទាំង៨ទិសមកគង់ក្នុងមន្ទីររោងនេះដើម្បីឱ្យពរជ័យដល់កូនចៅសិស្សគណបានសុខគួររៀងទៅ ។



www.elibraryofcambodia.org

៣-បទទេពប្រារព្ធ : -សំរាប់យាងទេព្តាគ្រប់អង្គប្រារព្ធ ឧទិសវេទមន្តប្រទ័ក្សិណជុំវិញ ពិធីរោង ។

៤-បទទេពនិមិត្ត : -សំរាប់យាងទេព្តាគ្រប់អង្គទ្រង់និមិត្តបារមី ប្រសិទ្ធិដល់កូនចៅ សិស្សគណឱ្យបានប្រកបដោយសុខសួស្តីគ្រប់ៗគ្នា ។

៥-បទទេពបន្ទំឬទេព្តថ្មី :-សំរាប់អញ្ជើញទេព្តគ្រប់អង្គយាងថ្មី ទតក្រសាលទៅលើទីអាសនៈជាទីមនោរម្យ ។

៦-បទអំគ្រូត៣ជាន់ :-សំរាប់យាងបារមីស្តេចគ្រអំគ្រ និងព្រះគ្រូព្រាហ្មណ៍មកស្ថិតនៅលើមន្ទីររោងនេះ ។

៧-ភ្លេងបទវិស្សកម្ម៣ជាន់:-សំរាប់យាងព្រះវិស្សកម្មទេវបុត្រមកប្រជុំ ក្នុងពិធីរោងនេះ។

៨-បទទេវេត : -សំរាប់យាងព្រះនាងទេវីមុនីមេខឡាវិទ្ធិអស្ចារ្យ មកគង់ប្រថាប់ប្រក់ព្រំ ឱ្យពរដល់កូនចៅ សិស្សគណបានសុខគ្រប់ៗគ្នាហោង ។

៩-បទខ្ទបចក្រវាឡ៣ជាន់ :-សំរាប់យាងសក្កទេវរាជ ចតុលោកបាលជាស្តេចនៃទេវតា មកគង់ប្រថាប់លើអាសនៈនេះជាអធិបតី ។

១០-បទចន្ទ័ចៅខា : -សំរាប់យាងព្រះអាទិត្យព្រះចន្ទ័បំភ្លឺទ្វីបទាំងបួន មកប្រទាននូវសច្ចៈយុត្តិធម៌ សុខមាលភាពដល់មនុស្សលោកទូទៅ ។

១១-បទតាយ៉េ៣ជាន់ : -សំរាប់យាងព្រះមុនីឥសីទាំង១០៨អង្គ មកប្រសិទ្ធិដល់កូនចៅសិស្សគណឱ្យបានសុខសប្បាយតរៀងទៅ ។

១២-បទព្រះថោង :-សំរាប់យាងស្តេចព្រះថោងវិរៈក្សត្រដ៏ឧត្តម មកជួយអបអរសាទរ ក្នុងពិធីនេះជាប្រពៃណីផង ។

១៣-បទបុប្ផស្ពានសួគ៌ : -សំរាប់ថ្វាយបុប្ផ ផ្កាភ្ញី គ្រឿងក្រអូប គ្រឿងលាប ពិដោឈ្មុយឈ្ងប់សូមទទួលដោយសោមនស្សចេតនា ។

១៤-បទមេលើម :-យើងខ្ញុំសូមថ្វាយនូវផ្កាចំប៉ីជាទីគាប់រាជហរទ័យដល់បារមីគ្រប់អង្គ ។

១៥-បទធូរាំងបាយបួរ :-សំរាប់យាងអញ្ជើញបារមីគ្រប់ព្រះអង្គសេពសោយ ក្រយាបូជ



www.elibraryofcambodia.org

ដែលកូនចៅសិស្ស គណបានរៀបចំថ្វាយនៅចំពោះមុខនេះដោយរីករាយ ។
១៦-បទបាវលុត : -សំរាប់ថ្វាយនៅបទភ្លេងកំដរពេលាំ អភិវឌ្ឍ តាមប្រពៃណីពីបូរាណ សូមទតកំសាន្តរាជហឫទ័យ ។
១៧-បទក្រសាលឧឡុកពាជាន់ : -សំរាប់យាងបារមីគ្រប់អង្គទាំងអស់ ចុះទតសួនឧទ្យានមានបុប្ផារីកចំរុះពណ៌មាសពណ៌ប្រាក់ប្រទាក់ប្រទង រងផ្ការ គួរជាទីសព្វរាជហឫទ័យផង ។
១៨-បទស៊ីនួន :-សំរាប់យាងបារមីគ្រប់អង្គ សំរួលព្រះកាយមុននឹងត្រឡប់ទៅកាន់លំនៅដើមវិញ ។
១៩-បទអ៊ុំទូក : -សំរាប់យាងបារមីគ្រប់អង្គទាំងអស់បានទទួលនូវគ្រឿងសក្ការៈបូជា សេពសោយទតក្រសាលគ្រប់សព្វអស់ហើយ យើងខ្ញុំសូមជូនដំណើរបារមីគ្រប់អង្គយាង ទៅកាន់ទីឋានកន្លែងដើមវិញដោយសុវត្ថិភាព ។
២០-បទការប៉ីបាយសេ : -សំរាប់ជូនដំណើរបារមីយាងត្រឡប់ទៅវិញ យើងខ្ញុំជាកូនចៅសិស្សគណទាំងអស់ សូមអបអរសាទរជូនដំណើរនិងទទួលនូវពរជ័យគ្រប់ប្រការគ្រប់ៗគ្នាហោង ។

## ការសង្កេតពិចារណា

**ភ្លេងអារក្ស :**

-ភ្លេងអារក្សគឺជាភ្លេងមួយមានលក្ខណៈបែបបទជាភ្លេងបំពេនូវជំនឿព្រលឹង មេបាគ្រូបាធ្យាយ អារុក្ខអារក្ស អ្នកតាចាស់ស្រុករក្សាទឹកដីពីសម័យបុរាណកាលនិយមនិងជាចិត្តសាស្ត្រព្យាបាលរោគសតិអារម្មណ៍ពង្រឹងសាមគ្គីភាពគ្រួសារខ្មែរទូទៅផង ។
-ភ្លេងអាពាហ៍ពិពាហ៍ (មង្គលការ) ភ្លេងនេះជាភ្លេងរក្សានូវទំរង់ បែបបទសញ្ចេតនា



www.elibraryofcambodia.org

ប្រពៃណីជាតិ អប់រំស្មារតី មនសិការចរិយាធម៌ សីលធម៌និងសង្គមធម៌ ។ ផ្សារភ្ជាប់មនោសញ្ចេតនាស្វាមីភរិយាថ្មីទៅនឹងទឹកដីជាតិមាតុភូមិរបស់យើង ។

**ភ្លេងគងស្គរឬធាំមួង :**

-ភ្លេងនេះមានអនុភាពណែនាំនូវជីវិតចិត្តនៃមនុស្សម្នាក់ៗ ឱ្យបែរទៅរកការស្ងប់រំងាប់ កើតធម៌សង្វេគពិចារណានូវរូបរាងកាយ ដែលទទួលនូវទុក្ខវេទនាគ្រប់បែបយ៉ាង មិនទៀងទាត់វិនាសទៅវិញជាធម្មតា ព្រោះមិនមែនជារបស់យើង ។ ភ្លេងនេះអប់រំចិត្តមិនឱ្យភ្លើតភ្លើន មិនឱ្យប្រមាទ ធ្វើឱ្យចិត្តស្ថិតនៅក្នុងចិត្តកុសល ធម្មារម្មណ៍ផង ។

**ភ្លេងស្គរឈ្នះ ឬ ខ្លុងខ្លាក់ :**

-ភ្លេងនេះ បានចង្អុលបង្ហាញបញ្ជាក់ពីអាយុសង្ខាររបស់មនុស្ស ការកើត ចាស់ ឈឺ ស្លាប់ជាពួជធារ ជាកៀមរពកនិងជាបច្ច័យនៃកម្មនិងផល ដែលបុគ្គលម្នាក់ៗបានធ្វើ ហើយត្រូវតែទទួលយកមិនអាចជៀសវាងបាន ។

**ភ្លេងពិណពាទ្យ :**

-ភ្លេងពិណពាទ្យគឺជាភ្លេងមួយសំរាប់តំឡើងពិធី ។ ជាភ្លេងសក្ការៈបែបទេវនិយម មានលក្ខណៈរក្សានូវថាមពល អច្ឆរិយជំនឿ បង្កើនស្មារតីបីតិបញ្ញា សិលធម៌ថ្លៃថ្នូររុងរឿង និជារស្មីសោភ័ណនៃវប្បធម៌សិល្បៈផង ។

**ភ្លេងមហោរី :**

-ភ្លេងមហោរីក៏ជាភ្លេងមួយសម្រាប់តំឡើងពិធីដូចជាភ្លេងពិណពាទ្យដែរ ។ លក្ខណៈសាច់បទមានក្បួនខ្នាតក្រិតក្រមច្បាស់លាស់ ជាក់លាក់ដូចគ្នា ។ សម្រាប់ប្រគំសំពះ



www.elibraryofcambodia.org

ភ្លេងផ្ទៃកតន្ត្រីមហោរី គោរពពិធីបុណ្យប្រពៃណីជាតិ ព្រមទាំងប្រគំកំដរបរិយាកាសជូនភ្ញៀវកិត្តិយសក្នុងពិធីជប់លៀងទៀតផង ។

## ៦_សំយោគ

គោលដៅនៃការសិក្សាភល់ចំណុចទាំងឡាយ បានបង្ហាញឱ្យយើងស្គាល់នូវតួនាទីនិងសារៈសំខាន់របស់តន្ត្រីខ្មែរក្នុងព្រះរាជាណាចក្រកម្ពុជា តាំងពីបូរាណរហូតមកដល់បច្ចុប្បន្នកាល ។

ការវិភាគនេះ ក៏អាចបង្ហាញនូវភាពសម្បូរបែបនៃតន្ត្រីខ្មែរ ព្រមទាំងវ័យចំណាស់របស់វប្បធម៌នេះ ដែលចាំបាច់យើងត្រូវថែរក្សាឱ្យបានគង់វង់សំរាប់ខេមរៈជាតិជំនាន់ក្រោយ ម្យ៉ាងទៀតយើងជឿជាក់ថា ការប្រមូលផ្តុំរៀបរយចងក្រងទាំងប៉ុន្មានខាងលើនេះគ្រាន់តែជាការកត់ត្រានូវការចងចាំនិងបទពិសោធន៍ផ្ទាល់ខ្លួន ដែលគ្រូភ្លេងខ្មែរបូរាណមួយរូបបានរួមចំណែកនិងអាចផ្តល់នូវចំណេះដឹងជាទីន្នផលមួយចំនួន ដល់មិត្តអ្នកអានជាទីគោរពទាំងឡាយបន្ថែមនូវចន្លោះលើចំណុចណាមួយបើពុំច្រើនក៏តិចដែរ ។ កម្មវត្ថុនេះជាលក្ខណៈបូកសរុបសង្ខេបខ្លីតែប៉ុណ្ណោះ។



www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

យើងខ្ញុំជាកូន ខ្ចៅ យ៉ាត់ណៃ, ខ្ចៅ សុផល, ខ្ចៅ វិសាល, ខ្ចៅ វ៉ាមុន, ខ្ចៅ ភារាជា, ខ្ចៅ ចំរើន និង ខ្ចៅ ភារី
បានឧបត្ថមការផ្សាយសៀវភៅនេះជា eBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ចៅ ៣ញ និង ឧបាសិកា ឈរ យឿន

(ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប)

ស្កេនជា eBook ដោយ អ៊ិត ចន្ទស៊ីណា
ខែមិនា ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្ចៅ ឃុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org

UNESCO
CAMBODIA

SECOND PRINGTING SPONSORED BY
UNESCO CAMBODIA
OCTOMBER 2000
335 COPIES

www.elibraryofcambodia.org